ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education Youth and Sport


វិទ្យាស្ថានជាតិអប់រំ

National Institute of Education

**យ៉ុន សុខេន**

**YON SOKHEN**


# កត្តាជោគជ័យរបស់សិស្សទទួលបាននិទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា

## ករណីសិក្សា៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

Successful factors for students to get grade A in national upper secondary school examination in Cambodia

Case Study៖ Royal University of Phnom Penh

**និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ**

**ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ**

**ភ្នំពេញ ២០១៩**

ក្រសួងអប់រំ យុវជន និងកីឡា
**Ministry of Education Youth and Sport**

វិទ្យាស្ថានជាតិអប់រំ
**National Institute of Education (NIE)**


យ៉ុន សុខេន
YON SOKHEN


# កត្តាជោគជ័យរបស់សិស្សទទួលបាននិទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា

## ករណីសិក្សា៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

Successful factors for students to get grade A in national upper secondary school examination in Cambodia

Case Study៖ Royal University of Phnom Penh

និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ
ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

សាស្ត្រាចារ្យណែនាំ៖ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

ឆ្នាំសិក្សា ២០១៨ - ២០១៩

**ក្រសួងអប់រំ យុវជន និងកីឡា**
**Ministry of Education Youth and Sport**

**វិទ្យាស្ថានជាតិអប់រំ**
**National Institute of Education**

# យ៉ុន សុខេន

YON SOKHEN

# កត្តាជោគជ័យរបស់សិស្សទទួលបាននិទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា

## ករណីសិក្សា៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

Successful factors for students to get grade A in national secondary upper school examination in Cambodia

Case Study៖ Royal University of Phnom Penh

គណៈកម្មការវាយតម្លៃនៃការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ថ្ងៃទី ខែ ឆ្នាំ២០២០

**និក្ខេបបទនេះត្រូវបានវាយតម្លៃដោយ៖**

ប្រធានគណៈកម្មការ

គ្រូវាយតម្លៃទី១

គ្រូវាយតម្លៃទី២

គ្រូវាយតម្លៃទី៣

លេខាកត់ត្រា

ឯកភាពដោយ៖

**នាយកវិទ្យាស្ថានជាតិអប់រំ**

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

**តំណាងក្រសួងអប់រំ យុវជន និងកីឡា**

**ឯកឧត្តមបណ្ឌិត ជ័យ សារិន**

# សេចក្តីប្រកាសរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ **យ៉ុន សុខេន** សូមបញ្ជាក់ថានិក្ខេបបទដែលមានចំណងជើង **«កត្តាជោគជ័យរបស់សិស្សទទួលបាននិទ្ទេស** A **ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា»** ករណីសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។

ស្នាដៃនេះពុំទាន់ត្រូវបានគេយកមកប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រនៅវិទ្យាស្ថានជាតិអប់រំ ឬសាកលវិទ្យាល័យណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ឬខ្លឹមសារអ្វីមួយត្រូវបានយកមកប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាត ឬចុះបញ្ជីឯកសារយោងនោះឡើយ ។ និក្ខេបបទស្រាវជ្រាវ និងចងក្រងខាងលើនេះពិតជាការស្រាវជ្រាវរបស់ខ្ញុំបាទប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

ហត្ថលេខា

**យ៉ុន សុខេន**

# ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

ក្នុងនាមជាសាស្ត្រាចារ្យណែនាំគោល នៃការសរសេរនិក្ខេបបទស្រាវជ្រាវនេះ សូមបញ្ជាក់ថាបេក្ខជនឈ្មោះ **យ៉ុន សុខេន** ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវខាងលើប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥៦

រាជធានីភ្នំពេញ ,ថ្ងៃទី ខែ ឆ្នាំ២០២០

**ហត្ថលេខា**

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកទាំងអស់គ្នា ដែលបានចូលរួមចំណែកជួយជ្រោមជ្រែង និងលះបង់ពេលវេលាដ៏មានតម្លៃក្នុងការចងក្រងនិក្ខេបបទនេះឡើង។

ជាបឋមខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោកឪពុក **យ៉ុន ចាប** និងអ្នកម្ដាយ **តឹក សុខន** ដែលអ្នកមានគុណទាំងពីរបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ផ្ដល់នូវដំបូន្មានល្អៗ និងបានបញ្ជូនកូនឱ្យចូលរៀនតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សាដោយមិនគិតពីការនឿយហត់និងលំបាក ព្រមទាំងតស៊ូគ្រប់បែបយ៉ាងដើម្បីកូនទទួលបានចំណេះដឹងដល់សព្វថ្ងៃនេះ។

លោកស្រី **ស្រឿន សុភាព** ជាភរិយានិងក្រុមគ្រួសារខ្ញុំ ដែលបានជួយជ្រោមជ្រែងផ្នែកថវិកា ស្មារតីនិងលើកទឹកចិត្តឱ្យខ្ញុំបាទបានបន្តការសិក្សាឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី ២ ឆ្នាំសិក្សា ២០១៨-២០១៩។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **បណ្ឌិត សៀង សុវណ្ណារ៉ា** ជាសាស្រ្តាចារ្យណែនាំគោលដែលបានផ្ដល់មតិយោបល់ល្អៗពីរបៀបរៀបចំកម្រងសំណួរ ការជ្រើសសំណាកដើម្បីធ្វើការសម្ភាស ជាពិសេសជំរុញឱ្យយើងខ្ញុំខិតខំប្រឹងប្រែងជម្នះឧបសគ្គដើម្បី សម្រេចបាននូវការសរសេរនិក្ខេបបទហូតទទួលបានជោគជ័យប្រកបដោយមោទនភាព។

សូមថ្លែងអំណរគុណចំពោះឯកឧត្តម **បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កើតឱ្យមានវគ្គបណ្ដុះបណ្ដាលនាយកសាលានេះឡើង។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **បណ្ឌិត សៀង សុវណ្ណារ៉ា** នាយកវិទ្យាស្ថានជាតិអប់រំដែលបានរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្ដុះបណ្ដាលវគ្គនាយកសាលាឱ្យក្លាយជាអ្នកគ្រប់គ្រងអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

សូមថ្លែងអំណរគុណផងដែរដល់ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លោកប្រធានការិយាល័យសិក្សា និងប្អូនៗសិស្សនិទ្ទេស A ទាំងអស់នៃ **សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** ដែលបានអនុញ្ញាត និងសហការក្នុងការចូលរួមបំពេញកម្រងសំណួរធ្វើឱ្យការប្រមូលទិន្នន័យសម្រាប់ការសរសេរនិក្ខេបបទនេះទទួលបានជោគជ័យ។

សូមថ្លែងអំណរគុណដល់គ្រូឧទ្ទេសគ្រប់មុខវិជ្ជានៅវិទ្យាស្ថានជាតិអប់រំ ដែលបានជួយជ្រោមជ្រែងកិច្ចការស្រាវជ្រាវនេះ។

ជាទីបញ្ចប់ សូមគោរពជូនពរលោកអ្នកមានគុណ ឯកឧត្តម លោក លោកស្រីទាំងអស់ជួបតែសេចក្ដីសុខ កម្លាំងមាំមួន សុខភាពល្អនិងសម្រេចគ្រប់ភារកិច្ច និងកិច្ចការទាំងឡាយ។

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥៦

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២០

និស្សិតវគ្គនាយកសាលា

**យ៉ុន សុខេន**

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដើម្បី រកឱ្យឃើញនូវកត្តាជោគជ័យរបស់សិស្ស ដែលទទួលបាននិទ្ទេស A ។ ភាគសំណាកក្នុងការសិក្សានេះគឺសិស្សនិទ្ទេសA ចំនួន ២១នាក់ ដែលកំពុងរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលមកពីបណ្ដាខេត្តនានានៅទូទាំងប្រទេសកម្ពុជា។ ឧបករណ៍ដែលប្រើប្រាស់សម្រាប់ការស្រាវជ្រាវនេះគឺកម្រងសំណួររៀបចំឡើងដោយអ្នកស្រាវជ្រាវ ហើយចែកចេញជា៤ ផ្នែក គឺៈ (១) ព័ត៌មានទូទៅរបស់សិស្សនិទ្ទេសAម្នាក់ៗ (២) កត្តាផ្ទាល់ខ្លួន (៣) កត្តាសាលារៀន និង (៤) កត្តាគ្រួសារ។ ទិន្នន័យដែលប្រមូលបាន ត្រូវបានវិភាគដោយការផ្ដុំគំនិតទៅតាមសំណួរនិមួយៗ និងមានផ្នែកខ្លះ ធ្វើឡើងតាមកម្មវិធី Excel 2010 ។

លទ្ធផលសំខាន់ៗនៃការសិក្សាស្រាវជ្រាវនេះ អាចសរុបបានពីកត្តាជោគជ័យរបស់សិស្សទទួលបាននិទ្ទេសAគឺមានដូចខាងក្រោមៈ

១- កត្តាខ្លួនឯងៈផ្ដោតសំខាន់ទៅលើការសិក្សាដោយខ្លួនឯងនៅផ្ទះ រៀនជាមួយគ្រូល្អៗ រៀនគួរជាមួយគ្រូ ការអានសៀវភៅ ការសិក្សាស្រាវជ្រាវធ្វើលំហាត់តាមរយៈសៀវភៅ Internet បណ្ណាល័យ សៀវភៅកំណែ និងក្លឹបសិក្សានៅសាលា។

២-កត្តាសាលាៈ គណៈគ្រប់គ្រងយកចិត្តទុកដាក់ក្នុងការសិក្សារបស់សិស្ស ការលើកទឹកចិត្ត ការផ្ដល់ប្រាក់រង្វាន់ សម្ភារៈសិក្សា លោកគ្រូអ្នកគ្រូបានបង្រៀនដោយយកចិត្តទុកដាក់ សាលារៀនមានបរិស្ថានល្អក្នុងការទាក់ទាញសិស្ស មានបណ្ណាល័យ មានបន្ទប់កុំព្យូទ័រ និងបន្ទប់ពិសោធន៍សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។

៣- កត្តាគ្រួសារៈ ឪពុកម្ដាយ រឺអ្នកអាណាព្យាបាលជួយលើកទឹកចិត្តឱ្យខិតខំរៀនសូត្រ ផ្ដល់ជាប្រាក់រង្វាន់លើកទឹកចិត្តក្នុងការប្រឡង ផ្ដល់សម្ភារៈសិក្សា ផ្ដល់អាហារ និងជួយជំរុញឱ្យកូនៗមករៀន។

ក្នុងចំណោមកត្តាទាំងបីខាងលើ កត្តាដែលមានឧត្តមភាពជាងគេហើយនាំឱ្យសិស្សទទួលបាននិទ្ទេសA គឺកត្តាផ្ទាល់ខ្លួន ។

# តារាងមាតិកា

**សេចក្តីប្រកាសរបស់បេក្ខជន** ....... iii

**ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ** ....... iv

**សេចក្តីថ្លែងអំណរគុណ** ....... v

**មូលន័យសង្ខេប** ....... vi

**ចំណងជើងក្រាហ្វិក** ....... XI

**ជំពូកទី ១ សេចក្តីផ្តើម**

១.១សាវតារ ....... 2

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ....... 6

១.៣ គោលបំណងនៃការសិក្សាស្រាវជ្រាវ ....... 7

១.៤ សំណួរនៃការស្រាវជ្រាវ ....... 7

១.៥ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ....... 7

១.៦ សារៈប្រយោជន៍នៃការស្រាវជ្រាវ ....... 8

១.៧ រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ ....... 8

**ជំពូកទី ២ រំលឹកទ្រឹស្តី**

២.១ និយមន័យ ....... 10

២.២ គន្លឹះក្នុងការរៀនឱ្យបានជោគជ័យ ....... 11

២.៣ ទស្សនៈរបស់សិស្សទទួលបាននិទ្ទេស A នៅកម្ពុជា ....... 15

២.៤ ទស្សនៈអ្នកប្រាជ្ញ និងបុគ្គលល្បីៗដែលជោគជ័យក្នុងការសិក្សា ....... 19

២.៥ បញ្ហាសិស្សក្នុងការសិក្សា ....... 22

២.៥.១ កត្តាខាងក្នុង ....... 22

២.៥.២ កត្តាខាងក្រៅ ....... 22

២.៦ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩- ២០២៣ ........ 24
២.៦.១ ការអភិវឌ្ឍធនធានមនុស្ស ........ 24
២.៧ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣ ........ 24
២.៨ ការអភិវឌ្ឍយុវជន ដើម្បីភាពជាពលរដ្ឋមានគុណភាពនៅកម្ពុជា ........ 25
២.៩ ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ២០៣០ ........ 26
២.៩.១ ការកសាងធនធានមនុស្ស ........ 26
២.៩.២ ការអប់រំមធ្យមសិក្សា ........ 27
២.១០ ទិន្នន័យសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីឆ្នាំ ២០១៤-២០១៩ ........ 28
២.១១ អំណោយដល់ជ័យលាភីសិស្សនិទ្ទេស A ទុកជាអនុស្សាវរីយ៍ពីរាជរដ្ឋាភិបាល ........ 31
២.១២ ការជូនអំណោយដល់នាយក នាយិកាមកចូលរួម ទុកជាអនុស្សាវរីយ៍ ........ 32

## ជំពូកទី ៣ វិធីសាស្ត្រនៃការស្រាវជ្រាវ

៣.១ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ 34
៣.២ ភាគសំណាក ........ 34
៣.៣ ឧបករណ៍ស្រាវជ្រាវ ........ 34
៣.៤ វិធីសាស្ត្រនៃការប្រមូលទិន្នន័យ ........ 35
៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ ........ 36

## ជំពូកទី ៤ លទ្ធផលស្រាវជ្រាវ

៤.១ ព័ត៌មានទូទៅស្តីពីការស្រាវជ្រាវ ........ 38
៤.២ លទ្ធផលនៃការសិក្សាស្រាវជ្រាវ ........ 38
៤.២.១ ព័ត៌មានទូទៅរបស់សំណាក ........ 38
៤.២.២ មុខរបរឪពុក ម្តាយសិស្សនិទ្ទេសA ........ 38
៤.៣ កត្តាផ្ទាល់ខ្លួន ........ 40

៤.៣.១ កត្តាផ្ទាល់ខ្លួន ដែលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបាននិទ្ទេសA ....................40
៤.៣.២ វិធីសាស្ត្រអានសៀវភៅឱ្យយល់ និងចាំបានល្អ ....................41
៤.៣.៣ ការចំណាយពេលរៀនដោយខ្លួនឯង និងរៀនគួរជាមួយគ្រូ ....................42
៤.៣.៤ ប្រសិទ្ធភាពរៀននៅសាលា និងប្រសិទ្ធភាពរៀនផ្ទាល់ខ្លួន ....................43
៤.៣.៤.១ ប្រសិទ្ធភាពរៀននៅសាលា ....................37
៤.៣.៤.២ ប្រសិទ្ធភាពរៀនផ្ទាល់ខ្លួន ....................45
៤.៤ កត្តាសាលារៀន ....................46
៤.៤.២ វិធីសាស្ត្របង្រៀន ....................48
៤.៤.៣ បរិស្ថានសាលារៀន ....................49
៤.៤.៤ បន្ទប់កុំព្យូទ័រ បណ្ណាល័យ និងបន្ទប់ពិសោធន៍សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ ....................50
៤.៥ កត្តាគ្រួសារ ....................52
៤.៥.១ ទស្សនៈនៃការយល់ឃើញរបស់ឪពុក ម្តាយ រឺអ្នកអាណាព្យាបាលចំពោះការសិក្សា ....................52
៤.៥.២ ជំរុញ និងលើកទឹកចិត្តក្នុងការរៀនសូត្រ ....................53
៤.៥.៣ ឪពុក ម្តាយ រឺ អ្នកអាណាព្យាបាលក្នុងការតាមដានការសិក្សា ....................54
៤.៥.៤ ទំនាក់ទំនងជាមួយនាយក និងគ្រូនៅសាលា ....................55

## ជំពូកទី៥ សេចក្តីសន្និដ្ឋាន សំណូមពរ និងអនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ....................58
៥.១.១ កត្តាសាលារៀន ....................58
៥.១.២ កត្តាគ្រួសារ ....................59
៥.១.៣ កត្តាផ្ទាល់ខ្លួន ....................59
៥.៣ សំណូមពរ ....................60
៥.៣.១ ក្រសួងអប់រំ យុវជន និងកីឡា ....................60

៥.៣.២ សាលារៀន.....60
៥.៣.៣ គ្រួសារសិស្ស.....61
៥.៣.៤ សិស្ស.....61
៥.៤ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត.....61
**ឯកសារយោង**.....
**ឧបសម្ព័ន្ធ**.....

# ចំណងជើងក្រាហ្វិក

ក្រាហ្វិកទី១ មុខរបរឪពុកម្ដាយសិស្សនិទ្ទេសA ..................................................... ៣៣
ក្រាហ្វិកទី២ កត្តាផ្ទាល់ខ្លួន ..................................................... ៣៤
ក្រាហ្វិកទី៣ វិធីសាស្ត្រអានសៀវភៅ..................................................... ៣៥
ក្រាហ្វិកទី៤ ចំនួនម៉ោងរៀនដោយខ្លួនឯង និងរៀនគួរជាមួយគ្រូ ..................................................... ៣៦
ក្រាហ្វិកទី៥ ប្រសិទ្ធភាពរៀននៅសាលា..................................................... ៣៧
ក្រាហ្វិកទី៦ ប្រសិទ្ធភាពរៀផ្ទាល់ខ្លួន ..................................................... ៣៨
ក្រាហ្វិកទី៧ គណៈគ្រប់គ្រងសាលា ..................................................... ៤០
ក្រាហ្វិកទី៨ វិធីសាស្ត្របង្រៀន ..................................................... ៤១
ក្រាហ្វិកទី៩ ស្ថានភាពបរិស្ថានសាលារៀន ..................................................... ៤២
ក្រាហ្វិកទី១០ បន្ទប់កុំព្យូទ័រ បណ្ណាល័យ និងបន្ទប់ពិសោធន៍ ..................................................... ៤៤
ក្រាហ្វិកទី១១ ទស្សនៈចំពោះការសិក្សា ..................................................... ៤៥
ក្រាហ្វិកទី១២ ការជុំរុញ និងលើកទឹកចិត្តក្នុងការសិក្សា..................................................... ៤៦
ក្រាហ្វិកទី១៣ ការតាមដានការសិក្សា ..................................................... ៤៧
ក្រាហ្វិកទី១៤ ទំនាក់ទំនងឪពុកម្ដាយជាមួយសាលារៀន ..................................................... ៤៨

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី ១

# សេចក្តីផ្តើម

## ១.សាវតារ

ការអប់រំ គឺជាបាតុភូតសង្គម ប្រសូត្រចេញពីពលកម្មផលិត ហើយត្រូវបានផ្ទេរចេញពីជំនាន់មួយទៅជំនាន់មួយ តាមរយៈបទពិសោធន៍ ឬលំនាំអប់រំបន្តបន្ទាប់ស្របតាមក្រិត្យក្រម នៃការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច។ រាល់លំនាំអប់រំត្រូវបំពេញភារកិច្ចបីយ៉ាងជាកំណត់គឺៈ ភារកិច្ចសេដ្ឋកិច្ចផលិតកម្ម (រក្សាស្ថិរភាពជីវភាព) ភារកិច្ចនយោបាយសង្គម (រក្សាស្ថិរភាពសង្គម) និងភារកិច្ចសតិអារម្មណ៍វប្បធម៌ ។ការកសាងសង្គមឱ្យរីកចម្រើនបានល្អ លុះត្រាតែប្រជាពលរដ្ឋទាំងអស់ជាអ្នកមានចំណេះដឹង ជំនាញវិជ្ជាជីវៈ ឥរិយាបថល្អ និងមានសមត្ថភាពប្រកបដោយគុណធម៌។ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងខ្លឹមសារអប់រំត្រូវស្របតាមមូលដ្ឋានទីផ្សារសេដ្ឋកិច្ចរបស់ជាតិឬទឹកដី និងសំណូមពររបស់ពលរដ្ឋ ព្រោះតាមធម្មតារចនាសម្ព័ន្ធថ្នាក់ក្រោមត្រូវកំណត់ដោយរចនាសម្ព័ន្ធថ្នាក់លើ ឬប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការ (បណ្ឌិត ចៅ លិន ការអប់រំនៅកម្ពុជា ២០១១)។ សម្រាប់ប្រទេសកម្ពុជាបានឆ្លងកាត់ការអប់រំជាច្រើនមានដូចជា (១) ការអប់រំសម័យបុរាណចាប់តាំងពីការសិក្សាសម័យនគរភ្នំហ្វូណានពីពុទ្ធសតវត្សទី៦ដល់ទី១១ (ព.ស.៥៤៣-១០៩៣) ពីគ្រឹស្តសតវត្សទី១ដល់ទី៦ (គ.ស១-៥៥០) ការសិក្សាសម័យចេនឡាពីពុទ្ធសតវត្សទី១១ ដល់ទី១៤ (ព.ស.១០៩៣ ដល់ ១៣៤៥) ពីគ្រឹស្តសតវត្សទី៦ ដល់ទី៩ (គ.ស.៥៥០ ដល់៨០២) ការសិក្សាសម័យមហានគរពីពុទ្ធសតវត្សទី១៤ ដល់ទី២០ (ព.ស.១៣៤៥ ដល់១៩៧៥) ពីគ្រឹស្តសតវត្សទី៩ ដល់ទី១៥ (ព.ស.៨០២-១៤៣២) ការសិក្សាអប់រំក្រោយមហានគរចាប់ពីសតវត្សទី១៦ ដល់ទី១៨ និងការអប់រំក្នុងសតវត្សទី១៩ (ឯកឧត្តមបណ្ឌិត ស៊ិន សេងហុក ទស្សនៈនៃការអប់រំ ច្បាប់អប់រំ និងគោលនយោបាយអប់រំ២០១៩) (២) ការអប់រំសម័យដើមនៃការទំនុកបម្រុងរបស់បារាំង (១៩៤៥ ដល់១៩៥៣) (៣) ការសិក្សាអប់រំសម័យសង្គមរាស្ត្រនិយម (១៩៥៥ ដល់១៩៦៧) (៤) ការសិក្សាអប់រំនៅសម័យសាធារណៈខ្មែរ (១៩៧០ ដល់១៩៧៥) (៥) ការសិក្សាអប់រំនៅសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់១៩៧៩) (៦) ការអប់រំសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ ដល់ ១៩៨៩) ការអប់រំសម័យរដ្ឋកម្ពុជា (១៩៨៩ ដល់១៩៩៣) និង(៧)

ការអប់រំនៅចុងសតវត្សទី២០ និងដើមសតវត្សទី២១នៅកម្ពុជានាពេលបច្ចុប្បន្ន (បណ្ឌិត ថៅ លិន ២០១១)។

ការអប់រំខាងលើនេះបានបញ្ជាក់ថាគ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថាន សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស និងសាលារៀនចំណេះទូទៅ ត្រូវបានបែងចែកជាសាលាបឋមសិក្សា និងសាលាមធ្យមសិក្សាបឋមភូមិ-ទុតិយភូមិ និងមត្តេយ្យសិក្សា។ ក្នុងភូមិសិក្សានិមួយៗមានទិសដៅ និងភារកិច្ចរបស់ខ្លួនច្បាស់លាស់ក្នុងការអប់រំ សិស្ស និស្សិត ឱ្យក្លាយទៅជាពលរដ្ឋល្អដែលសង្គមជាតិគ្រប់ជំនាន់ រង់ចាំទទួល ក្រោយបញ្ចប់ការសិក្សា។ គួរឱ្យស្តាយការអប់រំនៅឆ្នាំ១៩៧៥-១៩៧៩ ពុំមានកម្មវិធីសិក្សាច្បាស់លាស់ តែក្រោយមកការអប់រំនៅកម្ពុជាមានការរីកចម្រើនជាបន្តបន្ទាប់ឥតឈប់ឈរដល់សព្វថ្ងៃ។ ការអប់រំ ត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើកុមារាកុមារី យុវជនយុវតី ដែលជាអ្នកបន្តវេនពីមនុស្សជំនាន់មុននិងបច្ចុប្បន្ន ពីព្រោះជនប្រភេទចុងក្រោយនេះហើយ ដែលកំពុងតែជាប់ផុងខ្លួនក្នុងបណ្តាលបញ្ហាទាំងអស់នេះ។ ការអប់រំបានបង្ហាញពីសេចក្តីស្រឡាញ់ចំពោះមនុស្សដែលយើងចាំបាច់ត្រូវស្វាគមន៍ពួកគេ មានលទ្ធភាពចូលរួមក្នុងសង្គម ដោយប្រគល់ជូននូវទីកន្លែងដែលពួកគេមានសិទ្ធិអង្គុយនៅក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិ។ គេចាំបាច់ពិចារណាលើភារកិច្ចជាមូលដ្ឋាន ដើម្បីផ្តោតការយកចិត្តទុកដាក់ចំពោះមនុស្ស ដោយភ្ជាប់នូវពាក្យមួយឃ្លាថា ម្តាយរបស់មនុស្ស កុមារជាឪពុកគ្រប់ជំនាន់ (បណ្ឌិតថៅ លិន ការអភិវឌ្ឍធនធានមនុស្សដើម្បីជោគជ័យ ២០១១)។

ការអប់រំមានគុណភាព គឺជាកត្តាដ៏សំខាន់មួយសម្រាប់អភិវឌ្ឍន៍ប្រទេស។ បន្ទាប់ពីទទួលបាន សន្តិភាពក្នុងឆ្នាំ១៩៩៣ ប្រទេសកម្ពុជាមានសុខសន្តិភាព និងសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងរយៈពេល២០ឆ្នាំកន្លងទៅនេះ ជាពិសេសគឺការផ្តោតការយកចិត្តទុកដាក់ និងការតាំងចិត្តក្នុងការអភិវឌ្ឍប្រព័ន្ធអប់រំរបស់ប្រទេស។ ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៩-២០១៣ បានបង្ហាញពីការប្រែប្រួលជាច្រើនហើយនេះក៏ជាសញ្ញាបង្ហាញថាក្រសួងអប់រំ យុវជន និងកីឡាត្រូវធ្វើកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡារបស់ប្រទេសជាបន្តទៀត ស្របជាមួយនឹងកំណែទម្រង់របស់រាជរដ្ឋាភិបាល។ ក្នុងអំឡុងពេលអភិវឌ្ឍផែន ការយុទ្ធសាស្ត្រវិស័យអប់រំរយៈពេល ៥ ឆ្នាំកន្លងមកនេះ ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍របស់ខ្លួនបានធ្វើការកែលម្អដ៏សំខាន់ ក្នុងការផ្តល់ឱកាសចូលរៀនប្រកបដោយសមធម៌ ការកែលម្អគុណភាព និងប្រសិទ្ធភាពអប់រំ និងការគ្រប់គ្រងអប់រំ។ ប្រទេសកម្ពុជាមានសាលារៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិប្រហែល ៨៣០០

សាលារៀនមធ្យមសិក្សាទុតិយភូមិជិត៩៥៥ ក្នុងនោះប្រមាណ៩ភាគរយជាសាលារៀនឯកជន រីឯសាលាមត្តេយ្យសិក្សាវិញមានចំនួនប្រហែល៣០០០កន្លែង។ សិស្សគ្រប់កម្រិតសិក្សាទាំងអស់មានចំនួនប្រហែល៣.១លាននាក់ កំពុងសិក្សាក្នុងសាលារៀន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការបំណិនវិជ្ជាជីវៈ ២០១៦)។

ទោះបីជាប្រទេសកម្ពុជាធ្លាប់មានការអប់រំធ្លាក់ចុះ យ៉ាងណាក៏ដោយ មកទល់ពេលនេះរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់វិស័យអប់រំជាវិស័យអាទិភាពដោយឈរលើស្មារតី កំណែទម្រង់វិស័យអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានខិតខំប្រឹងប្រែងក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅប្រកបដោយគុណភាព និងប្រសិទ្ធភាពក្នុងការអប់រំមនុស្សគ្រប់គ្នា។ ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សម្រាប់បម្រើប្រទេសជាតិមិនអាចកាត់ផ្តាច់ចេញពីការអប់រំបានឡើយ។ វិស័យអប់រំរីកចម្រើន និងមានប្រសិទ្ធភាព ទាមទារចាំបាច់នូវកម្រិតសមត្ថភាពគ្រូបង្រៀនដែលក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងយកចិត្តទុកដាក់ថែរបំប៉នជាប្រចាំ។ មិនតែប៉ុណ្ណោះ វិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹងនិងសមត្ថភាពខ្ពស់ប្រកបដោយសម្បទាគ្រប់គ្រាន់ មានជំនាញមានភាពច្នៃប្រឌិតនិងនវានុវត្តន៍ មានស្មារតីសហគ្រិនភាពនិងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព។ ក្នុងន័យនេះ ការអប់រំសម្រាប់ឆ្នាំ២០៣០ ផ្តោតជាសំខាន់លើការផ្តល់សេវាអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្នសម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សារួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសការសិក្សាពេញមួយជីវិតដើម្បីបង្កើនប្រសិទ្ធភាព គុណភាពផលិតផល និងការងារស្របតាមយុគ្គសម័យបច្ចេកវិទ្យាក្នុងការបង្កើនសេដ្ឋកិច្ច សុខដុមជីវិតបុគ្គល និងសង្គម។ ការអប់រំអាចមានគុណភាពទៅបានលុះត្រាគ្រូបង្រៀន និងនាយកសាលារៀនមានគុណភាព។ ក្នុងន័យនេះយុទ្ធសាស្រ្តកំណែទម្រងវិស័យអប់រំ ២០១៨-២០២៣ ផ្តោតទៅលើការពង្រឹងការគ្រប់គ្រងសាលារៀន ការពង្រឹងគុណភាពគ្រូ និងការកែលម្អការបង្រៀន និងការរៀនដោយផ្តល់ឱ្យសាលារៀននូវស្វ័យភាពហិរញ្ញវត្ថុ និងការទទួលខុសត្រូវចំពោះលទ្ធផលសិក្សារបស់សិស្ស (ហួ ឈុនគ្រីប៉ូ ប៊ុន្លួន ម៉ែន សុខសុន្ទី ក្រមសីលធម៌វិជ្ជាជីវៈនាយក សាលារៀន មិថុនា ២០១៩) ។

ក្រសួងអប់រំបានធ្វើការកែទម្រង់គ្រប់គ្រងការអប់រំដូចជា៖ (១) កំណែទម្រង់ការគ្រប់គ្រងការ សិក្សាផ្តោតសំខាន់លើការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប្រចាំ កែលម្អ

វិធីសាស្ត្រ បង្រៀន ការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សា និង សៀវភៅសិក្សាគោល (២) កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល សំដៅដល់ការធានាការចូលរួម របស់មាតាបិតាសិស្ស និងសហគមន៍មូលដ្ឋាន ការអនុវត្តការគ្រប់គ្រងតាមសាលារៀន ការ អនុវត្តគោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (៣) កំណែទម្រង់ការ គ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីបង្កើនស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន ធ្វើ សវនកម្មថវិកាអប់រំជាទៀងទាត់ បង្កើនការបែងចែកថវិកាផ្សារភ្ជាប់ នឹងគោនយោបាយអប់រំ (៤) កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សសម្រាប់ការបណ្តុះបណ្តាលដោយផ្តោតលើវិធី សាស្ត្របង្រៀន និងកម្មវិធីបំប៉ននៅនឹងកន្លែង បង្កើនការបណ្តុះបណ្តាលគ្រូបង្រៀន អនុវត្តការ វាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ។ ដើម្បីធ្វើកំណែទម្រង់ការគ្រប់គ្រងអប់រំនេះ បានល្អ ត្រូវមានការ ចូលរួមពីភាគីពាក់ព័ន្ធដែលមានសាមីក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ សាលារៀន សហគមន៍ និងបណ្តាអង្គការក្រៅរាជរដ្ឋាភិបាលចូលរួម ដើម្បីធ្វើឱ្យការអប់រំនៅ កម្ពុជាមានការរីកចម្រើនដែលអាចឱ្យសិស្សទទួលបានការអប់រំមួយប្រកបដោយ វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងយកចំណេះជំនាញទៅធ្វើការនៅក្នុងសង្គមប្រកបដោយ គុណភាព និងប្រសិទ្ធភាពស្របតាមការងារដែលសង្គមចង់បាននៅពេលអនាគត (ផែនការ យុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣)។

នៅឆ្នាំ២០១៤ការធ្វើកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដើម្បីឱ្យ ការប្រឡងទទួលបានប្រសិទ្ធភាព ហើយអាចយកបាននូវលទ្ធផលក្នុងការប្រឡង ក្រសួងអប់រំ យុវជន និងកីឡាបានធានាគោលការណ៍៤យ៉ាងនៃការប្រឡងពោលគឺ ១) គោលការណ៍ច្បាប់ ២) យុត្តិធម៌ ៣) តម្លាភាព និង ៤) លទ្ធផលអាចទទួលយកបាន។ ក្រសួងអប់រំ យុវជន និង កីឡាបានបង្កើតគណៈកម្មការកំណែទម្រង់ការប្រឡងដែលមាន អនុគណៈកម្មការ បច្ចេសទេស អនុគណៈកម្មការពិនិត្យឡើងវិញប្រកាសអន្តរក្រសួង ស្តីពីគោលការណ៍ ចំណាយសម្រាប់ការប្រឡង អនុគណៈកម្មការនីតិកម្ម (ពិនិត្យបទប្បញ្ញត្តិ និងកម្រិតវិន័យ ប្រឡង) អនុ គណៈកម្មការហិរញ្ញវត្ថុ និងអនុគណៈកម្មការសន្តិសុខ (ក្រសួងអប់រំ យុវជន និង កីឡា កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ២០១៤) ដែលជាកត្តា ជោគជ័យរបស់សិស្សា នុសិស្សទូទាំងប្រទេសកម្ពុជាក្រោយពីបានធ្វើការកែទម្រង់វិស័យ អប់រំ។

កត្តាជោគជ័យរបស់សិស្សដែលទទួលបាននិទ្ទេសA ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានការកើនឡើងជាបន្តបន្ទាប់រហូតដល់ ៩៨៣នាក់នៅឆ្នាំ២០១៩ (នាយកដ្ឋានមធ្យមសិក្សា ២០១៩)។ តាមរយៈការធ្វើបទបង្ហាញរបស់សិស្សឆ្នើមដែលជាប់ចំណាត់ថ្នាក់លេខ១ពីថ្នាក់ទី១ដល់ថ្នាក់ទី១២ ហើយបានប្រឡងជាប់និទ្ទេសA នៅឆ្នាំ ២០១៦ បច្ចុប្បន្នកំពុងបន្តការសិក្សានៅប្រទេសជប៉ុនគឺ កញ្ញា រស់ ចាន់ត្រា បានប្រាប់ពីការជោគជ័យរបស់នាងថា៖ ការជោគជ័យរបស់នាងគឺដោយសារតែនាងបានខិតខំរៀនសូត្រដោយខ្លួនឯង តាមរយៈការរៀនរំលឹកមេរៀនក្រោយពីចប់ភ្លាមៗ ការអានឡើងវិញ មើលមេរៀនប្រចាំថ្ងៃ ធ្វើលំហាត់ និងរៀនជាមួយមិត្តភក្តិ។ ក្រៅពីរៀនខ្លួនឯងគឺមានសាលារៀនដែលជាកត្តាមួយផ្នែកជួយកញ្ញាក្នុងការប្រឡងបានជោគជ័យ ហើយអ្វីដែលពិសេសសម្រាប់កញ្ញានោះគឺមានកត្តាគ្រួសារដែលបានជំរុញការលើកទឹកចិត្ត និងបានផ្តល់សម្ភារៈក្នុងការសិក្សារៀនសូត្រ រហូតទទួលបាននិទ្ទេសA ក្នុងការប្រឡង (khmerbuzz24.com June 25,2019)។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្រោយពីអង្កេតឃើញពីកត្តាជោគជ័យរបស់សិស្សទទួលបាននិទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នាពេលបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅឆ្នាំ២០១៣-២០១៤ តាមរយៈការដាក់ចេញនូវយុទ្ធសាស្រ្តកំណែទម្រង់នានារបស់ក្រសួងជាហូរហែរ រហូតទទួលបានការកោតសរសើរពីគ្រប់មជ្ឈដ្ឋាន ជាពិសេសរាជរដ្ឋាភិបាល អ្នកអាណាព្យាបាលសិស្ស មាតាបិតា សហគមន៍ និងសង្គមស៊ីវិលព្រមទាំងបណ្តាប្រទេសនានាក្នុងពិភពលោកទៀតផង។

ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបានបញ្ជាក់ពីសមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា លោកគ្រូអ្នកគ្រូ គណៈគ្រប់គ្រងសាលារៀន មាតាបិតាសិស្ស និងសិស្សផ្ទាល់ដែលធ្វើឱ្យពួកគេប្រឡងបាននិទ្ទេស A B C D E ។ ភាពជោគជ័យនេះ គឺកើតចេញពីការធ្វើកំណែទម្រង់របស់ក្រសួង និងការខិតខំរបស់គណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូ គ្រួសារ មិត្តភក្តិ និងសិស្សានុសិស្សផ្ទាល់។

ម្យ៉ាងវិញទៀត ទោះជាក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការកែទម្រង់ការប្រឡងក្តី តាមរយៈការអង្កេតជាក់ស្តែងយើងបានឃើញថា៖ សមត្ថភាពរបស់សិស្សនៅមានកម្រិតនៅឡើយក្នុងការប្រឡងយកនិទ្ទេស A ជាពិសេសលើបញ្ហាការរៀន និងការបង្រៀនដែលមានលក្ខណៈនៅមិនទាន់ល្អ។ ដោយពិនិត្យឃើញថាពុំមាននរណាបានធ្វើការសិក្សាលើបញ្ហានេះ

អ្នកសិក្សាស្រាវជ្រាវមានបំណងចង់ធ្វើការសិក្សាពីកត្តាជោគជ័យ របស់សិស្សទទួលបាននិទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ដើម្បីឱ្យដឹងពីកត្តាជោគជ័យរបស់សិស្សដែលទទួលបាននិទ្ទេស Aទាំងនោះ។

## ១.៣ គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដូចតទៅ៖

១.រកឱ្យឃើញនូវកត្តាជោគជ័យរបស់សិស្សដែលទទួលបាននិទ្ទេស A ។

២.រកឱ្យឃើញពីឧបសគ្គចម្បងៗដែលសិស្សនិទ្ទេស A ជួបប្រទះនិងវិធីដែលគេដោះស្រាយក្នុងជីវិតសិក្សារបស់ពួកគេ។

## ១.៤ សំណួរនៃការស្រាវជ្រាវ

ឆ្លើយតបទៅនឹងគោលបំណងខាងលើ ការសិក្សាស្រាវជ្រាវនេះចាំបាច់ត្រូវរកឱ្យឃើញនូវចម្លើយនៃសំណួរដូចខាងក្រោម៖

១.តើមានកត្តាសំខាន់ៗផ្ទាល់ខ្លួនអ្វីខ្លះដែលនាំឱ្យសិស្សទទួលបាននិទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ?

២.តើឧបសគ្គចម្បងៗអ្វីខ្លះដែលសិស្សនិទ្ទេស A ជួបប្រទះហើយតើគេត្រូវជំនះឧបសគ្គទាំងនោះយ៉ាងដូចម្តេចដើម្បីទទួលបានជោគជ័យក្នុងការសិក្សា?

## ១.៥ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានដែនកំណត់ និងវិសាលភាពផ្តោតតែទៅលើលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិរបស់សិស្សនិទ្ទេស A តែប៉ុណ្ណោះ ដោយសំលឹងទៅលើតែកត្តានៃភាពជោគជ័យ៣ ពោលគឺ៖

១.កត្តាសិស្សខ្លួនឯង៖ របៀបនៃការរៀនរបស់សិស្ស (ការធ្វើលំហាត់ ការអានសៀវភៅ ការទន្ទេញមេរៀន ការអនុវត្តជាក់ស្តែងនៃមេរៀនដែលបានរៀន)។

២.កត្តាសាលារៀន៖ ការធ្វើកំណែទម្រង់នៃការប្រឡង ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ បន្ទប់សិក្សាស្រាវជ្រាវ ក្លឹបសិក្សា បរិស្ថានសាលារៀន និងការគ្រប់គ្រង។

៣. កត្តាគ្រួសារ៖ ការផ្តល់កម្លាំងចិត្ត ការផ្តល់អាហារ ការស្នាក់នៅ ការផ្តល់ប្រាក់ និងធនធានសម្ភារៈ។

## ១.៦ សារៈប្រយោជន៍នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ លើប្រធានបទស្តីពីកត្តាជោគជ័យរបស់សិស្សទទួលបាននិទ្ទេសAក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាមានសារៈប្រយោជន៍ដូចខាងក្រោមៈ

- ផ្តល់បទពិសោធន៍រៀនសូត្រដល់សិស្សានុសិស្សឱ្យយកទៅអនុវត្តដើម្បីទទួលបានជោគជ័យក្នុងការសិក្សា។
- លើកកម្ពស់គុណភាពនៃធនធានមនុស្សដើម្បី ចូលរួមចំណែកក្នុងការអភិវឌ្ឍសុខមាលភាពសង្គម។

## ១.៧ រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះចែកចេញជា ៥ជំពូកដែលរួមមានៈ

- ជំពូកទី១ៈ បង្ហាញពីសេចក្តីផ្តើម ពណ៌នាដោយសង្ខេបទៅលើលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវសារៈសំខាន់នៃការស្រាវជ្រាវនិងរចនាសម្ព័ន្ធនៃការស្រាវជ្រវ។
- ជំពូកទី២ៈ រំលឹកទ្រឹស្តី ធ្វើការបកស្រាយ និងពន្យល់យ៉ាងលម្អិតទៅលើវិធីសាស្ត្រផ្សេងៗ និងកត្តាជោគជ័យរបស់សិស្សដែលអ្នកស្រាវជ្រាវមុនៗបានរកឃើញ។
- ជំពូកទី៣ៈ វិធីសាស្ត្រនៃការស្រាវជ្រាវដែលជំពូកនេះនឹងលើកឡើងពីវិធីសាស្ត្រនៃការស្រាវជ្រាវ និងគម្រោងនៃការវិភាគដោយកំណត់ទៅលើគំរូសំណាកកម្រងសំណួរស្រាវជ្រាវ ឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ ការវិភាគទិន្នន័យ ដែនកំណត់ និងវិសាលភាព។
- ជំពូកទី៤ៈ លទ្ធផលនៃការស្រាវជ្រាវ ជំពូកនេះនឹងធ្វើការពិភាក្សាយ៉ាងលម្អិតទៅលើកម្រងសំណួរសម្រាប់យកមកវិភាគទិន្នន័យ ការបកស្រាយទិន្នន័យដែលប្រមូលបានជាក់ស្តែងឆ្លើយតបទៅ នឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ។
- ជំពូកទី៥ៈ សន្និដ្ឋានសរុប ការពិភាក្សា និងសំណូមពរដែលជំពូកនេះបានសង្ខេបគ្រប់លទ្ធផលទាំងអស់ ដែលបានរកឃើញនិងពិភាក្សាផ្តល់ជាយោបល់ឬជាសំណូមពរសម្រាប់ធ្វើការកែលម្អ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី ២

# រំលឹកទ្រឹស្តី

## ២.១ និយមន័យ

ភាពជោគជ័យគឺ ជាពាក្យមួយដែលមនុស្សគ្រប់រូបតែងតែប្រាថ្នាចង់បាន។ ពាក្យនេះត្រូវបានគេលើកឡើងក្នុងការសន្ទនាមនុស្សភាគច្រើន ជាពិសេសយុវជនតែងតែគិតឃើញមុនគេដល់គំនិតទ្រព្យសម្បត្តិស្តុកស្តម្ភ គេហដ្ឋានធំស្កឹមស្កៃ យានដ្ឋជំនិះទំនើបៗ ភាពឡូយឆាយ និងភាពស៊ីវិល័យជាដើម។ល។ (www.hruyfc.com)។ វិគីភីដា បានឱ្យនិយមន័យ ភាពជោគជ័យ គឺជាការទទួលបានតំណែង និងការឡើងប្រាក់ខែ ដូចជាការធ្វើផែនការនៃការធ្វើដំណើរអញ្ចឹង។ អ្នកត្រូវតែកំណត់ពីចំណុចចាប់ផ្តើម ទិសដៅ និងមធ្យោបាយធ្វើដំណើរ ប្រេងឥន្ធនៈ ឥវ៉ាន់ ផ្លូវធ្វើដំណើរជាដើម។ ចំណែកលោក Tilman Fertitta មហាសេដ្ឋីនៅសហរដ្ឋអាមេរិក បានឱ្យនិយមន័យភាពជោគជ័យ គឺថានរណាម្នាក់ធ្វើអ្វីមួយប្រសើរជាងនរណាម្នាក់ទៀត (www.bizkhmer.com)។ (Cambodia Free writer,11 November 2013) ភាពជោគជ័យសម្រាប់មនុស្សភាគច្រើន គឺការងារល្អ រកប្រាក់បានច្រើន មុខមាត់ខ្ពស់ និងមានគ្រួសារល្អ។ល។ ប៉ុន្តែសម្រាប់លោក Horn,1991 ភាពជោគជ័យ គឺមិនមែនអ្វីដែលខ្ញុំរកបាន នៅក្នុងពេលនេះទេ ប៉ុន្តែគឺអ្វីដែលខ្ញុំអាចបន្សល់ទុក បន្ទាប់ពីពេលដែលខ្ញុំស្លាប់ទៅ។ ខ្ញុំចង់ឈរតំណាងឱ្យអ្វីដែលអាចធ្វើឱ្យមានភាពប្លែក និងមានប្រយោជន៍សម្រាប់សង្គមជាតិ ទោះស្ថិតនៅក្នុងទ្រង់ទ្រាយតូច ឬធំក្តី ។ លោកស្រី សុទ្ធី ហៃដត៏ ភរិយារបស់ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា លោក William Heidt បានកំណត់ពីភាពជោគជ័យថា ជាសេចក្តីរីករាយ និងសន្តិភាពនៅក្នុងចិត្ត ហើយមិនមែនជាការរត់តាមទឹកប្រាក់នោះទេ។ នៅពេលដែលខ្ញុំជួបនិយាយជាមួយសិស្ស ខ្ញុំតែងតែប្រាប់ពួកគេឱ្យមានសេចក្តីប្រាថ្នាធំ និងខិតខំប្រឹងប្រែងធ្វើឱ្យបានល្អក្នុងវិស័យដែលពួកគេចាប់យក។ ចំពោះលោកបណ្ឌិត ដេត សុខឧត្តម ជាសាកលវិទ្យាធិការ និងជាសាស្ត្រាចារ្យផ្នែកទំនាក់ទំនងអន្តរជាតិនៅសាកលវិទ្យាល័យហ្សាម៉ាន លោកបានឱ្យនិយមន័យ ភាពជោគជ័យ គឺជាការសម្រេចបាននូវអ្វីដែលយើងសុបិន្ត។ ប្រសិនជាខ្ញុំមានសុបិន្តថាចង់ក្លាយជាសាកលវិទ្យាធិការ ហើយខ្ញុំបានក្លាយជាសាកលវិទ្យាធិការ នោះហើយគឺជាភាពជោគជ័យរបស់ខ្ញុំ។ ក៏ប៉ុន្តែ ក្នុងន័យទូលាយ ភាពជោគជ័យ មិនមែនត្រឹមតែជាការសម្រេចសុបិន្តប៉ុណ្ណោះនោះទេ តែវាគឺជាការសម្រេចបានប្រកបដោយសេចក្តីថ្លៃថ្នូរ តម្លៃ និងការខិតខំប្រឹងប្រែង ហើយវាក៏អាស្រ័យទៅលើការគោរពរបស់មិត្តរួមការងារ និងការបង្កើតការ

ជំរុញទឹកចិត្តសម្រាប់មនុស្សជំនាន់ក្រោយ (ភ្នំពេញប៉ុស្តិ៍ ២១, November 2017)។ សម្រាប់លោកហួ សេរីវឌ្ឍន៍ ជាប្រធានប្រតិបត្តិនៅក្នុងក្រុមហ៊ុន i-Qlick Cambodia ភាពជោគជ័យកើតមានឡើងនៅពេលដែលខ្ញុំរៀនចេះ អ្វីដែលខ្ញុំចង់រៀន ដែលអាចយកចំណេះនោះមកប្រើប្រាស់បាន(ភ្នំពេញប៉ុស្តិ៍ ២១, November 2017)។ ចំពោះលោក ហ៊ុន ចាន់សាន ជានាយកស្ថាបត្យកររបស់ក្រុមហ៊ុន Re-Edge Architecture & Design បានឱ្យនិយមន័យភាពជោគជ័យគឺជាការដែលអាចបណ្តុះបណ្តាលអ្នកជំនាន់ក្រោយឱ្យសម្រេចបានដូចគ្នានូវអ្វី ដែលយើងសម្រេចបាន (ភ្នំពេញប៉ុស្តិ៍២១,November 2017)។ សរុបសេចក្តីមកតាមនិយមន័យខាងលើបានបង្ហាញថាភាពជោគជ័យគឺអាស្រ័យទៅលើមនុស្សម្នាក់ៗមានភាពអត់ធ្មត់ មានឆន្ទៈក្នុងការសិក្សារៀនសូត្រ និងធ្វើការងារដើម្បីសម្រេចនូវគោលបំណងរបស់ខ្លួន។

## ២.២ គន្លឹះក្នុងការរៀនឱ្យបានជោគជ័យ

ដើម្បីទទួលបានភាពជោគជ័យមួយប្រសើរក្នុងការរៀនសូត្រ សិស្សានុសិស្សមួយចំនួនបានខិតខំប្រឹងប្រែងតាមវិធីសាស្ត្ររៀងៗខ្លួនដែលអាចធ្វើទៅបានក្នុងពេលបច្ចុប្បន្ន និងពេលអនាគតសម្រាប់ជីវិតឱ្យមានការរីកចម្រើនផ្នែកចំណេះដឹង ដើម្បីយកទៅប្រើប្រាស់ក្នុងការបំពេញការងារ និងកសាងអនាគតរបស់ខ្លួន។ តាម **Mr. Melon, 19 April 2016** បាននិយាយថាដើម្បីជោគជ័យក្នុងការសិក្សាត្រូវមានកត្តាមួយចំនួនដូចជា (១) ***កំណត់គោលដៅ*** ដាក់ទិសដៅរបស់អ្នកបង្កើនការយកចិត្តទុកដាក់ និងផ្តោតទៅគោលដៅរបស់អ្នក។ជំរុញទឹកចិត្តខិតខំប្រឹងប្រែងកាត់បន្ថយគំនិតអវិជ្ជមាន និងជំនួសមកវិញដោយជំនឿចិត្ត (២)***មានឥរិយាបទវិជ្ជមាន*** គិតវិជ្ជមានអំពីសមត្ថភាពរបស់អ្នកក្នុងការសម្រេចគោលដៅ តាំងចិត្តក្នុងការសិក្សាអំពីអ្វីដែលអ្នកនឹងប្រឈមមុខ ត្រូវមានចំណាប់អារម្មណ៍ទៅលើមុខវិជ្ជាដែលអ្នករៀន (ចេះឆ្លល់ ចេះសួរ ចេះដោះស្រាយ) (៣) ***គ្រប់គ្រងពេលវេលា*** បង្កើតតារាងកាលវិភាគមួយសម្រាប់ខ្លួនអ្នក ត្រូវយល់ដឹងថាអ្នកត្រូវចំណាយពេលទៅលើអ្វីខ្លះ? ត្រូវរៀនបន្ថែមដោយខ្លួនឯង ឬស្វ័យសិក្សា (ក្រៅពីម៉ោងសិក្សាក្នុងសាលា) (៤) ***អានសៀវភៅ*** មើលការសង្ខេបមេរៀនមុននឹងអាន ត្រូវយកចិត្តទុកដាក់ក្នុងការអាន និងគូសចំណាំចំណុចសំខាន់ៗ រំលឹកមេរៀន និងអានមេរៀនមុនចាប់ផ្តើមរៀននៅក្នុងថ្នាក់។ អានមេរៀនម្តងទៀតបន្ទាប់ពីរៀននៅសាលា និងត្រូវមានសៀវភៅសរសេរចំណុចសំខាន់ (៥) ***យកចិត្តទុកដាក់ចំពោះគ្រូ*** មានចិត្តចង់រៀនជាមួយគ្រូគ្រប់មុខវិជ្ជា អានមេរៀនមុននឹងដល់ម៉ោងចូលរៀន កត់ត្រាទុកចំណុចសំខាន់ៗឧស្សាហ៍សួរគ្រូ ដើម្បីជួយបង្កើនសមត្ថភាពក្នុងការសិក្សា អង្គុយនៅជួរខាងមុខដើម្បីងាយស្រួលយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ជាជាងអង្គុយនៅក្រោយ(៦) ***រក្សាទុកនូវរាល់ឯកសាររបស់គ្រូ*** កត់

មេរៀននៅក្នុងថ្នាក់ រំលឹកព្រមទាំងកែអ្វីដែលបានកត់ត្រាបន្ទាប់ពីរៀននៅសាលា (ក្នុងរយៈពេល២៤ម៉ោង)។មុនពេលប្រឡងព្យាយាមរំលឹកមេរៀនតាមសៀវភៅពុម្ព និងអ្វីដែលបានកត់ក្នុងថ្នាក់ ហាយឡាយ (Highlight) ចំណុចសំខាន់ៗ គូសជាក្រាប និងបង្កើតនិយមន័យទៅតាមគំនិតរបស់អ្នក **(៧)** ***រៀបចំឲ្យបានល្អសម្រាប់ប្រឡង*** រំលឹកអ្វីដែលធ្លាប់បានប្រឡងប្រចាំខែ (ទាក់ទងអ្វីដែលនឹងត្រូវប្រឡងនាពេលខាងមុខ) រៀនអនុវត្ត ឬហ្វឹកហាត់ឆ្លើយសំណួរ។ ទន្ទេញឱ្យចាំមាត់នូវនិយមន័យ រូបមន្ត យល់ដឹងអំពីទម្រង់នៃការប្រឡង។ទទួលទាន និងសម្រាកឱ្យបានគ្រប់គ្រាន់**(៨) ពេលប្រឡង** ត្រូវមានគំនិតវិជ្ជមាន និងខិតខំឱ្យអស់ពីសមត្ថភាពមកដល់បន្ទប់ប្រឡងឱ្យបានមុនពេល និងភ្ជាប់មកជាមួយនឹងប៊ិច និងរបស់របរផ្សេងៗទៀតដែលត្រូវការក្នុងពេលប្រឡង សម្រួលអារម្មណ៍ទាំងមុន និងពេលកំពុងប្រឡង អានការណែនាំ និងសំណួរឱ្យបានច្បាស់មុននឹងសរសេរចម្លើយចូល គ្រប់គ្រងពេលវេលាឱ្យបានល្អបើសល់ពេលសម្រាប់ផ្ទៀងផ្ទាត់ឡើងវិញកាន់តែល្អ(www.ahladang.com ,2016) ៕

យើងគ្រប់គ្នាដឹងហើយថា ការសិក្សាពិតជាមានសារៈសំខាន់ណាស់ សម្រាប់មនុស្សម្នាក់ៗ ហើយគ្រប់សិស្សានុសិស្ស ទាំងអស់ក៏មានបំណង ចង់ឱ្យខ្លួនរៀនពូកែផងដែរ។ ប៉ុន្តែមិនមែនមនុស្សទាំងអស់គ្នាសុទ្ធតែដឹងពីវិធីសាស្ត្រដើម្បីឱ្យខ្លួនរៀននិងប្រឡងទទួលបានជោគជ័យនោះទេ។ ខាងក្រោមនេះ គឺជាបទពិសោធន៍៩ចំណុចដែលសិស្សជោគជ័យក្នុងការសិក្សាតែងតែធ្វើ (www.hruyfc.com) (១)ត្រូវស្គាល់សាស្ត្រាចារ្យ ព្រោះថាសាស្ត្រាចារ្យអាចនឹងជួយអ្នកច្រើនប្រសិនបើគាត់ស្គាល់ថាអ្នកជានរណា។ មិនតែប៉ុណ្ណោះបើអ្នកដឹងពីបុគ្គលិកលក្ខណៈរបស់ពួកគាត់នោះអ្នកទំនងជាស្មានដឹងថាតេស្តនិងសំណួររបស់គាត់ចេញអ្វីទៀតផង (២) ត្រូវមានវត្តមានក្នុងថ្នាក់ជានិច្ច។បើអ្នកមានវត្តមានក្នុងថ្នាក់អ្នកនឹងអាចចាប់បាន ឬដឹងព័ត៌មានផ្សេងៗ ដូចជាការប្រឡង និងការធ្វើសំណួរខ្លីៗ។ ម្យ៉ាងវិញទៀត ការមករៀនទៀងទាត់អាចជួយឱ្យអ្នកតាមទាន់ និងយល់ពីមេរៀនដែលគ្រូបានពន្យល់ ទោះមិនបានទាំងអស់ ក៏យល់មួយភាគធំដែរ(៣)ការធ្វើកិច្ចការផ្ទះអាចជួយអ្នកដឹងពីអ្វីដែលអ្នកមិនដឹង ក្រោយពីអ្នកបានយកចម្ងល់ដែលអ្នកបានយកទៅសួរគ្រូរបស់អ្នក ដើម្បីដឹងពីចម្លើយ។ ផ្ទុយមកវិញ បើអ្នកមិនបានធ្វើកិច្ចការផ្ទះនោះអ្នកនឹងមិនមានអ្វីសួរគ្រូនោះទេ។ មានមនុស្សមួយចំនួនបានបរាជ័យនៅក្នុងថ្នាក់ដោយសារមិនបានធ្វើកិច្ចការផ្ទះ (៤) ការរៀនត្រៀមទុកជាមុន ប្រសិនបើអ្នកបានរៀនត្រៀមទុកជាមុនបានច្រើនថ្ងៃ នោះអ្នកនឹងមានពេលច្រើនសម្រាប់ត្រៀមទៅលើសំណួរឬចម្ងល់របស់អ្នក និងមានពេលយកទៅសួរគ្រូបានមុនពេលប្រឡង។ ប៉ុន្តែបើអ្នក ពន្យារពេលចាំរៀនរហូតដល់ដំណាក់កាលចុងក្រោយ នោះអ្នកនឹងមិនអាចរៀនបានគ្រប់មេរៀនទាំងអស់

នោះទេ ហើយអ្នកនឹងមិនអាចធ្វើកិច្ចការប្រឡងបាននោះដែរ(៥) ស្តាប់គ្រូពន្យល់និងកត់ត្រាទុកៈ សាស្ត្រាចារ្យពុំអាចមានពេលវេលាសរសេរនូវអ្វីដែលគាត់បាននិយាយនៅលើក្តារខៀនគ្រប់ទាំងអស់នោះទេ គឺមានន័យថាអ្នកត្រូវកត់ត្រាសង្ខេបដោយខ្លួនឯង(៦) អ្នកត្រូវមានតារាងពេលវេលាសិក្សាច្បាស់លាស់ប្រសិនបើអ្នកមិនបានដឹងពីពេលវេលានៃការសិក្សាច្បាស់លាស់ទេនោះ អ្នកនឹងខកខានក្នុងការរៀនសូត្រ និងមិនបានធ្វើកិច្ចការដែលត្រូវធ្វើទាន់ពេលវេលាឡើយ(៧)ការទៅអានសៀវភៅនៅក្នុងបណ្ណាល័យនេះ គឺជាការស្រាវជ្រាវមួយដែលសិស្សគ្រប់រូបគួរតែចំណាយពេលវេលាខ្លះ ដើម្បីសិក្សាស្រាវជ្រាវពីចំណេះដឹងទូទៅផ្សេងៗ ហើយការស្រាវជ្រាវនេះទំនងជាសិស្សអាចទទួលបានចំណេះដឹងក្រៅមេរៀនដែលជាការយល់ដឹងពីសង្គម(៨)ការរៀនជាក្រុមនេះគឺជាគន្លឹះមួយដ៏សំខាន់សម្រាប់ការសិក្សា ដើម្បីផ្លាស់ប្តូរចំណេះដឹងគ្នាជាមួយមិត្តភក្តិរបស់អ្នកនៅពេលទំនេរពីម៉ោងសិក្សា ក្នុងការធ្វើលំហាត់ដែលគ្រូបានដាក់ឱ្យ។ វិធីសាស្ត្រនេះនឹងកាន់តែល្អប្រសើរប្រសិនបើអ្នកចាប់ដៃគូរបានត្រឹមត្រូវ (៩)ការអានសំណួរពេលប្រឡងដោយការប្រុងប្រយ័ត្នៈពេលខ្លះសំណួរពេលប្រឡងអាច នឹងមានបំណងចង់បន្លំអ្នកសំណួរខ្លះចង់ដឹងពីនេះប៉ុន្តែបែរជាចង់ដឹងពីនោះទៅវិញ។ ហេតុនេះ បើអ្នកបានអានសំណួរច្បាស់លាស់នឹងមិនអាចច្រឡំបានឡើយ។ ការអនុវត្តយុទ្ធសាស្ត្រទាំង៩ជំហានខាងលើនេះអ្នកនឹងទទួលបានជោគជ័យក្នុងការសិក្សា ដូចទៅនឹងអ្វីដែលអ្នកបានរំពឹងទុកជាមិនខាន៕

ចំពោះភាពជោគជ័យក្នុងការសិក្សាមួយផ្នែកទៀតគឺៈ(thmeythmey.com08.Oct .2018)

**១) គោរពវិន័យឲ្យបានត្រឹមត្រូវៈ** ត្រូវមានវិន័យនៅក្នុងខ្លួន និងត្រូវគោរពវិន័យសាលាឲ្យបានត្រឹមត្រូវ គឺមករៀនឲ្យបានទៀងទាត់ អនុវត្តតាមបទបញ្ជារបស់សាលា និងអនុវត្តរាល់កិច្ចការដែលគ្រូដាក់ឲ្យធ្វើ។ ជាពិសេស ត្រូវគោរពនិងឲ្យតម្លៃលោកគ្រូ អ្នកគ្រូរបស់អ្នក។

**២) រៀបកាលវិភាគរៀនឲ្យបានច្បាស់ៈ** អ្នកត្រូវរៀបចំកាលវិភាគសម្រាប់រៀននៅសាលា និងរៀននៅផ្ទះឲ្យបានត្រឹមត្រូវ ហើយអនុវត្តតាមកាលវិភាគដែលអ្នកបានកំណត់នោះឲ្យបានជាប់លាប់ដោយចៀសវាងនូវហេតុផលឬយកលេសថា រវល់ធ្វើនេះ រវល់ធ្វើនោះទេ។

**៣) ស្រាវជ្រាវមេរៀនបន្ថែមៈ** ពឹងផ្អែកលើឯកសារ ឬខ្លឹមសារមេរៀនគ្រូតែមួយមុខមិនគ្រប់គ្រាន់ឡើយ គឺត្រូវធ្វើការស្រាវជ្រាវតាមបណ្ណាល័យ តាមអ៊ីនធើណេត និងអានសៀវភៅទាក់ទិននឹងមេរៀនដែលអ្នកកំពុងសិក្សាឱ្យបានច្រើនកាន់តែល្អ។

**៤) បង្កើតក្លឹបស្វ័យសិក្សាៈ** អ្នកត្រូវបង្កើតក្លឹបស្វ័យសិក្សាជាមួយមិត្តភក្តិឱ្យបានច្រើន គឺក្នុងចំណោមមិត្តភក្តិរបស់អ្នកមិនប្រាកដថា ពួកគេរៀនពូកែគ្រប់មុខវិជ្ជាដូចគ្នានោះទេ។ ដូច្នេះអ្នក

ណាពូកែគណិតឱ្យគេជួយបង្រៀនគណិត អ្នកពូកែអក្សរសាស្ត្រឱ្យគេជួយបង្រៀនអក្សរសាស្ត្រដល់មិត្តភក្តិដទៃដែលមិនពូកែ។ លើសពីនេះទៅទៀត ត្រូវចេះបង្កើតចំណោទ បង្កើតសំណួរ រួចនាំគ្នាជួយស្វែងរកចម្លើយ នោះប្រាកដជាចេះទាំងអស់គ្នាជាមិនខាន។

**៥) ខំរៀនមុខវិជ្ជាខ្សោយឲ្យបានច្រើនជាងគេ៖** ជាទូទៅសិស្សណារៀនពូកែមុខវិជ្ជាណា គឺពួកគេចូលចិត្តរៀនតែមុខវិជ្ជានោះ។ ផ្ទុយមកវិញ អ្នកមិនត្រូវធ្វើដូចពួកគេឡើយ គឺត្រូវគិតថាមុខវិជ្ជាណាដែលខ្លួនរៀនខ្សោយជាងគេ គឺត្រូវខំរៀនមុខវិជ្ជានោះឲ្យបានច្រើនជាងមុខវិជ្ជាផ្សេងៗ ទើបអាចធ្វើឲ្យអ្នកក្លាយជាសិស្សពូកែបាន។

**៦) យកចិត្តទុកដាក់ស្ដាប់គ្រូពន្យល់៖** អ្នកត្រូវយកចិត្តទុកដាក់ តាមដានការពន្យល់របស់គ្រូឲ្យបានច្បាស់ ត្រូវកត់ត្រា ឬ គូសចំណាំនូវចំណុចសំខាន់ៗឲ្យបានច្បាស់។ ជាពិសេស ត្រូវហ៊ានបង្កើតសំណួរសួរគ្រូនូវចំណុចណាដែលមិនសូវច្បាស់ ឬមិនយល់។

**៧) រាប់អានមិត្តភក្តិដែលល្អនិងរៀនពូកែ៖** កាលណាមានមិត្តភក្តិល្អៗ និងមានមិត្តភក្តិដែលរៀនពូកែកាន់តែច្រើន នោះអ្នកនឹងខំរៀន ខំធ្វើខ្លួនឱ្យល្អ ឲ្យត្រឹមត្រូវដូចមិត្តរបស់អ្នកជាពុំខាន ព្រោះប្រសិនជាអ្នកមិនអាចធ្វើខ្លួនឱ្យត្រឹមត្រូវដូចគេ ឬរៀនមិនពូកែដូចគេ នោះអ្នកប្រាកដជាមានអារម្មណ៍ខ្មាស់ខ្លួនឯង និងខ្មាស់មិត្តភក្តិរបស់អ្នក ហើយអ្នកក៏មិនអាចដើរក្នុងចំណោមពួកគេបាន ព្រោះពួកគេជាក្រុមអ្នករៀនពូកែ។

**៨) សម្រាកលំហែរខួរក្បាលឲ្យបានល្អ៖** មិនត្រូវបង្ខំខ្លួនឯងឱ្យរៀនរហូតនោះទេ គឺត្រូវយកពេលសម្រាក និងដើរកម្សាន្តនៅកន្លែងដែលមានបរិយាកាសល្អ ខ្យល់បរិសុទ្ធ ដើម្បីលំហែរខួរក្បាលឱ្យមានអារម្មណ៍ស្រស់ថ្លា នោះខួរក្បាលរបស់អ្នកនឹងឆាប់ទទួល និងចាប់យកមេរៀនបានយ៉ាងឆាប់រហ័ស ហើយចងចាំបានយូរទៀតផង។

**៩) ញ៉ាំអាហារដែលមានប្រយោជន៍ដល់សុខភាព៖** អ្នកត្រូវញ៉ាំអាហារណាដែលអាចជួយបំប៉នខួរក្បាលឱ្យមានប្រាជ្ញាឈ្លាសវៃ និងរាងកាយមាំមួនបានល្អ នោះអ្នកនឹងមានកម្លាំង និងមានអារម្មណ៍ល្អក្នុងការខិតខំរៀនសូត្របន្តទៀតផងដែរ៕ ការសិក្សាគឺជារឿងមួយដែលមនុស្សគ្រប់រូបមិនអាចជៀសផុតបាន។ បើទោះបីជាយើងមានឱកាសស្មើគ្នាក្នុងការសិក្សាយ៉ាងណាក៏ដោយក៏ពេលខ្លះលទ្ធផលដែលចេញពីការសិក្សាក៏មិនដូចគ្នាដែរ។ អ្នកខ្លះរៀនពូកែ ខ្លះទៀតរៀនមិនសូវពូកែ។ តាមពិតទៅ អ្នកដែលរៀនពូកែគឺមិនមែនពឹងផ្អែកតែលើការរៀនជាមួយគ្រូនៅក្នុងសាលាប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ត្រូវធ្វើស្វ័យសិក្សាតាមវិធីសាស្ត្ររបស់ពួកគេម្នាក់ៗផងដែរ។ វិធីសាស្ត្រទាំង៩ នេះដើម្បីឱ្យអ្នកសិក្សាទទួលបានជោគជ័យក្នុងការសិក្សា និងការប្រឡងនានា។

## ២.៣ ទស្សនៈរបស់សិស្សទទួលបាននិទ្ទេស A នៅកម្ពុជា

ការធ្វើកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានជំរុញឱ្យសិស្សានុសិស្សខិតខំប្រឹងប្រែងរៀនសូត្រដោយ មិនចាំបាច់ត្រូវរង់ចាំដល់ពេលជិតប្រឡងបានខំរៀននោះឡើយ ពោលគឺពួកគាត់ចាប់ខិតខំប្រឹងប្រែងតាំងពីដំណាក់កាលដំបូងនៃឆ្នាំសិក្សា ព្រោះខ្លួនគាត់ផ្ទាល់ខ្លាចប្រឡងបាក់ឌុបមិនជាប់។ រីឯឪពុកម្ដាយយាយតាក៏ខ្លាចកូន ចៅប្រឡងបាក់ឌុបមិនជាប់ដែរ ដែលតម្រូវឱ្យពួកគាត់ត្រូវតែជំរុញនិងតាមដានកូនចៅគាត់ឱ្យខិតខំប្រឹងប្រែងរៀនសូត្រតាំងពីដើមទីមក។ នេះគឺជាចំណុចល្អមួយ ដែលផ្ដើមចេញពីការធ្វើកំណែទម្រង់ការប្រឡង។ ដូចមនុស្សដែលត្រូវលោតកម្ពស់អញ្ចឹង គឺមិនអាចទៅដល់ទីហើយបានលោតផ្លោតនោះទេ ពោលគឺត្រូវរត់ពីចម្ងាយទើបអាចលោតកម្ពស់ ឬលោតចម្ងាយទៅរួច។ នៅក្នុងពិធីសំណេះសំណាលនិងផ្ដល់រង្វាន់លើកទឹកចិត្តកាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ ២០១៩ កន្លងទៅនេះ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានមានប្រសាសន៍ថា ចៅៗដែលបានខិតខំប្រឡងជាប់នេះ គឺប្រាកដណាស់ថាបានប្រឹងប្រែងតាំងពីដើមទីរហូតមក (សម្ដេចតេជោ ហ៊ុន សែន Oct 7, 2019)។ ចំពោះឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាបានលើកឡើងថា នៅក្នុងគម្រោងការអប់រំបែបឌីជីថលត្រូវឱ្យសិស្សថ្នាក់មធ្យមសិក្សា និងឧត្តមសិក្សា រៀនតាមបែបថ្មី មិនមែនរៀនដោយការទន្ទេញមេរៀនឬទ្រឹស្ដីដូចមុននោះទេ ពោលគឺបង្រៀនសិស្សឱ្យត្រិះរិះពិចារណា និងធ្វើការងារជាក្រុម ស្រាវជ្រាវដោះស្រាយបញ្ហា និងធ្វើបទបង្ហាញដោយប្រើបច្ចេកវិទ្យាព័ត៌មានជាជំនួយ(Business-cambodia.com)។ ខាងក្រោមនេះគឺជាទស្សនៈកត្តាជោគជ័យដែលសិស្សទទួលបាននិទ្ទេស A មួយចំនួនបង្ហាញពីវិធីសាស្ត្រក្នុងការរៀនសូត្ររហូតទទួលបាននិទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិកន្លងមក។

កញ្ញា ម៉ក សោភ័ណ្ឌ ជាសិស្សនិទ្ទេសA នៅវិទ្យាល័យច្បារអំពៅ (ភ្នំពេញ) ៖ អ្វីដែលធ្វើឲ្យខ្ញុំទទួលបានជោគជ័យនៅថ្ងៃនេះ គឺដោយសារការខំប្រឹងប្រែងស្ដាប់គ្រូពន្យល់ ការរៀនគួរបន្ថែម ការស្រាវជ្រាវលំហាត់ថ្មីៗ ហើយពេលខួរក្បាលហត់ ខ្ញុំតែងមើលភាពយន្ត ឬស្ដាប់ចម្រៀងសិន។ ខ្ញុំមិនបង្ខំខួរក្បាលខ្ញុំទេ (thmey thmey 15, Sep 2015)។

កញ្ញា រៀង តេរីត សិស្សទទួលបាននិទ្ទេស A នៅវិទ្យាល័យ ហ៊ុន សែន មង្គលបុរី ខេត្តបន្ទាយមានជ័យបានឱ្យដឹងថា គន្លឹះទទួលបាននិទ្ទេស A សម្រាប់ខ្ញុំមានពីរចំណុចសំខាន់ ទី១

៖ការព្យាយាមគឺជារឿងដែលមិនអាចមើលរំលងបាន និងទី២ ខ្ញុំត្រូវចាប់យកចំណុចសំខាន់នៃមេរៀន ព្រោះការស្វែងរកចំណុចសំខាន់នៃមេរៀនធ្វើឲ្យខ្ញុំយល់មេរៀនទាំងមូល។

យុវជន លឹម រស្មី ជាសិស្សនិទ្ទេស A នៅវិទ្យាល័យ ជាស៊ីមសន្ធរម៉ុក (ភ្នំពេញ)បានរៀបរាប់ថា៖ សម្រាប់ខ្ញុំគន្លឹះក្នុងការទទួលបានជោគជ័យនៅថ្ងៃនេះ មាន៦ចំណុចសំខាន់ទី១ គឺការជឿជាក់លើខ្លួនឯង ហើយអ្វីផ្សេងៗទៀតគ្រាន់តែជាការបន្ទាប់បន្សំតែប៉ុណ្ណោះ ទី២មិនត្រូវដាក់សម្ពាធលើខ្លួនឯងថា ត្រូវតែបាននិទ្ទេស A នោះទេ ទី៣ ស្វែងយល់ដោយខ្លួនឯង ទី៤ រៀនឲ្យយល់ជាជាងចងចាំ ទី៥ ត្រូវយល់ស្ថានភាពសង្គម ទី៦ ត្រូវប្រមូលលំហាត់ពីគ្រប់មជ្ឈដ្ឋាន ពីគ្រូពីសិស្សពូកែមកមើលទាំងអស់ (thmey thmey 15, Sep 2015) ។

កញ្ញា អ៊ឹង មុនីរាសី សិស្សនិទ្ទេសA នៅវិទ្យាល័យ ព្រះមុនីវង្ស ខេត្តបាត់ដំបង បានបញ្ជាក់ថា៖ ដើម្បីឲ្យរៀនពូកែជាដំបូងយើងត្រូវតាំងចិត្តឲ្យខ្ពស់ ឆ្ពោះទៅរកគោលដៅដែលយើងចង់បានបំផុត ហើយស្វ័យសិក្សាជាកត្តាសំខាន់មួយ ដែលធ្វើឲ្យខ្ញុំមានចំណេះដឹង។

កញ្ញា វ៉ែន ម៉ុមមុនិតា សិស្សនិទ្ទេសA នៅវិទ្យាល័យទ័ពមានជ័យ ខេត្តកំពង់ស្ពឺ ផ្តល់នូវបទពិសោធថា៖ សម្រាប់ខ្ញុំអ្វីដែលខ្ញុំតែងតែធ្វើគឺការអត់ធ្មត់ ព្រោះវាជាឱសថនាំយើងឆ្ពោះទៅរកភាពជោគជ័យ។ លើសពីនេះ ការបែងចែកកាលវិភាគក៏ជារឿងសំខាន់ ព្រោះដើម្បីគ្រប់គ្រងខ្លួនឯងកុំឲ្យរៀនតាមអារម្មណ៍។ ម្យ៉ាងទៀត ការអានច្រើន ដូចជាសារព័ត៌មាន សៀវភៅ ស្តាប់វិទ្យុ ជាដើម ធ្វើឲ្យខ្ញុំមានចំណេះដឹងទូទៅច្រើន ដែលងាយស្រួលក្នុងការសរសេរពេលប្រឡង។ មួយវិញទៀត ការរៀនបែបទន្ទេញឲ្យចាំ មិនមែនជាមធ្យោបាយដែលខ្ញុំតែងធ្វើនោះទេ តែខ្ញុំរៀនឲ្យយល់ប្រសើរជាង (thmey thmey 15, Sep 2015)។

កញ្ញា វ័ន្ត ច័ន្ទរស្មី ជាសិស្សនិទ្ទេសA នៅវិទ្យាល័យឥន្ទ្រទេវី រាជធានីភ្នំពេញ បានប្រាប់ថា៖ គន្លឹះក្នុងការសិក្សា សម្រាប់ខ្ញុំគឺការដកស្រង់បទពិសោធពីសិស្សច្បងដែលពូកែៗ និងរៀនតាមកាលវិភាគឲ្យបានច្បាស់លាស់ ហើយត្រូវគោរពតាមកាលវិភាគនោះឲ្យបានជាដាច់ខាត។ លើសពីនេះ ខ្ញុំធ្វើលំហាត់ជាមួយមិត្តតាមហ្វេសប៊ុក (facebook) ព្រោះវាងាយស្រួលមិនចាំបាច់ជួបមុខគ្នាក៏អាចរៀនជាមួយគ្នាបានដោយងាយស្រួល។ ម្យ៉ាងទៀត វាគ្មានអ្វីសំខាន់ជាងរៀនដោយខ្លួនឯងនោះទេ ព្រោះមានតែខ្លួនឯងទេ ដែលដឹងពីចំណុចខ្សោយឬចំណុចខ្លាំងរបស់ខ្លួន ។ពេលយើងដឹងពីចំណុចខ្សោយរបស់យើង យើងយកទៅសួរគ្រូ ពេលនោះយើងនឹងចេះច្បាស់ និងចាំទុកជារៀងរហូត((thmey thmey 15, Sep 2015)។

យុវជន ផាង វេងអាន ជាសិស្សសិក្សានៅសាលាក្នុងរាជធានីភ្នំពេញដែលប្រឡងបាក់ឌុបបាននិទ្ទេសA ក្នុងឆ្នាំ២០១៤បានចែករំលែកបទពិសោធលើគន្លឹះទទួលបានជោគជ័យ

ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមាន៣គឺៈ ទី១កត្តាខ្លួនឯងពោល ការបែងចែកពេលវេលារៀន ការអានសៀវភៅឱ្យបានច្រើន ការកត់សម្គាល់មេរៀនដែលយើងបានអាន ការធ្វើលំហាត់ ការស្រាវជ្រាវមេរៀន និងការធ្វើលំហាត់រៀនគួរបន្ថែម ទី២កត្តាគ្រួសារឪពុកម្តាយបានលើកទឹកចិត្តក្នុងការសិក្សា និងបានផ្តល់ជាសម្ភារៈសម្រាប់ការសិក្សា ដោយណែនាំក្នុងផ្លូវល្អ ទី៣កត្តាសាលារៀន មានលោកគ្រូអ្នកគ្រូបានជួយពន្យល់មេរៀន និងធ្វើលំហាត់ព្រមទាំងផ្តល់នូវវិធីសាស្រ្តក្នុងការរៀន ហើយសាលាមានបន្ទប់សិក្សាស្រាវជ្រាវសម្រាប់សិស្ស(http://www.rfi.fr/km/cambodia/success-story-20-08-2019)។

យុវជន សៀវ ស៊ីផាត់ មកពីវិទ្យាល័យព្រះសីហនុ ខេត្តព្រះសីហនុ ដែលបានប្រឡងបាក់ឌុបឆ្នាំ២០១៩ មានកម្រិតពិន្ទុ ១០០ ក្នុងចំណោមសិស្សនិទ្ទេសA ៩៨៣នាក់ បានប្រាប់ពីកត្តាជោគជ័យក្នុងការប្រឡងគឺដោយសារៈ ការសិក្សាខ្លួនឯងជាកត្តាចម្បងមួយដែលយើងម្នាក់ៗត្រូវអនុវត្តដោយយកចិត្ត ទុកដាក់ មិនថាការរៀននៅសាលាវីនៅផ្ទះនោះទេ។ វាជាការពិត ប្រសិនបើយើងរៀនខ្លួនឯងមួយថ្ងៃត្រឹមតែ៥ម៉ោង យើងនឹងមានការកើនឡើងនូវចំណេះដឹង។ សាលារៀនក៏ជាផ្នែកមួយសម្រាប់ខ្ញុំក្នុងការសិក្សាទទួលបានជោគជ័យដែរដោយមានលោកគ្រូអ្នកគ្រូបានបង្ហាត់បង្រៀននូវមេរៀនល្អៗ។ គ្រួសាររបស់ខ្ញុំក៏បានផ្តល់ជាកម្លាំងចិត្តក្នុងការសិក្សា និងសម្ភារៈសម្រាប់ការរៀនសូត្រដែរ (https://wwwbusiness- Cambodia.com ) ។

យុវតី ថន រតនា ជាអតីតសិស្សនិទ្ទេស A លំដាប់ពិន្ទុ ១០០ នៃឆ្នាំសិក្សា ២០១៨បានរៀបរាប់ថាមានរបៀបរៀនត្រឹមត្រូវ ដោយ បានបែងចែកកាលវិភាគសម្រាប់រៀន។ កញ្ញា ថន រតនា បញ្ជាក់ថា ក្រៅពីរៀននៅសាលារដ្ឋ នាងក៏បានបែងចែកកាលវិភាគសម្រាប់រៀននៅផ្ទះដោយខ្លួនឯងផងដែរដោយក្នុងមួយថ្ងៃ រតនាត្រូវក្រោករៀននៅពេលព្រឹកព្រលឹម និងមុនពេលចូលគេង។ បើតាមយុវតី រតនា ពេលព្រឹកនាងតែងក្រោករៀនមុខវិជ្ជាអក្សរសាស្រ្តខ្មែរ និងប្រវត្តិវិទ្យា។ រីឯពេលយប់ នាងរៀនផ្តោតលើមេរៀនលំហាត់ដូចជាៈ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា។ ការទទួលបាននិទ្ទេសAមិនមែនជារឿងចៃដន្យសម្រាប់សិស្សានុសិស្សឡើយ។ សិស្សានុសិស្ស ដែលត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានខិតខំរៀនសូត្រ និងស្រាវជ្រាវគន្លឹះសំខាន់ៗរបស់សិស្សច្បងមុនៗមកអនុវត្ត ដើម្បីទទួលបានលទ្ធផលល្អ។ កញ្ញា ថន រតនា អតីតសិស្សនិទ្ទេស A លំដាប់ខ្ពស់ ដែលបច្ចុប្បន្នជានិស្សិតពេទ្យឆ្នាំទី១នៃសាកលវិទ្យាល័យវិទ្យាសាស្រ្តសុខាភិបាល បានលើកឡើងថាៈ ខ្ញុំមានកាលវិភាគស្វ័យសិក្សាផ្ទាល់ខ្លួន។ ខ្ញុំរៀនពេលយប់ និងពេលព្រឹក។ ពេលយប់ខ្ញុំចាប់ផ្តើមរៀនពីម៉ោង ៩ ដល់ម៉ោង ១១ គឺរៀនមុខវិជ្ជាវិទ្យាសាស្រ្ត៣មុខ គណិតវិទ្យា, រូបវិទ្យា និងគីមីវិទ្យា ហើយសល់ពេល

ខ្ញុំធ្វើលំហាត់ជីវវិទ្យា។ ដោយឡែក ពេលព្រឹកខ្ញុំរៀនលើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ និងប្រវត្តិវិទ្យា (thmey thmey media youbute Jul 10, 2019)។

យុវសិស្ស ចាន់ ពិចិត្រ ជាសិស្សដែលបានប្រឡងជាប់និទ្ទេស A មានលំដាប់ពិន្ទុ១០០ នៅឆ្នាំ២០១៨មកពី វិទ្យាល័យព្រះបាទសុរាម្រិត ខេត្តកំពង់ឆ្នាំង។ ការដែលទទួលបានជោគជ័យក្នុងការប្រឡងនេះ យុវសិស្សរូបនេះបានបញ្ជាក់ថាមានកត្តាបីសំខាន់សម្រាប់គាត់គឺ៖ កត្តាខ្លួនឯង ការខិតខំប្រឹងរៀនសូត្រ ការអានសៀវភៅ ធ្វើលំហាត់ រៀនគួរបន្ថែមសម្រាប់មុខវិជ្ជាដែលត្រូវប្រឡង បែងចែកពេលវេលាក្នុងការសិក្សានៅផ្ទះ រៀនជាមួយមិត្តភក្តិ ស្រាវជ្រាវ លំហាត់តាមInternet។ កត្តាគ្រួសារ បានជួយជំរុញលើកទឹកចិត្ត ណែនាំក្នុងការរៀនសូត្រ ការឧត្ថម្ភជាសម្ភារៈ និងថវិកា និងផ្តល់សេចក្តីស្រឡាញ់ពីក្រុមគ្រួសារ។ កត្តាសាលារៀន មានលោកគ្រូអ្នកគ្រូ បានជួយបង្ហាត់បង្រៀននូវមេរៀនល្អៗដល់ខ្ញុំ ប្រាប់ពីវិធីក្នុងការប្រឡង ផ្តល់ដំបូលន្មាន និងបានផ្តល់ជាកម្លាំងចិត្តក្នុងការរៀនសូត្រ (YOURTURN CTN Youbute )។

យុវសិស្ស ឡី សត្យា ជាសិស្សនិទ្ទេសA នៅឆ្នាំសិក្សា២០១៨-២០១៩ មកពីសាលាប៊ែលធី អន្តរជាតិ ភ្នំពេញ បានរៀបរាប់ថា ខ្ញុំបានប្រឡងជាប់និទ្ទេសA ដោយសារតែការរៀនសូត្រខ្លួនឯង ទាំងនៅផ្ទះនិងនៅសាលា ហើយត្រូវកំណត់គោលដៅឱ្យច្បាស់លាស់ក្នុងការរៀនសូត្រ និងតាមដានការសិក្សាជារៀងរាល់ខែ។ កត្តាសាលារៀន មានអ្នកគ្រូ លោកគ្រូដែលមានសមត្ថភាពក្នុងការបង្រៀន ចែករំលែកនូវចំណេះដឹងល្អៗសម្រាប់សិស្សានុសិស្សគ្រប់ៗគ្នា។ គ្រួសាររបស់ខ្ញុំបានផ្តល់កម្លាំងចិត្ត និងជំរុញខ្ញុំឱ្យខិតខំរៀនសូត្រដើម្បីក្លាយជាសិស្សល្អ ( Youbute)។

យុវសិស្ស វណ្ណ លីដា ជាសិស្សដែលបាននិទ្ទេស A នៅឆ្នាំ២០១៨ វិទ្យាល័យសៀមរាបបានរៀបរាប់ថា ការរៀនសូត្រទទួលបាននិទ្ទេសA មិនស្ថិតលើអ្នកមាន រឺ អ្នកក្រនោះទេ ហើយកត្តាជោគជ័យក្នុងការសិក្សានេះគឺដោយសារតែការខិតខំរៀនសូត្រដោយខ្លួនឯង ដោយមានការបែងចែកពេលវេលារៀន។ មុនពេលចូលដេកត្រូវមើលមេរៀនឱ្យបាន៤ម៉ោង និងរៀនគួរជាមួយគ្រូបន្ថែម មើលគំរូសិស្សច្បងមុនៗ។ គ្រួសារខ្ញុំបានផ្តល់ថវិកាតិចតួច និងមានសម្ភារការសិក្សា ។ ចំពោះសាលារៀនគឺដោយសារមានគ្រូល្អៗបានបង្ហាត់បង្រៀននូវមេរៀនល្អ បានពន្យល់  ក្បោះក្បាយ មានបន្ទប់បណ្ណាល័យសម្រាប់ធ្វើការស្រាវជ្រាវ និងអានសៀវភៅ។

សរុបសេចក្តីមក ចំពោះភាពជោជ័យក្នុងការសិក្សារបស់សិស្សដែលទទួលបាននិទ្ទេសA គឺអាស្រ័យលើកត្តាបីសំខាន់ៗរួមមានះកត្តាខ្លួនគាត់ផ្ទាល់ កត្តាសាលារៀន កត្តាគ្រួសារ និងមានកត្តារួមផ្សំមួយទៀតគឺកត្តាសង្គម (មិត្តភក្តិ សហគមន៍ ឬរាជ រដ្ឋាភិបាលជាដើម)។

## ២.៤ ទស្សនៈអ្នកប្រាជ្ញ និងបុគ្គលល្បីៗដែលជោគជ័យក្នុងការសិក្សា

ការសិក្សាមិនមែនជាការងាយស្រួលសម្រាប់មនុស្សគ្រប់គ្នានោះទេ។ ការខិតខំប្រឹងប្រែងរៀនសូត្រវាអាស្រ័យទៅលើមនុស្សម្នាក់ៗដើម្បីទទួលបានជោគជ័យក្នុងការសិក្សា។ អ្នកខ្លះការទទួលបានជោគជ័យក្នុងការសិក្សាគឺអាស្រ័យទៅលើកត្តាខ្លួនឯង កត្តាគ្រួសារដែលជាអ្នកមាន កត្តាសាលារៀនដែលមានគ្រូល្អៗក្នុងការបង្ហាញផ្លូវ និងមានកត្តាសង្គមរួមផ្សំ។ សម្រាប់បុគ្គលល្បីៗ និងអ្នកប្រាជ្ញមួយចំនួនតើពួកគាត់មានការសិក្សាដូចម្តេចបានក្លាយជាបុគ្គលល្បី និងក្លាយជាអ្នកប្រាជ្ញក្នុងពិភពលោកដែលមនុស្សទូទៅស្គាល់ហើយបន្សល់ស្នាដៃទុកដល់មនុស្សជំនាន់ក្រោយរៀនសូត្រតាម។

សម្តេចព្រះមហាសុមេធាធិបតីជួន ណាត ប្រសូតនៅថ្ងៃអង្គារ ១១រោច ខែផល្គុន ពុទ្ធសករាជ ២៤២៧ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ១៨៨៣ នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ព្រះបិតានាមជួន ព្រះមាតានាម យក់ ។ គ្រួសារនេះមានបុត្រតែពីរគត់គឺសម្តេចនិងឧកញ៉ាសោភណមន្ត្រីជួននុត (https://kohsantepheapdaily.com.kh/article/125336.html ២៨. ៧. ២០១៥)។ សម្តេចព្រះសង្ឃរាជ ជួន ណាត មានសេចក្តីព្យាយាមប្រកបដោយថាមពលក្លៀវក្លាក្នុងការសិក្សា ទាំងផ្នែកភាសាបាលី ទាំងផ្នែកភាសាឯទៀតៗ មានភាសាបារាំងជាដើម។ ការសិក្សារបស់សម្តេចព្រះសង្ឃរាជមានភាពជោគជ័យប្រសើរណាស់ហើយមានតែសម្តេចព្រះសង្ឃរាជទេដែលរៀនចម្រើនលូតលាស់ មានល្បឿនឈ្នះលោកឯទៀតៗ។ សម្តេចចាប់រៀនដំបូងមេសូត្រ ប្រែមូលកច្ចាយនៈ និងគម្ពីរធម្មបទ អំពីព្រះពុទ្ធឃោសាចារ្យព្រះនាម ម៉ា កេត ដែលជាព្រះ ឧបជ្ឈាយ៍ នៃសម្តេចព្រះសង្ឃរាជ។ សម្តេចព្រះសង្ឃរាជ ដែលទ្រង់ចាប់រៀនវិជ្ជាណាមួយ មានវិជ្ជាបាលីជាដើម គឺរៀនដោយយកព្រះទ័យទុកដាក់ ខិតខំប្រឹងប្រែង ឥតមានបន្ធូរបន្ថយក្នុងការសិក្សានោះឡើយ។ សម្តេចទ្រង់ទទួលការសិក្សានោះគឺសិក្សាដោយឆន្ទៈដ៏មានកម្លាំងមែនទែន ពុំមែនសិក្សាវិជ្ជាណាមួយដោយលេងៗទេ។ វិជ្ជាខាងភាសាបាលីភាសាសំស្ក្រឹត និងភាសាបារាំង សុទ្ធតែវិជ្ជាដែលប្រដាប់ដោយវេយ្យាករណ៍ហ្មត់ចត់ ជ្រាលជ្រៅលំបាករៀន និងលំបាកយល់ជាទីបំផុត ប៉ុន្តែសម្តេចអាចរៀន

អាចយល់ច្បាស់លាស់ដោយឆាប់រហ័សគួរឲ្យកោតសរសើរពន់ពេកណាស (khmerpostasia .com/archuves/16630 14.08.2018)។

លោកនីកូឡា តេសឡា(Nikolas Tesla) 1856-1943 នៅប្រទេសអូទ្រីស ជាអ្នកប្រាជ្ញខាងអគ្គិសនីចរន្តឆ្លាស់ AC និងប្រព័ន្ធបញ្ជូនសារឥតខ្សែ (Wireless) ដែលមានឪពុកជាបុព្វជិតគ្រីស្តសាសនា ម្តាយជាស្រ្តីមេផ្ទះហើយម្តាយរបស់គាត់ពូកែចងចាំ និងពូកែខាងមេកានិច។ កត្តាជោគជ័យក្នុងការសិក្សារបស់លោកដោយសារការខិតខំប្រឹងប្រែងដោយខ្លួនឯង ព្យាយាមធ្វើពិសោធផ្នែកថាមពលមេកានិច។ ការរៀននៅសាកលវិទ្យាល័យប្រាក(ឆែក)លោកតែងតែយកចិត្តទុកដាក់ជាពិសេសលើមេរៀនរូបវិទ្យា។ ចំពោះគ្រួសារលោកវិញមានការយកចិត្តទុកដាក់ និងជួយជ្រោមជ្រែង លើកទឹកចិត្តក្នុងការសិក្សារហូតបានក្លាយជាអ្នកប្រាជ្ញខាងផ្នែកអគ្គិសនី(ចរន្តឆ្លាស់) និងប្រព័ន្ធបញ្ជូនសារឥតខ្សែ (Wireless) (www.rfi.fr/km 09.08.2018)

លោក អាល់ប៊ែរ អាញ់ស្តាញ់(1878-1955) កើតនៅថ្ងៃទី១៤ ខែមិនា ឆ្នាំ១៨៧៩ នៅទីក្រុងអ៊ូម(Ulm) ប្រទេសអាល្លឺម៉ង់ ជាអ្នកប្រាជ្ញដែលរកឃើញទ្រឹស្តីនាំទៅដល់ការបង្កើតអាវុធនុយក្លេអ៊ែរ។ គាត់ជាអ្នកវិទ្យាសាស្រ្តផ្នែករូបវិទ្យា។ បើនិយាយពីការសិក្សារៀនសូត្ររបស់លោកគឺ គាត់សិក្សាដោយខ្លួនឯងច្រើនជាងនៅសាលា។លោកចូលចិត្តរៀនដោយមានសេរីភាពក្នុងការសិក្សា ការអានសៀវភៅ និងឈ្វេងយល់លើប្រធានបទដោយខ្លួនគាត់ផ្ទាល់ ព្រមទាំងមានការត្រិះរិះពិចារណា និងការអនុវត្ត។ ចំពោះការសិក្សានៅសាលាគាត់មិនបានជោគជ័យទេ ដោយគាត់មិនចូលចិត្តធ្វើតាមគ្រូ និងវិន័យសាលាដោយការរៀនមានការទន្ទេញចាំមាត់ និងអានតាមគ្រូ (rfr.fr/km/world-history-biography 18.06.2017)។

លោកថូម៉ាស់ អេឌីសុន (Thomas Edison February 11.1847- October18. 1931)ជនជាតិអាមេរិក ជាអ្នកប្រាជ្ញដែលបានរកឃើញនូវគំនិតថ្មីៗជាច្រើន រាប់ចាប់តាំងពីប្រព័ន្ធចែកចាយថាមពលអគ្គិសនី រហូតដល់ឧបករណ៍ប្រើថាមពលអគ្គិសនី ជាពិសេស អំពូលភ្លើង ឧបករណ៍ថតសំឡេងនិងបំពងសំឡេង និងឧបករណ៍ថតនិងបញ្ចាំងខ្សែភាពយន្ត។ ការសិក្សារបស់លោក គឺរៀនសូត្រដោយខ្លួនឯងតាមរយៈការធ្វើពិសោធជាច្រើនលើកច្រើនសារក្នុងការបង្កើតអំពូលភ្លើង។ ចំពោះការសិក្សានៅសាលារៀនលោកមិនទទួលបានជោគជ័យនោះទេ ដោយលោករៀនមិនចេះរហូតដល់គ្រូបានផ្ញើសំបុត្រមកម្តាយថាកូនរបស់អ្នក សាលាមិនអាចបង្រៀនបានទេ។ចំណែកគ្រួសាររបស់លោកគឺមានម្តាយជាអ្នកជួយបង្រៀននៅផ្ទះ និងលើកទឹកចិត្តកូនក្នុងការរៀនសូត្រ។ ក្រៅពីមានម្តាយដែលមានទេពកោសល្យក្នុងការបង្រៀន អេឌីសុន មានឪពុកជាអ្នកចូលចិត្តអាន ហើយសម្បូរសៀវភៅដែលអាចធ្វើជាកូនបណ្ណាល័យតូច

មួយនៅក្នុងផ្ទះបាន។ នៅផ្ទះ ក្រៅពីទទួលការបង្រៀនពីម្ដាយ អេឌីសុនក៏បានចំណាយពេលជាច្រើនផងដែរក្នុងការអានសៀវភៅរបស់ឪពុកព្រមទាំងការធ្វើ ពិសោធន៍គ្រប់សព្វបែបយ៉ាងតាំងពីពេលមានអាយុទើបនឹងបាន១១ឆ្នាំមកម្ល៉េះ (https://en.wikipedia.org/wiki/Thomas_Edison)។

លោក អាឡាន់ ធូរីង កើតនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩១២ នៅក្នុងទីក្រុងឡុងដ៍ ប្រទេសអង់គ្លេសជាអ្នកដែលបង្កើតទ្រឹស្ដី នាំទៅដល់ការបង្កើតម៉ាស៊ីនកុំព្យូទ័រ ហើយពេលខ្លះត្រូវបានគេចាត់ទុកថាជា "បិតានៃវិទ្យាសាស្ត្រកុំព្យូទ័រសម័យទំនើប"។គាត់ គឺអ្នកប្រាជ្ញផ្នែកគណិតវិទ្យា។ តាំងពីក្មេងមក អាឡាន់ ធូរីង គឺជាក្មេងឆ្លាត ហើយគ្រូនៅសាលាក៏ចាប់អារម្មណ៍ដែរពីភាពឆ្លាតវៃខុសពីធម្មតារបស់អាឡាន់ ធូរីង ក៏ប៉ុន្តែ គ្រូមិនសូវជាយកចិត្តទុកដាក់។ ដោយសារតែភាពឆ្លាតវៃរបស់អាឡាន់ ធូរីង លើផ្នែកគណិតវិទ្យា គាត់បានប្រឡងជាប់ចូលរៀននៅឯសាកលវិទ្យាល័យដ៏ល្បីល្បាញមួយនៅអង់គ្លេស គឺសាកលវិទ្យាល័យខេមប្រ៊ិច។ អាឡាន់ ធូរីង បានរៀនជាប់ជានិស្សិតឆ្នើមលំដាប់ទី១ខាងគណិតវិទ្យាហេតុត្រូវបានសាកលវិទ្យាល័យជ្រើសរើសឲ្យធ្វើជាអ្នកស្រាវជ្រាវខាងគណិតវិទ្យា។ នៅឆ្នាំ១៩៣៥ គាត់មានសមត្ថភាពអាចធ្វើការគណនានូវគ្រប់អ្វីៗទាំងអស់ដែលគេអាចគណនាបាន។ ទ្រឹស្ដីនៅក្នុងឯកសារនេះហើយ ដែលក្រោយមកបានក្លាយទៅជាមូលដ្ឋានគ្រឹះ នៃវិទ្យាសាស្ត្រកុំព្យូទ័រសម័យទំនើប ហើយដែលត្រូវគេចាត់ទុកថាជាមូលដ្ឋានគ្រឹះមួយផងដែរ នៃបញ្ញាសប្បនិម្មិត នៅឆ្នាំ១៩៣៦។ អាឡាន់ ធូរីង បានចាកចេញពីអង់គ្លេស ទៅបន្តការសិក្សាថ្នាក់បណ្ឌិតខាងគណិតវិទ្យា នៅឯសកលវិទ្យាល័យដ៏ល្បីល្បាញមួយនៅសហរដ្ឋអាមេរិក គឺសាកលវិទ្យាល័យព្រីនស្តុន។ នៅឆ្នាំ១៩៤០ កិច្ចខិតខំប្រឹងប្រែងរបស់អាឡាន់ ធូរីងក៏សម្រេចបានជោគជ័យរហូតឈានទៅបង្កើតបាននូវម៉ាស៊ីនបំបែកកូតសម្ងាត់ដែលគេឲ្យឈ្មោះថា"The Bombe" (http://www.rfi.fr/km ១៧.១០.២០១៨)។

រួមសេចក្ដីមក យើងអង្កេតឃើញថា ការជោគជ័យរបស់អ្នកប្រាជ្ញខាងលើ គឺអាស្រ័យទៅលើការខិតខំប្រឹងប្រែងខ្លួនគាត់ផ្ទាល់ជាកត្តាចម្បងក្នុងការបង្កើតនូវទ្រឹស្ដី និងរបស់ប្រើប្រាស់ដល់សព្វថ្ងៃ ហើយមានអ្នកខ្លះទៀតអាស្រ័យទៅកត្តាគ្រួសារជាអ្នកជួយដើម្បីឱ្យក្លាយទៅជាអ្នកប្រាជ្ញ។ ចំពោះកត្តាសាលារៀនវិញបានផ្ដល់នូវចំណេះដឹងតែមួយផ្នែកមិនគ្រប់គ្រាន់នោះទេ ហេតុដូច្នេះហើយធ្វើឱ្យពួកគាត់ខិតខំរៀនសូត្រខ្លួនឯងរហូតដល់បានជោគជ័យក្នុងការសិក្សា។

## ២.៥ បញ្ហាសិស្សក្នុងការសិក្សា

កត្តាសំខាន់ដែលបង្កើតឱ្យមានជាឧបសគ្គចំពោះសិស្សគឺ មានកត្តាពីរយ៉ាង គឺកត្តាខាងក្នុង និងកត្តាខាងក្រៅ។ កត្តាខាងក្នុង គឺកត្តាសិស្សផ្ទាល់។ កត្តាខាងក្រៅ គឺកត្តាគ្រួសារ កត្តាសង្គម កត្តាសេដ្ឋកិច្ច រឺក៏ការគ្រប់គ្រងកម្មវិធីសិក្សា។

### ២.៥.១ កត្តាខាងក្នុង

យោងទៅតាមការសិក្សា សិស្សភាគច្រើននៅពេលដែលពួកគេមានភាពមមាញឹកក្នុងការសិក្សាច្រើន ពួកគេអាចជួបនូវបញ្ហាសុខភាព។បញ្ហាសុខភាពនេះហើយដែលធ្វើឱ្យពួកគេខកខានមិនបានមករៀន រឺមករៀនមិនបានទៀងទាត់ មិនយកចិត្តទុកដាក់ធ្វើកិច្ចការគ្រូជាដើម។ យូរៗទៅទង្វើបែបនេះក៏ក្លាយជាទម្លាប់មួយរបស់សិស្សដែលមិនអាចកែប្រែ រហូតធ្វើឱ្យពួកគេមានភាពធុញទ្រាន់ចំពោះការសិក្សា (Horn,2003) ។

ទីបញ្ចប់ពួកគេក៏ជ្រើសផ្លូវមួយ ដោយធ្វើការបោះបង់ការសិក្សាទាំងមិនស្តាយស្រណោះ ទោះបីជាដឹងថាផលប្រយោជន៍នៃការសិក្សានេះ វាមិនមែនជាប្រយោជន៍សម្រាប់បុគ្គលណាក្រៅពីខ្លួនឯងប៉ុណ្ណោះ។ សិស្សមួយចំនួនបានគិតថាការសិក្សារបស់ពួកគេគ្មានអ្វីក្រៅពីចង់បានការងារ និងរកប្រាក់បាននោះទេ មិនចាំបាច់អីនឹងទៅខ្វល់ខ្វាយពីការរៀនសូត្រធ្វើអ្វីទៀត។

### ២.៥.២ កត្តាខាងក្រៅ

#### ២.៥.២.១ កត្តាសង្គម

តាមរយៈការសិក្សាមួយស្តីអំពីតម្លៃនៃការសិក្សា បានបង្ហាញឱ្យឃើញពីគុណប្រយោជន៍នៃការសិក្សា (Walkar, 2009)។ មិនថាវ័យណាឡើយ ការសិក្សាពិតជាសំខាន់ដែលខានមិនបាន គឺទាមទារឱ្យយើងគ្រប់រូបត្រូវទទួលការសិក្សាជាកំហិត ដើម្បីអភិវឌ្ឍន៍ខ្លួនឯងឱ្យស្របទៅនឹងតម្រូវការសង្គមនាពេលបច្ចុប្បន្ន។ក្រៅពីនេះ ក៏មានការសិក្សា Pilly, Rhodes and Wilss (2004) មួយទៀតដែរ បានបង្ហាញពីតម្រូវការការងារនៅក្នុងសង្គមដែលធ្វើឱ្យសិស្សមួយចំនួនទៅធ្វើការដោយមិនបានគិតពីការសិក្សារបស់គេទេ ហើយម៉្យាងទៀតការសិក្សានេះក៏បានលើកឡើងថាការសិក្សាតែងតែមានសម្ពាធពីសង្គម ដែលអូសទាញសិស្សឱ្យបោះបង់ការសិក្សា។

#### ២.៥.២.២ កត្តាគ្រួសារ

ចំពោះកត្តាគ្រួសារនេះ អ្នកសិក្សាSutherland and Crowther(2006)បានធ្វើការបកស្រាយថាកត្តានេះ វាបានធ្វើឱ្យសិស្សគ្រប់រូបមានភាពស្មុកស្មាញមែនទែនក្នុងដំណើរការងារ

ផ្ទះក៏ដូចជាការសិក្សា។ វាពិតជារឿងមួយដែលធ្ងន់ធ្ងរពិបាក នឹងវែកពន់ ប៉ុន្តែសិស្សនូវតែខិតខំប្រឹងប្រែងក្នុងការបន្តការសិក្សាដើម្បីកសាងអនាគតរបស់ពួកគេ។ សិស្សដែលមានការលំបាកតែងតែមានបញ្ហាបន្តិចបន្តួចជាមួយគ្រួសារដែលបានជះឥទ្ធិពលមកលើការសិក្សា បណ្ដាលឱ្យពួកគេមិនអាចប្រមូលអារម្មណ៍ផ្ដោតទៅលើការសិក្សាគឺពិតជាមិនបាន។

កត្តានេះហើយដែលMarty Liebowits and Taylor(2004)បានបង្ហាញនៅក្នុងរបាយការណ៍ពីកត្តារួមផ្សំខាងលើជាច្រើនដែលជំរុញទឹកចិត្តសិស្សបោះបង់ការសិក្សា។ ពេលខ្លះក៏មានកត្តាប្រយោលទាំងនេះបានផ្ដល់ផលប៉ះពាល់ខ្លាំងចំពោះការសិក្សា។ កត្តាប្រយោលទាំងនោះមានដូចជាកង្វះការថែរក្សារីភាពស្និតស្នាលចំពោះកូន ខ្វះពេលវេលាគ្រប់គ្រាន់ក្នុងការអប់រំកូន ភាពឈឺថ្កាត់របស់សមាជិកគ្រួសារជាដើម ដែលជំរុញឱ្យសិស្សមិនអាចបំពេញតួនាទីសិក្សាបានល្អ។

## ២.៥.២.៣ កត្តាហិរញ្ញវត្ថុ

យោងតាមការសិក្សារបស់លោកLiebowits and Taylor(2004) បានបន្តការបកស្រាយថាក្រុមសិស្សដែលមានការខ្វះខាតលើហិរញ្ញវត្ថុ គឺសិស្សដែលស្ថិតនៅក្នុងជីវភាពគ្រួសារក្រីក្រដែលតម្រូវឱ្យពួកគេរៀនបណ្ដើរនឹងធ្វើការងារបណ្ដើរ។ បញ្ហាសេដ្ឋកិច្ចនេះហើយដែលតម្រូវប្រើប្រាស់ពេលវេលាសិក្សារបស់ខ្លួនមកធ្វើការងារក្នុង ការរកប្រាក់កម្រៃដើម្បីដោះស្រាយបញ្ហាជីវភាពដែលកំពុងតែប្រឈមមុខនឹងបញ្ហាលំបាក។ ផ្ទុយមកវិញសិស្សមួយចំនួនធំ ជួបប្រទះបញ្ហាជីវភាពខ្លាំងក៏ពុំសូវបំពេញតាមគោលការណ៍រីមករៀនបំពេញម៉ោងសិក្សា បានត្រឹមត្រូវល្អប្រសើរនោះទេ ពេលខ្លះពួកគេអវត្តមានច្រើនចំពោះម៉ោងសិក្សា ដែលបណ្ដាលឱ្យការទទួលចំណេះដឹងពីការសិក្សានូវមានកម្រិត ដែលពិបាកយកទៅ ប្រើប្រាស់ឬអនុវត្តបានឡើយ។កត្តាខាងលើនេះហើយដែលបានជំរុញទឹកចិត្តសិស្សមិនចង់បន្តការសិក្សា ពីព្រោះពួកគេពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបន្តការសិក្សានាពេលនេះ។

## ២.៥.២.៤ កម្មវិធីសិក្សា

តាមការបកស្រាយរបស់ Mintzberg(2009) និង Wayne(2000)ការគ្រប់គ្រងកម្មវិធីសិក្សាក៏ជាកត្តា មួយដែលធ្វើឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលមិនបានគាប់ប្រសើរដែរ។ ប្រសិនបើការគ្រប់គ្រងកម្មវិធីសិក្សានូវមានភាពខ្សត់ខ្សោយនោះ ការរៀបចំកម្មវិធីសិក្សារបស់ក្រសួងអប់រំក៏នូវមានដែនកំណត់ ដែលមិនទាន់អាចឆ្លើយតបទៅនឹងសង្គមការងារដែលសិស្សកំពុងតែត្រូវការជាចាំបាច់ ក៏អាចបណ្ដាលឱ្យសិស្សមិនមានចំណាងចង់បន្តការសិក្សាទៅមុខ

ទៀតឡើយ។ ជាក់ស្តែងការសិក្សាកម្មវិធីនៅតាមសាលារៀនសព្វថ្ងៃ តាមមុខវិជ្ជានីមួយៗមានច្រើនជំពូក និងមេរៀនដែលជាហេតុធ្វើឱ្យការសិក្សាមិនចប់កម្មវិធី។

## ២.៦ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩- ២០២៣

សម្រាប់ប្រទេសកម្ពុជាក្នុងនីតិកាលទី៦ នៅក្នុងផែនការយុទ្ធសាស្រអភិវឌ្ឍជាតិ ២០១៩-២០២៣ សំដៅទៅលើ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាពឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្រ្តជាតិចំណុចអាទិភាពនៅជំពូកទី៤ នៃគោលនយោបាយ និងសកម្មភាពអាទិភាព២០១៩-២០៣០ គឺត្រូវផលិតធនធានមនុស្ស សម្រាប់ការភិវឌ្ឍជាតិ។ ដូច្នេះមនុស្សត្រូវតែមានចំណេះដឹង និងគុណភាពក្នុងការធ្វើការងារសមស្របទៅតាមបរិបទសង្គមជាតិជាពិសេសអ្នកដែលបានប្រឡងជាប់និទ្ទេសA (រាជរដ្ឋាភិបាល ២០១៩)។

### ២.៦.១ ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ គឺជាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងក្នុងពេលចំពោះមុខទាំងសម្រាប់អនាគត ពិសេសក្នុងពេលដែលកម្ពុជាឈានទៅក្នុងប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០តាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល។ ការអភិវឌ្ឍធនធានមនុស្សក្នុងនិតិកាលទី៦នឹងផ្តោតលើៈ(១)ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា (២)ការបណ្តុះបណ្តាលជំនាញបច្ចេសទេស(៣) ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ និង (៤) ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម (ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៩-២០២៣)។

## ២.៧ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨ - ២០២៣

ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ទៅលើសិស្សានុសិស្សក្នុងការធ្វើកំណែទម្រង់វិស័យអប់រំដោយមានចក្ខុវិស័យទៅលើការកសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែកដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។ វត្ថុបំណងរយៈពេលវែងឆ្ងាយ គឺការអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្តុះបណ្តាលស្មារតីយុវជន

យុវតីកម្ពុជាគ្រប់រូបឱ្យមានមោទនភាពជាតិមានសីលធម៌ល្អ និងគុណធម៌ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសកម្ពុជា និងប្រជាពលរដ្ឋរបស់ខ្លួន (ក្រសួងអប់រំ យុវជន និងកីឡា, វិច្ឆិកា ២០១៨) ។ វត្ថុបំណងចំពោះមុខ គឺធានាថាយុវជន និងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមរដ្ឋធម្មនុញ្ញ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គមគ្រួសារ ភូមិសាស្ត្រ ពូជសាសន៍ សាសនាភាសា យេនឌ័រ និងកាយសម្បទា។ ក្រសួង សង្ឃឹមទុកថានៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួន ពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោកនិងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេស (យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨) ។

ក្នុងន័យនេះការផលិតធនធានមនុស្សសម្រាប់ អភិវឌ្ឍន៍ប្រទេសជាតិពិតជាមានសារៈប្រយោជន៍ ដូចជាសិស្សដែលបាននិទ្ទេសA ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិកន្លមកជាធនធានមួយយ៉ាងសំខាន់ក្នុង ការជួយប្រទេសកម្ពុជាគ្រប់វិស័យទៅតាមតម្រូវការសង្គម។

## ២.៨ ការអភិវឌ្ឍយុវជន ដើម្បីភាពជាពលរដ្ឋមានគុណភាពនៅកម្ពុជា

ដើម្បីអភិវឌ្ឍន៍យុវជននៅកម្ពុជាឱ្យមានភាពជាពលរដ្ឋល្អក្នុងសង្គម ក្រសួងអប់រំ យុវជន និងកីឡាមានយុទ្ធសាស្ត្រគោលទី១គឺកំណែទម្រង់កម្មវិធីយុវជន ក្នុងនោះមានយុទ្ធសាស្ត្ររងសំខាន់មួយចំនួន។ យុទ្ធសាស្ត្ររងទី១ គឺការផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំ និងមានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាព និងសមធម៌។ យុទ្ធសាស្ត្ររងទី២ លើកទឹកចិត្តយុវជនឱ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព។ យុទ្ធសាស្ត្ររងទី៣ អភិវឌ្ឍន៍យុវជនឱ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អចេះរួមរស់ជាមួយគ្នាដោយសន្តិភាព និងសុខុដុមនីយកម្ម។ យុទ្ធសាស្ត្ររងទី៤ បង្កឱកាសឱ្យយុវជនចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានានៅក្នុងការអភិវឌ្ឍសហគមន៍ និងសង្គមជាតិ។ យុទ្ធសាស្ត្ររងទី៥ ពង្រឹងយន្តការគ្រប់គ្រង និងពិនិត្យតាមដានកម្មវិធីអភិវឌ្ឍយុវជន (យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣) ។

ដើម្បីសម្រេចបានយុទ្ធសាស្រ្តខាងលើ ត្រូវមានភាគីពាក់ព័ន្ធចូលរួមក្នុងនោះមានក្រសួងអប់រំ យុវជន និងកីឡាមានតួនាទីនៅក្នុងការផលិត បណ្តុះបណ្តាលធនធានមនុស្សប្រកបដោយវិជ្ជាជីវៈ អភិវឌ្ឍន៍សមត្ថភាពអ្នកធ្វើការងារជាយុវជន សម្របសម្រួលសេវាកម្មអភិវឌ្ឍន៍យុវជន ការបង្កើតកម្មវិធី និងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍យុវជននៅក្នុងក្រសួង ស្ថាប័នទាំងអស់។

## ២.៩ ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ២០៣០

គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរយៈពេល១០ឆ្នាំ ២០១៥-២០២៥ បានដាក់ចេញផែនទីបង្ហាញផ្លូវសម្រាប់លើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែងនិងការលើកកម្ពស់ផលិតភាព។ ក្នុងន័យនេះរាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡាត្រូវការធនធានមនុស្សក្នុងការងារដើម្បីសម្រេចនូវគោលនយោបាយចាំបាច់ត្រូវផលិតធនធានមនុស្សឱ្យសម នឹងគោលនយោបាយដូចជាសិស្សដែលមានសមត្ថភាពក្នុងការប្រឡងទទួលបាននិទ្ទេស A ជាធនធានមានសមត្ថភាពក្នុងការអភិវឌ្ឍជាតិ(គោលដៅអភិវឌ្ឍជាតិប្រកបដោយចីរភាពទី៤ កុម្ភៈ ២០១៩)។

### ២.៩.១ ការកសាងធនធានមនុស្ស

ទោះបីកម្ពុជាមានភាពល្អប្រសើរខាងប្រជាសាស្រ្តក៏ដោយ កម្លាំងពលកម្មភាគច្រើននៅមានកម្រិតអប់រំទាប និងមានកម្រិតជំនាញទាបនៅឡើយ។ ជាលទ្ធផល កម្ពុជាមានការប្រឈមនឹងអន្តរកាលសេដ្ឋកិច្ច ខណៈពេលដែលមានបំណងចាកចេញពីសកម្មភាពដែលត្រូវការជំនាញកម្រិតទាប និងមានតម្លៃទាប និងពង្រីកមូលដ្ឋានឧស្សាហកម្មរបស់ខ្លួនដើម្បីបង្កើនកំណើន បរិយាបន្នដែលឈរលើមូលដ្ឋានទូលំទូលាយ។ ការសិក្សាជាច្រើនបានបង្ហាញពីកង្វះជំនាញ និងកង្វះទីផ្សារការងារពិសេសជំនាញកម្រិតទាបទៅកម្រិតមធ្យម។ កង្វះកម្លាំងពលកម្មដែលបានទទួលការអប់រំ និងមានជំនាញនឹងធ្វើឱ្យកម្ពុជាមានការលំបាក ក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាង ដើម្បីដណ្តើមការវិនិយោគផ្ទាល់ពីបរទេស។ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ទទួលស្គាល់យ៉ាងច្បាស់ពីភាពចាំបាច់ដើម្បីអភិវឌ្ឍន៍ធនធានមនុស្សឱ្យបានសមស្រប។ ជាអាទិភាពកម្ពុជាគួរអភិវឌ្ឍន៍ចំណេះធ្វើ និងធនធានបច្ចេកទេសដែលចាំបាច់សម្រាប់ធ្វើពិពិធកម្មផលិតកម្មរបស់ខ្លួនទៅរក សកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់ និងបង្កើតជំនាញ។ អាហារូបត្ថម្ភ ការអប់រំកុមារតូច និងគុណភាពអប់រំបឋម

សិក្សា និងអប់រំមូលដ្ឋាន ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការអប់រំកម្រិតឧត្តមសិក្សា គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍជំនាញបានថយចុះយ៉ាងគំហុកពី ៨៨,៩ ភាគរយក្នុងឆ្នាំសិក្សា២០១៣-២០១៤ មក៨២,៧ ភាគរយក្នុងឆ្នាំសិក្សា២០១៧-២០១៨។ អត្រានេះមានកម្រិតទាបខ្លាំងនៅតាមបណ្តាលស្រុកភាគពាយ័ព្យ (ប្រមាណ ៧០ភាគរយ)។ ជារឿយៗអត្រាបញ្ចប់ការសិក្សាមានកម្រិតទាបនៅកន្លែងដែលមានអត្រាបោះបង់ការសិក្សាខ្ពស់។ អត្រាបញ្ចប់ការសិក្សាសម្រាប់សិស្សប្រុសមានកម្រិតទាបជាងសិស្សស្រី។ ការវាយតម្លៃលទ្ធផលសិក្សាបង្ហាញថា សិស្សនៅតាមសាលារៀនពុំបានរៀនសូត្រឱ្យបានគ្រប់គ្រាន់នៅឡើយ។

## ២.៩.២ ការអប់រំមធ្យមសិក្សា

ដើម្បីឱ្យសិស្សទទួលបាននិទ្ទេស A នៅមធ្យមសិក្សាទុតិយភូមិកាន់តែកើនឡើងការអប់រំនៅមធ្យមសិក្សាពិតជា មានសារៈសំខាន់ណាស់ក្នុងការបង្រៀននិងរៀននៅមធ្យសិក្សា។ ការចូលរៀននៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិនៅតែមានកម្រិតថេរ ប៉ុន្មានឆ្នាំចុងក្រោយនេះ។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ គឺ៥៩,២ ភាគរយនិង ២៨,៥ ភាគរយ នៅមធ្យមសិក្សាទុតិយភូមិ នាឆ្នាំសិក្សា២០១៧-២០១៨។ រាជរដ្ឋាភិបាលបានបង្កើនចំនួនសាលារៀនមធ្យមសិក្សាបឋមភូមិប៉ុន្មាន ឆ្នាំចុងក្រោយនេះដែលនាំឱ្យចំណុះសិស្សក្នុងមធ្យមសិក្សាបឋមភូមិបានថយចុះពី ៤៨៩ នាក់ ឆ្នាំសិក្សា ២០០៧-២០០៨ មក៣៥៣ នាក់ ឆ្នាំសិក្សា ២០១៧-២០១៨ និងបង្ហាញពីភាពប្រសើរឡើងក្នុងការទទួលបានសេវាអប់រំនៅមធ្យមសិក្សាបឋមភូមិ។ ចំនួនគ្រូនៅមធ្យមសិក្សាបឋមភូមិក៏បានកើនឡើងបន្តិចម្តងៗផងដែរពី ២៣១៥៨ នាក់ឆ្នាំសិក្សា ២០០៧-២០០៨ ដល់ ៣៣១៨១ នាក់ ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ដែលនាំឱ្យផលធៀបសិស្ស គ្រូថយចុះយ៉ាងគំហុកពី ២៧,៥៣ ឆ្នាំសិក្សា ២០០៧-២០០៨ មក ២២,៤ ឆ្នាំសិក្សា ២០១៧-២០១៨។ ដូចគ្នានេះដែរ ចំនួនសាលាមធ្យមសិក្សាទុតិយភូមិក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ចំនួនសិស្សគិតជាមធ្យមក្នុងសាលាមធ្យមសិក្សាទុតិយភូមិគឺ ៨២៦នាក់ក្នុងឆ្នាំសិក្សា២០០៧-២០០៨ ធៀបនឹង ៥៩៤នាក់ក្នុងឆ្នាំសិក្សា២០១៧-១០១៨។ ចំនួនគ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិក៏បានកើនឡើងដែរនាឆ្នាំចុងក្រោយនេះ។ ឆ្នាំសិក្សា ២០០៧-២០០៨ មានគ្រូមធ្យមសិក្សាទុតិយភូមិ៧៦៨៤ នាក់ និងបានកើនដល់ ១៣២២៣នាក់ឆ្នាំសិក្សា២០១៧-២០១៨។ ការកើនឡើងនៃចំនួនគ្រូបង្រៀន នាំឱ្យផលធៀបសិស្ស គ្រូថយមកត្រឹម ២១,៦ ឆ្នាំសិក្សា ២០១៧-២០១៨ ពី៣៨,៩៧ កាលពីឆ្នាំសិក្សា ២០០៧-២០០៨ ដែលជាកត្តាជួយបង្កើនគុណភាពនៃការបង្រៀន និងរៀនដែលធ្វើឱ្យសិស្ស

ប្រឡងជាប់បានច្រើនទទួលបាននិទ្ទេសកាន់តែល្អប្រសើរ (ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ ២០៣០)។

## ២.១០ និន្នន័យសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីឆ្នាំ ២០១៤-២០១៩[1]

ក្រោយពីមានការកែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាពីឆ្នាំ២០១៤មក មានការប្រែប្រួលទៅតាមចំនួនសិស្សដែលទទួលបាននិទ្ទេសA ពីមួយឆ្នាំទៅមួយឆ្នាំដែលជាហេតុធ្វើឱ្យវិស័យអប់រំមានការរីកចម្រើនបានមួយកម្រិតក្នុងការ ប្រឡងសញ្ញាបត្រមធ្យមសិក្សា (វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ១៩ មីនា ២០១៩)។ ក្នុងនោះការប្រឡងត្រូវបានបែងចែកជាពីរគឺមានថ្នាក់វិទ្យាសាស្ត្រ (គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ភាសាខ្មែរ ភាសាបរទេស និងមួយមុខវិជ្ជាទៀតគឺចាប់ឆ្នោតដោយក្រសួងជាអ្នកចេញវិញ្ញាសា)និងវិទ្យាសាស្ត្រសង្គម (ភាសាខ្មែរ គណិតវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា ភាសាបរទេស និងមួយមុខទៀតគឺចាប់ឆ្នោតដោយក្រសួងជាអ្នកចេញវិញ្ញាសា) ហើយចំនួនមុខវិជ្ជា ១០មុខ ដែលសិស្សបានរៀននៅសាលាមកនៅត្រឹមតែ ៧មុខវិជ្ជា សម្រាប់ការប្រឡង។ សម្រាប់និទ្ទេសមាន ៥ កម្រិតគឺ A B C D E (លោក អ៊ឹង ង៉ោហុក ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ២០១៩)។

នៅឆ្នាំ **២០១៤** មានសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ ចំនួន ៨៩,៩២១ នាក់ ស្រី ៤៨,៦០១ នាក់ ប្រឡងជាប់មានចំនួន ៣៣,៩៩៧ នាក់ និងមាននិទ្ទេសដូចខាងក្រោម៖

| A | ស្រី | B | ស្រី | C | ស្រី | D | ស្រី | E | ស្រី |
|---|---|---|---|---|---|---|---|---|---|
| ១១ | ៦ | ២១៩ | ១៣១ | ៩០៨ | ៥០៣ | ១,៨៨៧ | ៩៩១ | ៣០,៩៧២ | ១៤,៤៩២ |

នៅឆ្នាំ **២០១៥** មានសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ ចំនួន ៨៣,៣២៥ នាក់ ស្រី ៤២,៩០៦ នាក់ ប្រឡងជាប់មានចំនួន ៤៦,៥៦០ នាក់ និងមាននិទ្ទេសដូចខាងក្រោម៖

| A | ស្រី | B | ស្រី | C | ស្រី | D | ស្រី | E | ស្រី |
|---|---|---|---|---|---|---|---|---|---|
| ១០៨ | ៥៩ | ១,០៨៥ | ៥៤៧ | ៣,២៩២ | ១,៦៤២ | ៦,០៩៣ | ២,៩៨៣ | ៣៥,៩៨២ | ១៧,៣១០ |

[1] នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ តុលា ២០១៩

នៅឆ្នាំ **២០១៦** មានសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណោះទូទៅមានសិស្សបានប្រឡងចំនួន ៨៩,៦៦១ នាក់ ស្រី ៤៥,៦៥៥ នាក់ ប្រឡងជាប់មានចំនួន ៥៥,៧៥៣ នាក់ និងមាននិទ្ទេសដូចខាងក្រោម៖

| A | ស្រី | B | ស្រី | C | ស្រី | D | ស្រី | E | ស្រី |
|---|---|---|---|---|---|---|---|---|---|
| ៤០៥ | ២០១ | ២,៨០១ | ១,៣៣៥ | ៥,៥៩៥ | ២,៦២៨ | ៨,៨៣៥ | ៤,១៧១ | ៣៨,១១៧ | ១៨,៦១១ |

នៅឆ្នាំ**២០១៧** មានសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណោះទូទៅចំនួន ៩៩,៧២៨ នាក់ ស្រី ៥០,២៧១ នាក់ ប្រឡងជាប់មានចំនួន៦៣,៦៦៨ នាក់ និងមាននិទ្ទេសដូចខាងក្រោម៖

| A | ស្រី | B | ស្រី | C | ស្រី | D | ស្រី | E | ស្រី |
|---|---|---|---|---|---|---|---|---|---|
| ៤២៤ | ២១៣ | ២,៤៦៤ | ១,២១៧ | ៥,០០០ | ២,៤១៦ | ៩,១២៣ | ៤,១៨៦ | ៤៦,៦៥៧ | ២៣,៦២១ |

នៅឆ្នាំ **២០១៨** មានសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណោះទូទៅមានសិស្សបានប្រឡងចំនួន១១៣,៣៦៥ នាក់ ស្រី៥៥,៩៥៥ នាក់ ប្រឡងជាប់មានចំនួន៧៦,០៣៤ នាក់ និងមាននិទ្ទេសដូចខាងក្រោម៖

| A | ស្រី | B | ស្រី | C | ស្រី | D | ស្រី | E | ស្រី |
|---|---|---|---|---|---|---|---|---|---|
| ៤០៨ | ២១៤ | ២២២២ | ១០៩២ | ៦០៤១ | ២៩១៨ | ១៥១៨០ | ៦៦៩២ | ៥២១៨៣ | ២៥៥០១ |

នៅឆ្នាំ **២០១៩** មានសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណោះទូទៅចំនួន ១១៥,២០៦ នាក់ ស្រី៥៥,៤៧៤ នាក់ ប្រឡងជាប់មានចំនួន៧៩,០៥២ នាក់ និងមាននិទ្ទេសដូចខាងក្រោម៖

| A | ស្រី | B | ស្រី | C | ស្រី | D | ស្រី | E | ស្រី |
|---|---|---|---|---|---|---|---|---|---|

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៩៤៣ | ២០០ | ២៤៣០ | ១១២៤ | ៥៨៤៧ | ២៤៣៣ | ១៤១០០ | ៥៦៨៥ | ៥៦២៣២ | ២៥៨៦២ |

តាមទិន្នន័យខាងលើបានបង្ហាញថា ការរៀនសូត្ររបស់សិស្សានុសិស្សបានប្រឡងជាប់ច្រើនពីមួយឆ្នាំទៅមួយឆ្នាំដោយ មានការកើនឡើងចាប់តាំងពីកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិភូមិ ២០១៤ មានប្រមាណ ៣៧.៨០៨ % នៅឆ្នាំ ២០១៥ មាន ៥៥.៨៧៨ % នៅឆ្នាំ ២០១៦ មាន ៦២.១៨២ % នៅឆ្នាំ ២០១៧ មាន ៦៣.៨៤២ % នៅឆ្នាំ ២០១៨ មាន ៦៧.០៧០ % នៅឆ្នាំ ២០១៩ មាន ៦៨.៦២០ % ( Result of Grade 12 National Examination 2010-2019)។ តួលេខសិស្សប្រឡងជាប់និទ្ទេស A មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ឆ្នាំទី១ ប្រឡងដល់ទៅ ២ ដង។ ប្រឡងលើកទី ១ ជាប់បានត្រឹមតែ ២៥,៧២% ទេ។ អញ្ចឹង ចំនួនតិចណាស់បន្ទាប់ពីកំណែទម្រង់ ឱ្យប្រឡងលើកទី ២ ជាប់បាន ១៧,៩២% ហើយជាប់និទ្ទេស A មាន ១១ នាក់។ ឆ្នាំ ២០១៥ ជាប់បាន ៥៥,៨៨% និទ្ទេស A ពេលនោះ គឺមាន ១០៨ នាក់។ ឆ្នាំ ២០១៦ ឡើងមកដល់ ៦២,១៨% និទ្ទេស A ឡើងរហូតដល់ ៤០៥ នាក់។ ឆ្នាំ ២០១៧ បេក្ខជនប្រឡងជាប់ឡើងដល់ ៦៣,៨៤% និទ្ទេស A ឡើងដល់ ៤២៤ នាក់។ ឆ្នាំ ២០១៨ ប្រឡងជាប់ ៦៧,០៧% និទ្ទេស A ធ្លាក់មកនៅ ៤០៨ នាក់។ អញ្ចឹងបានសេចក្តីថា ធ្លាក់និទ្ទេស A។ ដល់ឆ្នាំ ២០១៩ នេះ ប្រឡងជាប់ ៦៨,៦២% និទ្ទេស A ឡើងមកដល់ ៩៤៣ នាក់ (សម្រង់ប្រសាសន៍សម្តេចតេជោ ហ៊ុន សែន ក្នុងពិធីសំណេះសំណាលជាមួយសិស្សនិទ្ទេស A នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា ២០១៨-២០១៩ ៧. តុលា .២០១៩)។

ការកើនឡើងនៃការប្រឡងជាប់របស់សិស្សទាំងអស់មិនថា សិស្សដែលទទួលបាននិទ្ទេស A នោះទេគឺបានបង្ហាញឱ្យឃើញពីការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡាចំពោះការសិក្សារៀនសូត្ររបស់សិស្សនៅទូទាំងប្រទេស។ នេះជាកត្តាជោគជ័យមួយយ៉ាងធំធេងសម្រាប់ប្រទេសកម្ពុជា ក៏ដូចសិស្សានុសិស្សដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរៀនសូត្រ។ សាលារៀនជាថ្នាលបណ្តុះបណ្តាលនូវចំណេះដឹង ឥរិយាបថ ភាពអត់ធ្មត់ក្នុងការរៀនសូត្រដែលផ្តល់នូវទីកន្លែងសម្រាប់ការសិក្សារៀនសូត្រ និងការស្រាវជ្រាវចំពោះសិស្សានុសិស្សគ្រប់រូបដើម្បីក្រេបជញ្ជក់យកចំណេះដឹង ហើយក៏ជាទីកន្លែងដែលផ្តល់ភាពជោគជ័យដល់សិស្សគ្រប់គ្នាផងដែរ។ លោកគ្រូ អ្នកគ្រូ បានបង្រៀនដល់សិស្សសម្រាប់ការប្រឡងទទួលបានលទ្ធផលល្អប្រសើរ។ អ្នកអាណាព្យាបាលសិស្ស និង

ឪពុកម្តាយសិស្សបានខិតខំប្រឹងប្រែងក្នុងការយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូន និង ជំរុញការលើកទឹកចិត្តដល់កូនគាត់ផ្ទាល់ (សម្តេចតេជោ ហ៊ុន សែន Oct .18. 2018 )។

## ២.១១ អំណោយដល់ជ័យលាភីសិស្សនិទ្ទេស A ទុកជាអនុស្សាវរីយ៍ពីរាជរដ្ឋាភិបាល

សម្រាប់សិស្សប្រឡងជាប់និទ្ទេស A សរុប ៤០៨ នាក់ក្នុង១នាក់ៗ ទទួលបានប្រាក់ស្លឹង ដែលជាប្រាក់បោះពុម្ពនៅឆ្នាំ១៥១៤ ក្រោយហ្លួងព្រះស្តេច កន ឈ្មោះស្តេច ស្រីសុគន្ធបទ ហើយដែលរើរាជធានីទៅនៅត្បូងឃ្មុំបច្ចុប្បន្នព្រៃនគរក្នុង ទៅបោះនៅទីនោះ។ ប្រាក់នេះយើងត្រូវយកពីប្រទេសហូឡង់ត្រឡប់មកវិញ ដើម្បីយកមកបោះពុម្ពសារជាថ្មីនៅប្រទេសសិង្ហបុរី ធ្វើពីមាសផង ធ្វើពីប្រាក់(ផង) ដើម្បីឱ្យដឹងថា ខ្មែរយើងមិនមែនទើបនឹងមានប្រាក់កាសចាយនោះទេ គឺមានតាំងពីសម័យមុននឹងទៀត។ ប៉ុន្តែ ប្រាក់ស្លឹងនេះ គឺជាប្រាក់តំណាងមួយនៃដំណាក់កាលមានប្រទេសជាច្រើនចូលមករកស៊ីជាមួយនឹងកម្ពុជា។ តែយើងទៅយកពីប្រទេសហូឡង់ត្រឡប់មកវិញ ដើម្បីឱ្យចៅៗបានដឹងពីប្រវត្តិ។ រីឯថវិកាជូនចៅៗម្នាក់ ២ លានរៀលនិង iPad ១ គ្រឿង។ រួចហើយក៏មានសៀវភៅនេះ ខុសលើសចៅៗឆ្នាំមុនៗ គឺខុសអាហ្នឹង។ នេះគឺបានបញ្ជូនឱ្យបានគ្រប់គ្រូបង្រៀនហើយ ប៉ុន្តែឥឡូវនេះ ជូនចំពោះចៅៗ។ មួយគឺជាសៀវភៅរបស់លោកតា ក្រមង៉ុយ ក្នុងនេះ គ្រាន់តែគាត់ដាក់ "កុំដេកចាំសំណាង កុំភ្លេងភ្លាងចាំបុព្វេ ខំរកកុំទំនេរ រវៀនរិះចេះឱ្យគ្រប់។ បើចង់ស្រាលខ្លួន រៀនសូត្រឱ្យមួន ឱ្យមាំឱ្យស្ទាត់ កុំចេះស្ទាក់ស្ទើរ ល្ងីល្ងើឥតបត់ បើចេះប្រាកដ ប្រាក់រត់តាមហៅ"។នេះជាសៀវភៅរបស់បណ្ឌិត អ៊ូចុង ច្បាប់គោរពមាតាបិតា ឥរិយាបថជីវិតដោយកម្រ។ (https://pressocm.gov.kh/archives/38323 Oct 18,2018) ។

ចំពោះសិស្សដែលទទួលបាននិទ្ទេសA នៅទូទាំងប្រទេសកម្ពុជាក្រៅពីទទួលបានរង្វាន់ពីរាជរដ្ឋាភិបាល ក៏មានរង្វាន់លើកទឹកចិត្តពីសំណាក់រដ្ឋមន្ត្រី អភិបាលនៃគណៈអភិបាលខេត្តមួយចំនួនផ្តល់ជូននូវ ម៉ូតូមួយគ្រឿង កុំព្យូទ័រ និងថវិកាមួយចំនួន។ ជាក់ស្តែងនៅខេត្តកណ្តាល ស្រុកខ្សាច់កណ្តាល សិស្សទទួលបាននិទ្ទេសA ពីរនាក់ទទួលបានម៉ូតូ ១គ្រឿង និងថវិកាមួយចំនួនពីអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (m.freshnewsasia.com Sep 18 2019)។

## ២.១២ ការជូនអំណោយដល់នាយក នាយិកា មកចូលរួមទុកជាអនុស្សាវរីយ៍

នាយក នាយិកា មកចូលរួមក្នុងពិធីចំនួន១៧១នាក់ក្នុង១នាក់ៗ ទទួលបានប្រាក់ស្លឹងមួយសៀវភៅមួយប្រអប់ ថវិកាផ្ទាល់ខ្លួនចំនួន ១ លានរៀល និងថវិកាសម្រាប់សាលានីមួយៗ ចំនួន ៣ លានរៀល។

# ជំពូកទី៣
# វិធីសាស្ត្រនៃការស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៣.១ វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវ គឺជារបៀបឬវិធីនៃការស្រាវជ្រាវទៅតាមបទដ្ឋានវិទ្យាសាស្ត្រដែលមានលក្ខណៈជាសកល ដោយការពិនិត្យពិច័យ និងប្រកបដោយក្រមសីលធម៌ក្នុងការស្រាវជ្រាវ។

យោងតាមប្រធានបទខាងលើនេះ អ្នកសិក្សាស្រាវជ្រាវ បានជ្រើសរើសការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ (Qualitative Research) ដោយធ្វើការប្រមូលព័ត៌មាន របាយការណ៍ពាក់ព័ន្ធនានាព្រមទាំងទស្សនៈ និងទ្រឹស្តីមួយចំនួនដែលទាក់ទងទៅនឹងប្រធានបទ។ ក្រៅពីនេះ អ្នកស្រាវជ្រាវបានផ្តោតជាសំខាន់ទៅលើការចុះប្រមូលទិន្នន័យ និងចុងក្រោយធ្វើការសន្និដ្ឋានបញ្ចប់។

## ៣.២ ភាគសំណាក

ចំពោះទំហំសំណាក អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងសិស្សដែលមាននិទ្ទេសA ជាគោលដៅនៃការសិក្សាស្រាវជ្រាវ ។ ម្យ៉ាងវិញទៀតក្នុងចំណោមសិស្សនិទ្ទេសA កំពុងសិក្សា អ្នកស្រាវជ្រាវបានជ្រើសរើសយកតែ ២១នាក់មកធ្វើការសម្ភាសនិងឱ្យបំពេញកម្រងសំណួរដើម្បីប្រមូលទិន្នន័យ ដោយបានបែងចែកទៅតាមឆ្នាំសិក្សា ដែលពួកគេបានប្រឡងជាប់ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានចំនួន៧នាក់ ស្រី២នាក់ ២០១៧-២០១៨ មានចំនួន៧នាក់ ស្រី៣នាក់ និង២០១៨-២០១៩ មានចំនួន៧នាក់ ស្រី៥នាក់ ហើយមួយឆ្នាំសិក្សាជ្រើសរើសយកតែ ៧នាក់ប៉ុណ្ណោះព្រោះអ្នកសិក្សាយល់ឃើញថាក្នុងចំនួននេះអាចយកធ្វើជាតំណាងឱ្យសិស្សនិទ្ទេស A នៅទូទាំងប្រទេសបាន។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ដើម្បីជាជំនួយក្នុងការប្រមូលទិន្នន័យសម្រាប់ប្រធានបទស្រាវជ្រាវ អ្នកស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍ស្រាវជ្រាវ ជាទម្រង់កម្រងសំណួរ។ រីឯ ការចងក្រងកម្រងសំណួរគឺមានលក្ខណៈជាទម្រង់វាយតម្លៃតាមកម្រិតនៃការអនុវត្តដោយបែងចែកកត្តាដែលជះឥទ្ធិពលដល់ការរៀនសូត្រចំនួន៣គឺៈ កត្តាខ្លួនឯង កត្តាសាលារៀន និងកត្តាគ្រួសារ។ ម្យ៉ាងវិញទៀតកម្រង

សំណួរនេះផ្តោតជាសំខាន់ទៅលើបំណិន និងកត្តាជោគជ័យរបស់សិស្សដែលទទួលបាននិទ្ទេសAក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ហើយបែងចែកជា១៩ វិធីសាស្រ្តតូចៗដើម្បីឱ្យអ្នកបំពេញងាយយល់។

នៅក្នុងកម្រងសំណួរ ត្រូវបានបែងចែកជាបួនផ្នែកធំៗដូចជា៖

ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន ដែលក្នុងផ្នែកនេះមាន៦សំណួរទាក់ទងទៅនឹង អាយុ ភេទ ឆ្នាំប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឯកទេសដែលរៀននៅសាកលវិទ្យាល័យ និងមុខរបរឪពុកម្តាយ។

ផ្នែកទី២ ផ្តោតសំខាន់ទៅលើ កត្តាជោគជ័យសិស្សផ្ទាល់ដែលទទួលបាននិទ្ទេសA ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដែលមាន ៨សំណួរ ហើយសំណួរនិមួយៗនិយាយពីវិធីសាស្រ្តក្នុងការរៀនដោយខ្លួនគាត់ផ្ទាល់។

ផ្នែកទី៣ ផ្តោតសំខាន់ទៅលើ កត្តាសាលារៀន មាន៦ សំណួរដែលសំណួរនិមួយៗនិយាយពីគណៈគ្រប់គ្រងសាលារៀន វិធីសាស្រ្តបង្រៀនរបស់គ្រូ បរិស្ថានសាលា បន្ទប់ស្រាវជ្រាវ បន្ទប់កុំព្យូទ័រ បន្ទប់បណ្ណាល័យ និងបន្ទប់ពិសោធន៍ ដែលជាផ្នែកមួយសំខាន់ក្នុងការរៀនសូត្រ។

ផ្នែកទី៤ ផ្តោតសំខាន់ទៅលើកត្តាគ្រួសារមាន៥សំណួរ ដែលរៀបរាប់ពីការផ្តល់សម្ភារៈដល់ការសិក្សា ការលើកទឹកចិត្ត ការតាមដានការសិក្សារបស់កូន និងទំនាក់ទំនងជាមួយគណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូ។

## ៣.៤ វិធីសាស្រ្តនៃការប្រមូលទិន្នន័យ

ក្រោយពីបានទទួលការប្រឹក្សាយោបល់ ពីសំណាក់សាស្រ្តាចារ្យដឹកនាំទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវ ព្រមទាំងទទួលបានលិខិតអនុញ្ញាត ពីវិទ្យាស្ថានជាតិអប់រំ ក៏ដូចជាការអនុញ្ញាតពី សាកលវិទ្យាល័យភូមិន្ទភ្នំពេញ អ្នកស្រាវជ្រាវបានចុះទៅជួបទំនាក់ទំនងជាមួយលោកប្រធានការិយាល័យសិក្សានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងលោកប្រធានការិយាល័យសិក្សានៃវិទ្យាស្ថានភាសាបរទេស (IFL) ដោយផ្ទាល់ដើម្បីសុំការចូលរួម និងផ្តល់ឱកាសក៏ដូចជាបង្កលក្ខណៈងាយស្រួលក្នុងការប្រគល់ និងប្រមូលកម្រងសំណួរដែលសិស្សបានបំពេញទៅតាមចម្លើយជាក់ស្តែង។

បន្ទាប់ពីមានការយល់ព្រមសហការ ពីលោកប្រធានការិយាល័យសិក្សាទាំងពីររួចមក អ្នកស្រាវជ្រាវបានជួបសម្ភាសជាមួយសិស្សនិទ្ទេសA ហើយបានប្រាប់យ៉ាងច្បាស់ពីគោលបំណងនៃការបំពេញកម្រងសំណួរទៅកាន់សិស្សនិទ្ទេសA ព្រមទាំងស្នើសុំពួកគាត់ ចែក

រំលែកបទពិសោធន៍ ដោយស្ម័គ្រចិត្ត ជៀសវាងការជះឥទ្ធិពលមកដល់ចម្លើយ និងការវិភាគទិន្នន័យនាពេលក្រោយ។

នៅពេលប្រមូលកម្រងសំណួរត្រឡប់មកវិញ អ្នកសិក្សាស្រាវជ្រាវបានធ្វើការត្រួតពិនិត្យ និងស្នើសុំឱ្យភាគសំណាកជួយបំពេញបន្ថែមចំពោះចំណុចខ្វះចន្លោះទាំងឡាយដែលមាន ដើម្បីជៀសវាងការខ្វះខាត និងការបាត់បង់ទិន្នន័យ ដែលជាការប៉ះពាល់ដល់ការវិភាគនិងបកស្រាយទិន្នន័យនៅពេលបន្ទាប់។ ជាចុងក្រោយ អ្នកស្រាវជ្រាវ ក៏បានថ្លែងអំណរគុណទៅកាន់ភាគសំណាកនិងសាលកវិទ្យាល័យភូមិន្ទភ្នំពេញ ព្រមទាំងលោកប្រធានការិយាល័យសិក្សាទាំងពីរ ដែលបានរួមចំណែកយ៉ាងសកម្ម ឱ្យអ្នកស្រាវជ្រាវប្រមូលបានទិន្នន័យទៅតាមកាលកំណត់មួយរយភាគរយ។

## ៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ

ក្នុងការវិភាគទិន្នន័យដែលប្រមូលបាន អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ គឺដើម្បីចង្អុលបង្ហាញពីចំនួនប្រេកង់ និងភាគរយនៃការយល់ឃើញរបស់អ្នកចូលរួមផ្តល់ចម្លើយ ទៅលើចំណុចលម្អិតនីមួយៗដែលមាននៅក្នុងកម្រងសំណួរស្ទាបស្ទង់មតិទាំងបួនផ្នែកនៃកម្រងសំណួរ អ្នកស្រាវជ្រាវត្រូវផ្តុំគំនិត ទៅតាមក្រុមសំណួរនិមួយៗ បន្ទាប់មកបកស្រាយគំនិត និងសង់ក្រាហ្វិកតាមកម្មវិធី Ms. Excel 2010។

## ៣.៦ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

ក្រមសីលធមិមានសារៈសំខាន់ណាស់សម្រាប់ការស្រាវជ្រាវ ពីព្រោះរាល់សំណួរ និងការសម្ភាសគឺអ្នកស្រាវជ្រាវមិនធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អ្នកចូលរួមនោះទេ។ ដើម្បីរក្សាក្រមសីលធមិ អ្នកស្រាវជ្រាវបានណែនាំខ្លួន ប្រាប់ពីគោលបំណង រយៈពេលឆ្លើយសំណួរ និងការសុំសម្ភាស ការសន្យាលើលក្ខខណ្ឌមួយចំនួន ដូចជាការរក្សាការសម្ងាត់ជូនអ្នកចូរួម ហើយព័ត៌មានដែលទទួលបាននឹងមិនត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀតឡើយ។ រាល់ការសម្ភាសត្រូវបានសុំការអនុញ្ញាត និងមានការឯកភាពពីអ្នកដែលឆ្លើយតបសម្ភាសន៍។ ក្នុងដំណើរការសម្ភាសន៍គឺបានជ្រើសរើសកន្លែងដែលមិនមានការរំខានពីមជ្ឈដ្ឋានខាងក្រៅ។ អ្នកសម្ភាសន៍បានស្លៀកពាក់សម្លៀកបំពាក់សមរម្យ ទឹកមុខស្រស់ស្រាយ ញញឹមរួសរាយ និងបង្ហាញនូវភាពស្និតស្នាល សម្តីទន់ភ្លន់ និងអង្គុយតាមបែបបទនៃគោលការណ៍អ្នកសម្ភាសន៍។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

## ៤.១ ព័ត៌មានទូទៅស្ដីពីការស្រាវជ្រាវ

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញ បកស្រាយ និងពិភាក្សាលទ្ធផលនៃការវិភាគទិន្ន ន័យបានមកពីការបំពេញកម្រងសំណួរ និងការសម្ភាសសិស្សទទួលបាននិទ្ទេស A ចំនួន២១នាក់ ក្នុងនោះស្រីចំនួន៩នាក់ ដើម្បីស្វែងយល់ពីកត្តាជោគជ័យ ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ដែលបច្ចុប្បន្នពួកគេកំពុងសិក្សារៀនសូត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

## ៤.២ លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.២.១ ព័ត៌មានទូទៅរបស់សំណាក

*តារាងទី១: ចំនួនសិស្ស និងភេទ*

| **ចំនួនសិស្ស និងភេទ សរុប** | | |
|---|---|---|
| សិស្ស/ ភេទ | ចំនួន | ភាគរយ |
| ប្រុស | ១២នាក់ | ៥៧ |
| ស្រី | ៩នាក់ | ៤៣ |
| សរុប | ២១នាក់ | ១០០ |

### ៤.២.២ មុខរបរឪពុក ម្ដាយសិស្សនិទ្ទេសA

នៅក្នុងចំណោមមុខរបរឪពុកម្ដាយសិស្សនិទ្ទេស A ទាំង២១នាក់មានមុខរបរផ្សេងៗគ្នា ក្នុងនោះរួមមាន៖ កសិករ មន្ត្រីរាជការ អ្នករកស៊ី អ្នកធ្វើការអង្គការក្រៅរដ្ឋាភិបាល រោងចក្រកាត់ដេរ និងមេផ្ទះជាដើម។

*ក្រាហ្វិកទី១: មុខរបរឪពុកម្ដាយសិស្សនិទ្ទេសA*




មុខរបរឪពុកម្តាយរបស់សិស្សទទួលបាននិទ្ទេស A ដូចបង្ហាញក្នុងក្រាហ្វិកខាងលើបានបញ្ជាក់ថា ១១នាក់ស្មើនឹង៥២,៣៨% ឪពុកម្តាយមានមុខរបរជាកសិករ ៩នាក់ស្មើនឹង ៤២.៨៦% ឪពុកឬម្តាយមានមុខរបរជាមន្ត្រីរាជការ ៧នាក់ស្មើនឹង៣៣.៣៣% ឪពុកឬម្តាយមានមុខរបរជាអ្នករកស៊ី និង១នាក់ស្មើនឹង៤.៧៦%មានឪពុកធ្វើការនៅអង្គការក្រៅរដ្ឋាភិបាល(NGO)។ ចំពោះម្តាយជាអ្នកធ្វើការរោងចក្រកាត់ដេរមានចំនួន១នាក់ស្មើនឹង៤.៧៦%និងម្តាយជាស្ត្រីមេផ្ទះមានចំនួន២នាក់ស្មើនឹង៩.៥២%។ ក្នុងចំណោមមុខរបរ ឪពុកម្តាយ សិស្សនិទ្ទេស A ទាំង២១នាក់ ឪពុកម្តាយជាកសិករជារោងចក្រកាត់ដេរឬជាមេផ្ទះមានចំនួនច្រើនជាងគេរហូតដល់១៤នាក់ គឺស្មើនឹង៦៦.៦៧%។

លទ្ធផលនេះសរបញ្ជាក់ឱ្យឃើញថា កត្តាជីវភាពគ្រួសារមិនជះឥទ្ធិពលដល់ភាពរៀនពូកែរបស់សិស្សនោះទេឬអាចនិយាយបានម្យ៉ាងទៀតថាការសិក្សា គឺមិនអាស្រ័យទៅលើកត្តាជីវភាពគ្រួសារមានឬក្រនោះដែរ។ លទ្ធផលនេះស្របទៅនឹងប្រសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចែកសញ្ញាបត្រនានាថា ទ្រព្យសម្បត្តិអាចមានភាពខុសគ្នារវាងអ្នកមាន និងអ្នកក្រ ប៉ុន្តែគម្លាតខួរក្បាលគឺគ្មានភាពខុសគ្នា រវាងអ្នកមាននិងអ្នកក្រនោះទេ។

## ៤.៣ កត្តាផ្ទាល់ខ្លួន

### ៤.៣.១ កត្តាផ្ទាល់ខ្លួន ដែលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបាននិទ្ទេសA

*ក្រាហ្វិកទី២ ៖ កត្តាផ្ទាល់ខ្លួន*




តាមក្រាហ្វិកខាងលើបង្ហាញថា កត្តាដែលធ្វើឱ្យសិស្សទទួលបាននិទ្ទេសAក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិគឺកត្តាផ្ទាល់ខ្លួន ពោលគឺសិស្សត្រូវខិតខំរៀនគួរ និងស្រាវជ្រាវលំហាត់បន្ថែមមានអត្រាខ្ពស់ជាងគេរហូតដល់៤៨%។ បន្ទាប់មក ការបែងចែកកាលវិភាគរៀនខ្លួនឯងមាន១៩.០៤%។ ការកំណត់គោលដៅរៀនសូត្រច្បាស់លាស់មាន ១៤% និងមានចំណេះដឹងមូលដ្ឋានគ្រឹះពីថ្នាក់ក្រោម និងការលើកទឹកចិត្តពីគ្រួសារ លោកគ្រូ អ្នកគ្រូ និងមិត្តភក្តិមាន៩.៥២%។

ទិន្នន័យនេះបញ្ជាក់ថា ភាគច្រើននៃការទទួលបានជោគជ័យល្អក្នុងការសិក្សារបស់សិស្សានុសិស្ស គឺការខិតខំប្រឹងប្រែងរៀនគួរនិងការស្រាវជ្រាវលំហាត់ថ្មីៗលើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យាជាដើមដោយខ្លួនឯង។ លទ្ធផលនេះក៏ស្របទៅនឹងស្ថានភាពជាក់ស្តែងដែលអ្នកស្រាវជ្រាវបានសង្កេតឃើញលើការសិក្សារបស់សិស្សរាល់ថ្ងៃ គឺថា បើការសិក្សាតែនៅក្នុងសាលាមិនគ្រប់គ្រាន់សម្រាប់សិស្សនោះទេ។ ដូចនេះហើយទើបសិស្សត្រូវរៀនគួរក្រៅម៉ោងបន្ថែមទៀត។ ម្យ៉ាងវិញទៀតសិស្សក៏ត្រូវការស្រាវជ្រាវមេរៀន រឺលំហាត់ថ្មីៗតាមរយៈ Internet សៀវភៅកំណែ ឯកសារនានា រឺតាមរយៈគ្រូបង្រៀនដើម្បី

បង្កើនសមត្ថភាពក្នុងការប្រឡង។ ចំពោះសិស្សខ្លះទៀតយល់ថាការបែងចែកកាលវិភាគរៀនដោយខ្លួនឯងក៏ជួយក្នុងការសិក្សាបានល្អដែរ ព្រោះមានពេលវេលាគ្រប់គ្រាន់ មានភាពស្ងប់ស្ងាត់ អារម្មណ៍ស្រស់ថ្លាក្នុងការកំណត់ម៉ោងសិក្សាទៅតាមមុខវិជ្ជាដែលខ្លួនបានកំណត់ថាម៉ោងណាត្រូវរៀនមុខវិជ្ជាអ្វី។ ជាទូទៅសិស្សមួយចំនួនមិនបានគិតពីការបែងចែកម៉ោងរៀននោះទេ។ រីឯកត្តាកំណត់គោលដៅច្បាស់លាស់ក៏ជាផ្នែកមួយ សម្រាប់សិស្សស្វែងរកទិសដៅពិតប្រាកដក្នុងការប្រឡងដើម្បីទទួលបាននិទ្ទេសល្អ ថាតើគាត់ត្រូវចាប់ផ្តើមពីពេលណា ដើម្បីឱ្យការសិក្សាទទួលបានជោគជ័យ។ ចំពោះកត្តាមានមូលដ្ឋានគ្រឹះពីថ្នាក់ក្រោមក៏មានសារសំខាន់ណាស់ដែរពីព្រោះថា សិស្សទាំងអស់ត្រូវរៀនតាមលំដាប់ថ្នាក់ពីតូចទៅធំហើយមេរៀនតែងតែមានទំនាក់ទំនងគ្នាពីមួយកម្រិតទៅមួយកម្រិត តួយ៉ាងកម្មវិធីសិក្សានាពេលបច្ចុប្បន្ននេះត្រូវមានទំនាក់ទំនងគ្នាពីមួយកម្រិតទៅមួយកម្រិត ហេតុនេះហើយសិស្សត្រូវមានមូលដ្ឋានគ្រឹះពីថ្នាក់ក្រោមជាចាំបាច់។ សម្រាប់កត្តាលើកទឹកចិត្តពិតជាមានសារៈសំខាន់ក្នុងការជំរុញឱ្យការរៀនសូត្ររីការប្រឡងទទួលបានជោគជ័យពីព្រោះគ្រួសារនិមួយៗតែងតែផ្តល់នូវកាស្រឡាញ់ លើកទឹកចិត្តចំពោះកូនៗក្នុងការសិក្សារៀនសូត្រ។

### ៤.៣.២ វិធីសាស្ត្រអានសៀវភៅឱ្យយល់ និងចាំបានល្អ

ក្រាហ្វិកទី៣៖ វិធីសាស្ត្រអានសៀវភៅ



ក្រាបខាងលើបានបង្ហាញថា វិធីសាស្ត្រអានសៀវភៅតាមរយៈការកំណត់ពេលវេលាច្បាស់លាស់ក្នុងការអានគឺមានអត្រាភាគរយខ្ពស់ជាងគេស្មើនឹង២៨.៥៧%។ បន្ទាប់មកគឺការសង្ខេបខ្លឹមសារមេរៀនមាន២៣.៨០% ចំណងចំណូលចិត្តអានមាន១៩.០៤% និងសម្រាក់ភ្នែកមាន១៩.០៤% និងទីកន្លែងមានអត្រាទាបជាងគេគឺ៩.៥២%។

បើយើងអង្កេតទៅលើវិធីសាស្ត្រនៃការអានសៀវភៅ ភាគច្រើនសិស្សត្រូវការពេលវេលា ដែលល្អបំផុតសម្រាប់អានសៀវភៅ និងទន្ទេញមេរៀនឲ្យឆាប់ចាំ គឺនៅពេលភ្លឺស្រាងៗ (ជិតព្រឹក) ព្រោះរាងកាយមានថាមពលពេញលេញ មានអារម្មណ៍ស្រស់ថ្លា ខួរក្បាលឆាប់ចាប់ឬទទួលបានច្រើន ដោយសាររាងកាយរបស់បានសម្រាកគ្រប់គ្រាន់នៅពេលយប់។ ចំណែកសិស្សមួយចំនួនត្រូវសង្ខេបខ្លឹមសារមេរៀន នៅពេលអានមិនប្រាកដថា អាចអានចាំបានទាំងអស់នោះទេ។ ដូច្នេះ ពេលអានដល់ចំណុចដែលគិតថាសំខាន់ ត្រូវគូសចំណាំ ឬកត់ត្រាទុកក្នុងកូនសៀវភៅដៃ ដើម្បីរម្លឹកឡើងវិញ។ វិធីសាស្ត្រនេះ គឺជាគន្លឹះមួយដ៏សំខាន់ដែលអ្នកអានសៀវភៅមិនដែលមើលរំលងឡើយ។ សម្រាប់ទីកន្លែង ចំពោះការអានវិញគឺសិស្សមិនសូវខ្វល់ខ្វាយទេព្រោះពួកគាត់គិតថាកន្លែងណាក៏អាចអានបានដែរឱ្យតែពួកគាត់ចង់អាន។ នេះសរបញ្ជាក់ឱ្យឃើញថា វិធីសាស្ត្រនៃការអានមិនអាស្រ័យលើទីកន្លែងនោះទេ។

### ៤.៣.៣ ការចំណាយពេលរៀនដោយខ្លួនឯង និងរៀនគួរជាមួយគ្រូ

*ក្រាហ្វិកទី៤៖ ចំនួនម៉ោងរៀនដោយខ្លួនឯង និងរៀនគួរជាមួយគ្រូ*



ក្រាហ្វិកខាងលើ បានបង្ហាញឱ្យឃើញថាសិស្សចំណាយពេលរៀនដោយខ្លួនឯង២ម៉ោងក្នុងមួយថ្ងៃមានចំនួន២៤% ៣ម៉ោងក្នុងមួយថ្ងៃមានចំនួន២៤% ៤ម៉ោងក្នុងមួយថ្ងៃមានចំនួន៣៨% និង៥ម៉ោងក្នុងមួយថ្ងៃមានចំនួន១៤%។ ក្នុងក្រាហ្វិកនេះ ក៏បង្ហាញឱ្យឃើញផងដែរថាសិស្សដែលចំណាយពេលរៀនគួរ៤ម៉ោងក្នុងមួយថ្ងៃមានចំនួន១៩% ៥ម៉ោងក្នុងមួយថ្ងៃមានចំនួន៤៧.៦១% ៦ម៉ោងក្នុងមួយថ្ងៃមានចំនួន១៤.២៨% ៧ម៉ោងក្នុងមួយថ្ងៃមានចំនួន១៤.២៨% និង៨ម៉ោងក្នុងមួយថ្ងៃមានចំនួន៤.៧៦%។ នេះបង្ហាញឱ្យឃើញថាសិស្សដែលទទួលបាននិទ្ទេស A ភាគច្រើនគឺចំណាយពេលរៀនខ្លួនឯង៤ម៉ោងឬចំណាយពេលរៀនគួរ៥ម៉ោងក្នុងមួយថ្ងៃ។ ពេលវេលានេះគឺសមស្របទៅនឹងពេលវេលាក្នុងការរៀននៅផ្ទះឬរៀនគួរព្រោះថាការសិក្សានៅសាលាបានប្រើប្រាស់ពេលវេលាច្រើនទៅហើយ ដូចនេះមកផ្ទះចំណាយពេលត្រឹមតែ៤ម៉ោង ឬរៀនគួរចំណាយពេលត្រឹម៥ម៉ោងក្នុងមួយថ្ងៃ វាជាការល្អបំផុតសម្រាប់សិស្សក្នុងការធ្វើលំហាត់ ការស្រាវជ្រាវ ឬការអានសៀវភៅ ហើយពេលវេលានេះមិនប៉ះពាល់ដល់សុខភាព។ ប៉ុន្តែមានសិស្សនិទ្ទេស A ខ្លះយល់ថា២ រឺ ៣ម៉ោងវាគ្រប់គ្រាន់ក្នុងការរៀនសូត្រ ពោលគឺពួកគាត់ធ្វើលំហាត់ត្រួសៗ ហើយសង្ខេបមេរៀនដែលបានរៀនពីសាលាដូចនេះចំពោះពេលវេលានេះ ហាក់បីដូចជាតិចសម្រាប់ការសិក្សានៅផ្ទះ។ បើយើងពិនិត្យមើលទៅលើពេលវេលា ៥ម៉ោង វិញឃើញថាជាពេលដែលច្រើនបន្តិចសម្រាប់ការសិក្សានៅផ្ទះ ដោយសំអាងថាការសិក្សានៅសាលាមានរយៈពេលច្រើនហើយ តែមករៀននៅផ្ទះច្រើនទៀតវាមិនល្អចំពោះសុខភាពនោះទេ ហើយអាចធ្វើឱ្យអស់កម្លាំងរៀនមិនបានចាំល្អនោះដែរ។

### ៤.៣.៤ ប្រសិទ្ធភាពរៀននៅសាលា និងប្រសិទ្ធភាពរៀនផ្ទាល់ខ្លួន

#### ៤.៣.៤.១ ប្រសិទ្ធភាពរៀននៅសាលា

ក្រាហ្វិកទី៥៖ *ប្រសិទ្ធភាពរៀននៅសាលា*




បើផ្ដោតទៅលើប្រសិទ្ធភាពរៀននៅសាលាទាំងមូល ជារួមសិស្សយល់ថារៀននៅសាលាគឺល្អជាងការរៀននៅទីកន្លែងផ្សេង ព្រោះថាមានគ្រូជាអ្នកណែនាំបង្ហាញផ្លូវក្នុងការធ្វើលំហាត់ ពន្យល់ពីគន្លឹះមេរៀន មានក្រុមសិក្សា មានឯកសារស្រាវជ្រាវពីបណ្ណាល័យ មានបន្ទប់ពិសោធន៍ មានបន្ទប់កុំព្យូទ័រ លោកគ្រូ អ្នកគ្រូបានពន្យល់គ្រប់ចំណុចនៃមេរៀនជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ ហើយគណៈគ្រប់គ្រងសាលាជួយជំរុញលើកទឹកចិត្តឱ្យខិតខំរៀនតាមដានការសិក្សានិងយកចិត្តទុកដាក់ក្នុងការប្រឡង។ ចំពោះមិត្តភក្តិយើងអាចពិភាក្សាគ្នាបង្កើតការក្លឹបសិក្សាជួយគ្នាទៅវិញទៅមក ដែលមានគ្រូជាអ្នកជួយ និងផ្ដល់ភាពជឿជាក់ក្នុងការរៀនសូត្រ។ ម្យ៉ាងទៀតនៅសាលារៀនមានបរិស្ថានល្អ អាចទាក់ទាញសិស្សឱ្យចង់មករៀន។ ឯសិស្សមួយចំនួននៅតែគិតថាការរៀននៅសាលាមានកម្រិតត្រឹមតែល្អបង្គួរទេដោយពួកគាត់គិតថា រៀននៅសាលាមានតែមេរៀន អត់មានធ្វើលំហាត់ គ្មានម៉ោងគ្រប់គ្រាន់ក្នុងការបង្រៀន គ្រូពន្យល់ពាក្យគន្លឹះមេរៀន និងលំហាត់តែមិនបានអនុវត្ត គ្មានបន្ទប់សម្រាប់ស្រាវ ជ្រាវ ម៉ោងរៀននៅសាលាមិនគ្រប់គ្រាន់ ក្នុងបន្ទប់មានសិស្សច្រើនពិបាកក្នុងការសួរលោកគ្រូអ្នកគ្រូ ពិបាកស្ដាប់គ្រូពន្យល់មេរៀន រឺលំហាត់។ បន្ថែមពីនេះទៅទៀតក៏មានសិស្សមួយភាគតូចបានយល់ថា ការរៀននៅសាលាមានកម្រិតត្រឹមតែមធ្យមទេ ដោយមានគ្រូខ្លះបង្ខិតបង្ខំឱ្យរៀនគួរ និងបង្រៀនម៉ោងរដ្ឋមិនបានដិតដល់។ ពេលវេលាមិនគ្រប់គ្រាន់ ពន្យល់មិនបានល្អ ការផ្ដល់ចំណេះដឹងទូទៅច្រើន មិនមានលក្ខណៈច្បាស់ទាក់ទង និងមេរៀន។

ដើម្បីកែលម្អគុណភាពសាលារៀនឱ្យមានប្រសិទ្ធភាព ត្រូវពង្រឹងគុណភាពការគ្រប់គ្រងការបង្រៀន និងរៀនជាមុនសិន។

### ៤.៣.៤.២ ប្រសិទ្ធភាពរៀនផ្ទាល់ខ្លួន

ក្រាហ្វិកទី៦៖ *ប្រសិទ្ធភាពរៀនផ្ទាល់ខ្លួន*




បើផ្តោតទៅលើប្រសិទ្ធភាពរៀនផ្ទាល់ខ្លួនទាំងមូល ជារួមសិស្សយល់ថាល្អមានអត្រាខ្ពស់ជាងដាច់ស្មើនឹង ៨៥.៧១% និងអត្រាល្អបង្គួរមាន ៩.៥៣% ។ ចំណែកសិស្សដែលគិតថាមានកម្រិតមធ្យមមាន ៤.៧៦% និងខ្សោយ 0%។

ស្ទើរតែទាំងអស់ នៃសិស្សយល់ថាការរៀនផ្ទាល់ខ្លួនមានប្រសិទ្ធភាពល្អ ពីព្រោះឆាប់យល់ មានពេលវេលាច្រើនក្នុងការអនុវត្តលំហាត់ និងអានសៀវភៅ បំពេញនូវចំណុចខ្វះខាតពីសាលានិងបានបង្កើនចំណេះដឹងបន្ថែម ពង្រីកចំណេះដឹងនិងទទួលបានព័ត៌មានថ្មីក្នុងការស្រាវជ្រាវ ឆាប់យល់និងចាំបានយូរ បើយើងដឹងពីចំណុចខ្វះខាត និងដឹងពីចំណុចខ្លាំងក្នុងការធ្វើលំហាត់ ដឹងពីសមត្ថភាពថាអ្វីដែលយើងមិនចេះ ហើយសួរគ្រូបន្ថែម មានពេលធ្វើលំហាត់និងអានមេរៀនដែលបានរៀនពីសាលា មានអារម្មណ៍ស្ងប់មិនមានការរំខានពីមជ្ឈដ្ឋានខាងក្រៅហើយអនុវត្តលំហាត់បានស្ទាត់ និងចាំមេរៀនបានល្អជាងនៅក្នុងសាលា។ ដឹងពីសមត្ថភាពផ្ទាល់ខ្លួនថាខ្សោយអ្វី ហើយចេះអ្វី បន្ទាប់មកត្រូវបំពេញបន្ថែមនូវអ្វីដែលខ្វះមានពេលវេលាគ្រប់គ្រាន់ក្នុងការស្រាវជ្រាវលំហាត់ និងរំលឹកឡើងវិញនូវមេរៀនដែលបានរៀនពីសាលា អាចវាស់សមត្ថភាពខ្លួនឯងបានក្នុងមេរៀននិមួយៗ ហើយសម្រេចគោលបំណង

បានច្បាស់លាស់ក្នុងការប្រឡង។ ចំពោះសិស្សមួយចំនួនបានគិតថាការរៀនផ្ទាល់ខ្លួនបានត្រឹមកម្រិតល្អបង្គួរដោយសារពួកគេយល់ថា មានពេលតិចតួចក្នុងការរៀន ដោយសារអស់កម្លាំងពីការរៀនគួរ និងរៀននៅសាលារដ្ឋ មានគំនិតតែមួយ ហើយពិបាកសួរគេ បើឆ្ងល់នូវចំណុចណាមួយ។ បន្ថែមពីនេះក៏មានសិស្សមួយភាគតូចបានយល់ថា ការរៀនផ្ទាល់ខ្លួនមានកម្រិតត្រឹមមធ្យមដោយមានហេតុផលថា ជួបការលំបាកក្នុងការដោះស្រាយលំហាត់ មិនអាចសួរគ្រូបានភ្លាមធ្វើឱ្យមានអារម្មណ៍ពិបាកចិត្តលែងចង់រៀន ។

តាមការបង្ហាញពីការស្រាវជ្រាវខាងលើរវាងប្រសិទ្ធភាពនៃការរៀននៅសាលា និងការរៀនដោយខ្លួនឯងមានការទំនាក់ទំនងគ្នាទៅវិញទៅមក។ ចំពោះកម្រិតប្រសិទ្ធ (ល្អ) នៃការរៀននៅសាលាមានសិស្សស្មើនឹង ៨២.៨៥% ចំពោះកម្រិតប្រសិទ្ធភាព (ល្អ) នៃការរៀនដោយផ្ទាល់ខ្លួនមានសិស្ស ស្មើនឹង ៨៥.៧១% ។ ក្នុងន័យនេះបានបង្ហាញថា ការរៀនសូត្រដោយខ្លួនឯងមានប្រសិទ្ធភាពជាងនៅសាលា។

## ៤.៤ កត្តាសាលារៀន

សាលារៀនគឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអប់រំ ផ្តល់នូវចំណេះដឹង សមត្ថភាពជំនាញ និងអាកប្បកិរិយាល្អសម្រាប់សិស្សរស់នៅក្នុងសង្គម។ ទទ្ទឹមនឹងនេះដែរសិស្សដែលទទួលបាននិទ្ទេសល្អតែងតែជួយលើកមុខមាត់សាលាឱ្យមានកិត្តិយសល្បីនៅ ក្នុងសង្គមតាមរយៈការប្រឡងបាក់ឌុបជាប់បានច្រើនជាងគេពិសេសនោះគឺ សិស្សដែលទទួលបាននិទ្ទេសA ។ជាមួយគ្នានេះដែរថាតើសាលារៀនបានផ្តល់អ្វីខ្លះសម្រាប់ប្អូនៗដែលទទួលបាននិទ្ទេស A គឺត្រូវបានបរិយាយដូចខាងក្រោម៖

### ៤.៤.១ គណៈគ្រប់គ្រងសាលា

**ក្រាហ្វិកទី៧៖ គណៈគ្រប់គ្រងសាលា**




តាមក្រាហ្វិកខាងលើបានបង្ហាញថា គណៈគ្រប់គ្រងសាលាបានយកចិត្តទុកដាក់ចំពោះសិស្សមានអត្រាខ្ពស់ជាងគេគឺ ៨៥.៧១% ឯការយកចិត្តទុកដាក់ខ្លះៗមានតែ៩.៥២% និងមិនយកចិត្តទុកដាក់មាន ៤.៧៦%។

តាមទិន្នន័យក្នុងក្រាហ្វិកនេះបានបញ្ជាក់ថា ភាគច្រើនគណៈគ្រប់គ្រងសាលាបានយកចិត្តទុកដាក់ចំពោះសិស្សក្នុងការរៀនសូត្រជាពិសេសសិស្សដែលរៀននៅថ្នាក់ទី១២ ដែលជាសិស្សត្រូវប្រឡងដោយគណៈគ្រប់គ្រង ផ្ដល់កម្លាំងចិត្ត និងលើកទឹកចិត្តមុនពេលប្រឡង ព្រមទាំងណែនាំឱ្យធ្វើជាសិស្សល្អ ផ្ដល់កិត្តិយសជាសិស្សល្អនៅក្នុងវិទ្យាល័យ និងឆ្លាក់ឈ្មោះទុកជាគំរូ ផ្ដល់ជាប្រាក់រង្វាន់ចំពោះការខិតខំប្រឹងប្រែងក្នុងការប្រឡងទទួលបាននិទ្ទេសA ផ្ដល់ជាសម្ភារសិក្សាមានសៀវភៅ ប៊ិច និងកាតាប។ល។ ផ្ដល់កន្លែងស្នាក់នៅក្នុងសាលាដើម្បីរៀនអប់រំ ឱ្យធ្វើជាសិស្សល្អ កូនល្អ ដើម្បីជាប្រយោជន៍សម្រាប់ប្រទេសជាតិ ផ្ដល់ឱកាសក្នុងការរៀនបំប៉ននិងរៀបចំការប្រឡងសាកល្បង ដើម្បីវាស់សមត្ថភាពមុនពេលប្រឡងថ្នាក់ជាតិ ចង្អុលបង្ហាញពីការដាក់អាហារូបរណ៍ទៅសិក្សាបន្តនៅសាកលវិទ្យាល័យនានា។ ប៉ុន្តែក៏មានគណៈគ្រប់គ្រងសាលាមួយចំនួនបានយកចិត្តទុកដាក់តិចតួចចំពោះការសិក្សា បើតាមទិន្នន័យខាងលើ ដោយសារពួកគាត់គិតថាសិស្សអាចរៀន និងប្រឡលជាប់ដោយខ្លួនគាត់ ហើយដូច្នេះមិនបាច់ជួយគាត់ទេ។ បន្ថែមពីនេះទៅទៀតមានគណៈគ្រប់គ្រងសាលាតិចបំផុតមិនបានយកចិត្តទុកដាក់ចំពោះការសិក្សាក៏ដូចជាការប្រឡងរបស់សិស្ស ដោយគាត់គិតថាការងារប្រឡងនៅថ្នាក់ជាតិ សិស្សអាចធ្វើបាន។

យោងតាមអង្គការ Unicef ប្រចាំនៅកម្ពុជា គណៈគ្រប់គ្រងសាលាត្រូវចេះស្វែងយល់ស្តាប់ និងរៀនសូត្រពីលោកគ្រូអ្នកគ្រូ និងបង្កើតនូវស្មារតីផ្ទៃក្នុងសាលារៀនល្អ បង្កើតសាមគ្គីភាព និងលើកទឹកចិត្តសិស្សក្នុងការសិក្សាដោយបង្កើតនូវកម្មវិធីរៀនបំប៉ន និងក្លឹបសិក្សា។ គណៈគ្រប់គ្រងសាលា គឺជាអ្នកនាំមុខគេក្នុងការរៀន និងបង្រៀន។ ទោះបីក្នុងការសិក្សាស្រាវជ្រាវនេះមានគណៈគ្រប់គ្រងមួយចំនួនតូចមិនបានយកចិត្តទុកដាក់ទៅលើសិស្សក្តីក៏មិនមានបញ្ហាដល់ការសិក្សាដែរ។

### ៤.៤.២ វិធីសាស្រ្តបង្រៀន

*ក្រាហ្វិក៨ ៖ វិធីសាស្រ្តបង្រៀន*




ផ្អែកតាមក្រាហ្វិកខាងលើបង្ហាញថា ស្ទើរតែទាំងស្រុងសិស្សបានពេញចិត្តចំពោះវិធីសាស្រ្តបង្រៀន ៩០.៤៧%។

តាមទិន្នន័យនេះយើងអង្កេតឃើញថា ការបង្រៀនរបស់គ្រូពិតជាមានវិធីសាស្រ្តល្អក្នុងការផ្ទេរចំណេះដឹងដោយពួកគាត់បានប្រាប់ពីគន្លឹះនៃលំហាត់ ប្រាប់ពីវិធីសាស្រ្តរៀន និងរបៀបធ្វើលំហាត់ចំពោះមុខវិជ្ជាវិទ្យាសាស្រ្ត ចែកក្រុមពិភាក្សាគ្រប់ម៉ោងសិក្សានៅសាលា ដាក់លំហាត់ឱ្យធ្វើនៅផ្ទះ ឱ្យស្រាវជ្រាវមេរៀន និងលំហាត់ថ្មីៗ។ វិធីសាស្រ្តទាំងអស់នេះហើយដែលធ្វើឱ្យសិស្សទទួលបានជោគជ័យក្នុងការប្រឡង។ មានសិស្សតិចតួចណាស់ដែលបានពេញចិត្តខ្លះៗទៅលើវិធីសាស្រ្តបង្រៀន ដោយពួកគាត់យល់ថាការបង្រៀននៅសាលា

បង្រៀនតែទ្រឹស្តី អត់បានអនុវត្តន៍ គ្រូនិយាយច្រើនជាងក្នុងពេលបង្រៀន ហើយមានគ្រូខ្លះខ្វះសមត្ថភាពបង្រៀនដែលជាហេតុធ្វើឱ្យពួកគាត់ពេញចិត្តតិចតួច។

តាមការសិក្សារបស់ Flynn(2007)បានបង្ហាញថាគ្រូបង្រៀនជាអ្នកជួយសិស្សគ្រប់ពេលដែលសិស្សត្រូវការ និងជាអ្នកចង្អុលបង្ហាញឱ្យសិស្សដើរទៅរកផ្លូវត្រូវ មិនតែប៉ុណ្ណោះគ្រូជាតួសម្តែងក្នុងការបង្រៀនឱ្យសិស្សចាប់អារម្មណ៍និងចូលចិត្តរៀនជាមួយផងដែរ។ ដូច្នេះ កត្តាគ្រូបង្រៀនជាកត្តាមួយដែលមានសារសំខាន់បំផុតក្នុងការរៀនសូត្ររបស់សិស្ស។

### ៤.៤.៣ បរិស្ថានសាលារៀន

*ក្រាហ្វិកទី៩ ៖ ស្ថានភាពបរិស្ថានសាលារៀន*




តាមក្រាហ្វិកបានបង្ហាញថា នៅតាមសាលារៀនរបស់សិស្សដែលទទួលបាននិទ្ទេសA មានបរិស្ថានកម្រិតល្អ៧១.៤២% ចំណែកឯល្អបង្គួរមាន៩.៥២% និងមធ្យម ១៩.០៤%។ កម្រិតខ្សោយគឺ០%។

ជារួម យើងពិនិត្យលើទិន្នន័យចំពោះបរិស្ថានសាលារៀនគឺមានកម្រិតល្អភាគច្រើនដោយសារនៅសាលាបន្ទប់រៀន និងបន្ទប់អនាម័យមានផាសុខភាព មានស្ងួរច្បារ គ្មានសម្រាមនៅក្នុងថ្នាក់រៀន ទីធ្លាក៏គ្មានសម្រាម មានសួនផ្កា មានដើមឈើតូច ធំ គ្មានក្លិន ស្ថានភាពអគាររាំងមាំ បន្ទប់ទឹកមានអនាម័យ មានអគារគ្រប់គ្រាន់និងមានសភាពស្រស់គួរទាក់ទាញសិស្សឱ្យមានចិត្តចង់មករៀន មានការយកចិត្តទុកដាក់ពីសំណាក់អ្នកគ្រប់គ្រង និង

សហគមន៍ក្នុងការថែរក្សាបរិស្ថាន មានលោកគ្រូអ្នកគ្រូនាំគ្នាសម្អាតជាប្រចាំ មានសួនច្បារគ្រប់មុខថ្នាក់ មានសួនផ្កានៅតាមផ្លូវចូល។ ប៉ុន្តែក៏មានសិស្សមួយចំនួនទៀតបានយល់ថាបរិស្ថានសាលានៅមានកម្រិតល្អបង្គួរដោយសារនៅមានការប្រើប្រាស់ថង់ប្លាស្ទិចក្នុងបរិវេណសាលា មានសួនច្បារតិចតួច និងមានសម្រាមខ្លះក្នុងទីធ្លាសាលា។ ចំណែកកម្រិតបរិស្ថានមធ្យមក៏មានគួរសម ពីព្រោះនៅមានសម្រាមខ្លះៗនៅតាមថ្នាក់រៀន និងបរិវេនសាលា ដោយសារសិស្សមិនចេះសម្អាត និងមិនបានសហការជាមួយថ្នាក់ដឹកនាំសាលា មិនមានការថែទាំពីថ្នាក់គ្រប់គ្រងសាលា មិនមានសួនច្បារស្រស់បំព្រង បន្ទប់ទឹកខ្វះអនាម័យ។

នេះសរបញ្ជាក់ឱ្យឃើញថា សមត្ថភាពក៏ដូចជាចំណេះដឹង គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនសមស្របទៅតាមតម្រូវការក្នុងការលើកស្ទួយចំណេះដឹងផ្នែកបរិស្ថានសាលាសម្រាប់ទាក់ទាញសិស្សមករៀនសូត្រ។ កាលណាបរិស្ថានសាលាល្អ នោះការបង្រៀន និងការរៀនពិតជាមានលទ្ធផលល្អក្នុងការសិក្សា និងសិស្សប្រឡងជាប់ច្រើន។ យោងតាមអង្គការ ISF Cambodia បរិស្ថានក្នុងសាលារៀនស្អាតមានសារៈសំខាន់ និងមានឥទ្ធិពលដោយផ្ទាល់ទៅលើសុខភាពសិស្ស, គ្រូ និងបុគ្គលិកទាំងអស់។ ដើម្បីធ្វើឱ្យសាលាជាកន្លែងមានអនាម័យល្អដោយបានបង្រៀនសិស្សអំពីបរិស្ថាន និងឥទ្ធិពលរបស់វាចំពោះសុខភាព។ បន្ទាប់មក បានលើទឹកចិត្តពួកគេឱ្យចេះស្រឡាញ់ថែរក្សាបរិស្ថាន និងធ្វើការសម្អាតថ្នាក់រៀន កន្លែងលាងដៃក្នុងទីធ្លាសាលាជារៀងរាល់ថ្ងៃមុនម៉ោងចូលរៀន។ ម៉្យាងវិញទៀតបរិស្ថានសាលាក៏បានលើកទឹកចិត្តសិស្សឱ្យចូលរួមសម្អាតបរិស្ថានដែលនៅជុំវិញផ្ទះ និងនៅក្នុងសហគមន៍ផងដែរ។ ដូចបានបង្ហាញក្នុងក្រាហ្វិកខាងលើសិស្សនិទ្ទេសA២១នាក់ដែលមកពីសាលារៀនៗខុសគ្នាទូទាំងប្រទេសភាគច្រើនសាលារបស់ពួកគាត់មានបរិស្ថានកម្រិតល្អ។

### ៤.៤.៤ បន្ទប់កុំព្យូទ័រ បណ្ណាល័យ និងបន្ទប់ពិសោធន៍សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ

ក្រាហ្វិកទី១០៖ បន្ទប់កុំព្យូទ័រ បណ្ណាល័យ និងបន្ទប់ពិសោធន៍




លទ្ធផលដែលបង្ហាញក្នុងក្រាហ្វិកខាងលើបានបញ្ជាក់ថា សាលារបស់សិស្សនិទ្ទេសA ៨២% មានបន្ទប់កុំព្យូទ័រ។ ចំណែកឯ១៩.០៤%ទៀតគឺគ្មានបន្ទប់កុំព្យូទ័រទេ។ ចំពោះបណ្ណាល័យគឺមានទាំង១០០% រីឯបន្ទប់ពិសោធន៍វិញគឺមាន៦៦.៦៦%។ មានតែសិស្សនិទ្ទេសA ៣៣.៣៣%ប៉ុណ្ណោះដែលសាលារបស់ពួកគេគ្មានបន្ទប់ពិសោធន៍ ។

នេះសរបញ្ជាក់ឱ្យឃើញថា ក្នុងចំណោមសិស្សនិទ្ទេសAទាំង ២១នាក់ សាលារបស់ពួកគេសុទ្ធតែមានបន្ទប់កុំព្យូទ័រ ដើម្បីទុកឱ្យសិស្សរៀនពីបច្ចេកវិទ្យា និងសិក្សាស្រាវជ្រាវបង្កើនចំណេះដឹងព្រមទាំងពង្រឹងសមត្ថភាពខាងកុំព្យូទ័រដែលស្របទៅ នឹងការអប់រំនាពេលបច្ចុប្បន្នដែលកំពុងត្រូវការការរៀនពីចម្ងាយ។ ចំណែកឯសាលាមួយចំនួនទៀតដែលគ្មានបន្ទប់កុំព្យូទ័រពីព្រោះខ្វះបន្ទប់ គ្មានថវិកាក្នុងទិញកុំព្យូទ័រ រឺក៏គ្មានអ្នកជួយ។ បញ្ហានេះជាចំណុចមួយមិនល្អប្រសើរដែលធ្វើឱ្យមានការប៉ះពាល់ដល់ការសិក្សាស្រាជ្រាវ និងការរៀនដល់សិស្ស។ ចំពោះលទ្ធផលបន្ទប់បណ្ណាល័យនៅតាមសាលារៀនគឺមានទាំងអស់ បើទោះបីជាបណ្ណាល័យទាំងនោះមានលក្ខណៈស្តង់ដា រឺគ្មានក៏ដោយក៏សាលាទាំងនោះមានបន្ទប់ដាក់សៀវភៅសម្រាប់សិស្សានុសិស្សអានដែរ។ នេះជាចំណុចល្អប្រសើរសម្រាប់សិស្សអានសៀវភៅ និងសិក្សាស្រាវជ្រាវមេរៀន រឺធ្វើលំហាត់ ។ សម្រាប់បន្ទប់ពិសោធន៍នៅតាមសាលាមានអត្រាខ្ពស់គួរឱ្យកត់សម្គាល់ តាមភាពជាក់ស្តែងក្រសួង បានផ្តល់សម្ភារៈពិសោធន៍ស្ទើរតែគ្រប់សាលា ហើយម្យ៉ាងវិញទៀតមានសាលាខ្លះត្រូវផ្តល់ដោយគម្រោង(SEIP)ជួយក្នុងការរៀបចំទៀតផង។

ទោះបីជាយ៉ាងនេះក្តីក៏នៅមានសាលាមួយចំនួន មិនមានបន្ទប់ពិសោធន៍ដែរដោយសំអាងទៅលើគ្មានលទ្ធភាពសាងសង់បន្ទប់ រឺគ្មានបន្ទប់ គ្មានថវិកាសម្រាប់ធ្វើការពិសោធន៍ ។

ដូចនេះបើផ្ទៀងផ្ទាត់គ្នាជាមួយនឹងលទ្ធផលដែលបានមកពីការសម្ភាសន៍សិស្សនិទ្ទេស A ទាំង២១នាក់ អ្នកស្រាវជ្រាវអាចធ្វើការសន្និដ្ឋានបានថាសាលាភាគច្រើនមានសម្ភារគ្រប់គ្រាន់ដូចជាបន្ទប់កុំព្យូទ័រ បណ្ណាល័យ និងបន្ទប់ពិសោធន៍ជាដើមដែលធ្វើឱ្យការរៀននិងបង្រៀនមានប្រសិទ្ធភាព នាំសិស្សឱ្យទទួលបានជោគជ័យក្នុងការសិក្សា។

### ៤.៥ កត្តាគ្រួសារ

គ្រួសារជាកោសិកា នៃសង្គមដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណភាពអប់រំ និងការចូលរួមចំណែកតាមដានការសិក្សារបស់កូនៗ រឺក៏តាមដានការបង្រៀនរបស់គ្រូនៅតាមសាលាដែលកូនគាត់រៀន។ ម្យ៉ាងវិញទៀតពួកគាត់មានតួនាទីក្នុងការអប់រំ ផ្តល់ដំបូន្មានឱ្យកូនៗគាត់ក្លាយជាពលរដ្ឋល្អ សិស្សល្អដែលសង្គមត្រូវការជាចាំបាច់។ ចំពោះការជោគជ័យក្នុងការរៀនសូត្រ រឺ ការប្រឡងបាននិទ្ទេសល្អ កត្តាគ្រួសារបានរួមចំណែកយ៉ាងសកម្មក្នុងការបំពេញតួនាទីជាអ្នកផ្តល់នូវ ធនធានសម្ភារ ការលើកទឹកចិត្ត និងជំរុញកូនក្នុងការរៀនសូត្រ។

#### ៤.៥.១ ទស្សនៈនៃការយល់ឃើញរបស់ឪពុក ម្តាយ រឺអ្នកអាណាព្យាបាលចំពោះការសិក្សា

ក្រាហ្វិកទី១១៖ ទស្សនៈចំពោះការសិក្សា




ផ្អែកតាមទិន្នន័យក្នុងក្រាហ្វិកនេះបានបង្ហាញឱ្យឃើញថា ឪពុកម្តាយ រឺអ្នកអាណាព្យាបាលមានទស្សនៈល្អចំពោះការសិក្សា ១០០%។

ក្រោយពីស្រង់មតិសិស្សមក ឃើញថាឪពុកម្ដាយ រឺអ្នកអាណាព្យាបាលមានទស្សនៈល្អចំពោះការសិក្សា ពីព្រោះពួកគាត់យល់ឃើញថាការសិក្សាអាចឱ្យកូនមានអនាគត់ល្អ និងមានការងារជួយគ្រួសារ ក្លាយជាក្មេងល្អ និងកូនល្អ។ កាតព្វកិច្ចរបស់ឪពុកម្ដាយជាមនុស្សល្អនៅក្នុងសង្គម ហើយស្របតាមប្រសាសន៍របស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡានាពេលបច្ចុប្បន្នថាឪពុកម្ដាយត្រូវអប់រំកូននៅផ្ទះនិងតាមដានការរៀនសូត្ររបស់កូនពីចម្ងាយឱ្យបានគ្រប់ពេល។ ក្នុងន័យនេះឪពុកម្ដាយពិតជាចង់ឱ្យកូនរបស់គាត់ទទួលបាននូវចំណេះដឹងសមត្ថភាព ជំនាញពិតប្រាកដដើម្បីយកទៅអនុវត្តន៍នៅក្នុងសង្គម ។ ស្របតាមរបាយការណ៍របស់ធានាគារពិភពលោកឆ្នាំ២០០៧បានបង្ហាញថាគ្រប់ឪពុកម្ដាយ រឺអ្នកអាណាព្យាបាលសុទ្ធតែមានទស្សនៈល្អចំពោះការសិក្សារបស់កូនៗ។

### ៤.៥.២ ជំរុញ និងលើកទឹកចិត្តក្នុងការរៀនសូត្រ

ក្រាហ្វិកទី១២៖ ការជំរុញ និងការលើកទឹកចិត្តក្នុងការសិក្សា




ផ្អែកតាមលទ្ធផលដូចបានបង្ហាញក្នុងក្រាហ្វខាងលើ គ្រប់ឪពុកម្ដាយ រឺអ្នកអាណាព្យាបាលបានយល់ច្បាស់ពីការសិក្សារបស់កូនៗ ដោយបានជំរុញលើកទឹកចិត្តតាមរយៈ ការមើលសៀវភៅតាមដានប្រចាំខែ ឱ្យបន្តការសិក្សានៅសាកលវិទ្យាល័យ ណែនាំឱ្យប្រឹងរៀនសូត្រ ផ្ដល់ជាប្រាក់រង្វាន់ក្នុងការប្រឡងជាប់ ផ្ដល់សម្ភារសិក្សា ផ្ដល់សម្ភារប្រើប្រាស់ មានដំណើរកម្សាន្ត ញុំាអាហារជាលក្ខណៈគ្រួសារ ផ្ដល់ពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សារបស់កូ

នៗ  កត្តាទាំងអស់នេះហើយដែលនាំឱ្យការសិក្សារបស់កូនគាត់ទទួលបានជោគជ័យរហូតប្រឡងបាននិទ្ទេសA។

### ៤.៥.៣ ឪពុក ម្ដាយ រឺ អ្នកអាណាព្យាបាលក្នុងការតាមដានការសិក្សា

ក្រាហ្វិកទី១៣៖ ការតាមដានការសិក្សា




មាតាបីតាសិស្សនិទ្ទេសA ចំនួន៧១.៤២%បានតាមដានការសិក្សារបស់សិស្សជាប់ជាប្រចាំ  មានមាតាបីតាសិស្សនិទ្ទេសA ចំនួនតែ១៤.០៤% ប៉ុណ្ណោះដែលបានតាមដានការសិក្សារបស់កូនម្ដងកាល។ ចំណែកឯសិស្សនិទ្ទេសA ចំនួន១៤.០៤% ទៀតមិនបានតាមដានកូនទាល់តែសោះ។

ទោះជាយ៉ាងនេះក្ដី ឪពុកម្ដាយ រឺអ្នកអាណាព្យាបាលភាគច្រើនបានតាមដានការសិក្សារបស់កូន  ហេតុផលនេះសរបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់ឪពុកម្ដាយក្នុងការបំពេញតួនាទីចំពោះកូនដែលកំពុងសិក្សាហើយពួកគាត់គិតថាការតាមដានការសិក្សានេះជួយកូនគាត់ឱ្យបានទៅរៀនទៀងទាត់។ មានឪពុកម្ដាយរបស់សិស្សនិទ្ទេសA តិចតួចប៉ុណ្ណោះដែលបានតាមដានការសិក្សារបស់កូនម្ដងកាល ពីព្រោះគាត់យល់ឃើញថា គាត់មិនសូវមានពេលវេលាគ្រប់គ្រាន់ ហើយម្យ៉ាងទៀតគាត់មានទំនុកចិត្តលើកូនគាត់ទាំងស្រុងក្នុងការសិក្សា។ ទោះជាយ៉ាងនេះក៏ដោយ ក្នុងក្រាហ្វខាងលើនេះក៏បានបង្ហាញថា ឪពុកម្ដាយសិស្សនិទ្ទេសA ចំនួនមិនដែលបានតាមដានការសិក្សារបស់កូនទាល់តែសោះ ដោយសារ (១) រវល់ការងារផ្ទះ និងការរកស៊ី (២) មានទំនុកចិត្តលើកូន និង (៣) មិនយល់ពីតម្លៃនៃការសិក្សាជាដើម។ លទ្ធផលនេះសរបញ្ជាក់ឱ្យឃើញថា  លទ្ធផលនៃការសិក្សារបស់កូនភាគច្រើនគឺអាស្រ័យទៅ

លើការតាមដានរបស់ឪពុកម្តាយឬអ្នកអាណាព្យាបាល។ ភាគតិចណាស់ដែលអាស្រ័យលើកូនផ្ទាល់។

### ៤.៥.៤ ទំនាក់ទំនងជាមួយនាយក និងគ្រូនៅសាលា

ក្រាហ្វិកទី១៩ ៖ ទំនាក់ទំនងជាមួយសាលារៀន




ផ្អែកតាមក្រាហ្វទី១៩បានបង្ហាញឱ្យឃើញថាឪពុកម្តាយសិស្សទទួលបាននិទ្ទេស A មានទំនាក់ទំនងជាមួយសាលាមានអត្រាខ្ពស់ស្មើនឹង ៦១.៩០% និងមិនបានទំនាក់ទំនងមានចំនួនតែ៣៨.០៩%ប៉ុណ្ណោះ។

លទ្ធផលនេះបានបង្ហាញឱ្យឃើញថា ទំនាក់ទំនងឪពុកម្តាយជាមួយសាលារៀនមានអត្រាខ្ពស់ ដោយសារពួកគាត់មានការយល់ដឹងពីតម្លៃនៃការសិក្សារបស់កូន ទើបពួកគាត់មានពេលវេលាទំនាក់ទំនងជាមួយសាលាតាមរយៈកម្មវិធីបុណ្យផ្កា ឬកម្មវិធីប្រជុំផ្សេងៗក្នុងសាលារៀន។ ម៉្យាងវិញទៀត ពួកគាត់យល់ថា ការមានទំនាក់ទំនងជាមួយសាលាជួយឱ្យកូនគាត់មករៀនបានទៀងទាត់ ហើយរាល់ពេលកូនគាត់មានបញ្ហាសាលាផ្តល់ព័ត៌មានបានទាន់ពេលវេលា។ ចំពោះឪពុកម្តាយ រឺអ្នកអាណាព្យាបាលមួយចំនួន ដែលមិនមានទំនាក់ទំនងជាមួយសាលា គឺដោយសារពួកគាត់រវល់រកស៊ីចិញ្ចឹមជីវិត ផ្ទះនៅឆ្ងាយសាលា មិនមានអីចាំបាច់ក្នុងការទំនាក់ទំនងជាមួយសាលា និងឪពុកម្តាយទៅធ្វើការនៅក្រៅប្រទេស។ ក្នុងន័យនេះបញ្ជាក់ថាការមានទំនាក់ទំនងជាមួយសាលាពិតជាសំខាន់សម្រាប់ការសិក្សារបស់កូន។ បើសិនមិនមានទំនាក់ទំនងជាមួយសាលារៀនទេអាចធ្វើឱ្យមានការប៉ះពាល់ដល់ការសិក្សា នៅ

ពេលដែលកូនមានបញ្ហាសាលាមិនអាចផ្តល់ព័ត៌មានទៅគ្រួសារបានភ្លាមៗ ហើយបើគ្រួសារមានបញ្ហាវិញក៏មិនអាចផ្តល់ព័ត៌មានបានភ្លាមៗដែរ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន ការពិភាក្សា និង
# សំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងវិភាគទិន្នន័យលើប្រធានបទ «កត្តាជោគជ័យរបស់សិស្សទទួលបាននិទ្ទេសA ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា» បានបង្ហាញថា មានកត្តាជោគជ័យមួយចំនួន ដែលមានការពាក់ព័ន្ធដល់ការសិក្សានេះ កត្តាទាំងនោះមានដូចជា កត្តាសិស្សផ្ទាល់ កត្តាសាលារៀន និងកត្តាគ្រួសារជាដើម។ ការសិក្សានេះ គ្រាន់តែផ្អែកទៅលើសិស្សនិទ្ទេសA ជាពិសេសគឺឆ្លុះបញ្ចាំងដល់កត្តាជោគជ័យ ក្នុងការការសិក្សាក៏ដូចជាការប្រឡងសញ្ញាបត្រមធ្យមសិក្សា។ កត្តាជោគជ័យទាំងនោះ នឹងត្រូវធ្វើការវិភាគនិងទាញសេចក្តីសន្និដ្ឋានលម្អិតដូចតទៅៈ

### ៥.១.១ កត្តាសាលារៀន

ការគ្រប់គ្រងសាលាពិតជាសំខាន់ណាស់ ដល់ដំណើរការបង្រៀន និងការរៀនសូត្ររបស់សិស្ស។ ការគ្រប់គ្រងល្អ និងការប្រកាន់ភ្ជាប់នូវគោលការណ៍ធ្វើឱ្យសាលាក្លាយទៅជាសាលាគំរូដែលគេទទួលស្គាល់គ្រប់ទិសទីដូចសាលាវត្តបូព៌ជាដើម។ សាលារៀនទាំងអស់ត្រូវមានគោលការណ៍គ្រប់គ្រងមួយច្បាស់លាស់ និងមានភាពជាក់លាក់ដែលបុគ្គលិកគ្រប់រូបត្រូវតែអនុវត្តដោយខានមិនបាន ពីព្រោះបើការគ្រប់គ្រងមួយមិនបានល្អវាមានផលប៉ះពាល់ជាច្រើនដល់កត្តាជោគជ័យរបស់សិស្សក្នុងការប្រឡង។ ហេតុដូចនេះ ការគ្រប់គ្រងមួយដែលល្អគឺទាមទារឱ្យមានការធ្វើផែនការ ការអនុវត្តផែនការ និងការវាយតម្លៃសកម្មភាពការងារឱ្យបានច្បាស់លាស់ទើបអាចទទួលបាននូវលទ្ធផលល្អប្រសើរ។ បន្ថែមលើនេះទៅទៀត ការគ្រប់គ្រងមួយដែលល្អ គឺត្រូវចេះបង្កើតសកម្មភាពដល់សិស្សក្នុងការសិក្សា តាមរយៈការបង្កើតក្លឹបសិក្សា ការបង្កើតឱ្យមានបន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ និងបន្ទប់បណ្ណាល័យឬសាលអានជាដើម ដើម្បីពង្រឹងការរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ ព្រោះវាជាកត្តាដែលជួយឱ្យ

សិស្សទទួលបានជោគជ័យក្នុងការសិក្សា និងការប្រឡងនានា ហើយក៏មានប្រយោជន៍ដល់ការសិក្សាសម្រាប់ក្មេងៗជំនាន់ក្រោយទៀតផងដែរ។

ដូច្នេះទិន្នន័យក្នុងជំពូកទី៤បានបង្ហាញថា គណៈគ្រប់គ្រងសាលាបានយកចិត្តទុកដាក់ចំពោះការសិក្សារបស់សិស្ស។ បន្ថែមពីនេះទៅទៀតលោកគ្រូអ្នកគ្រូក៏បានបង្រៀន និងផ្ទេរចំណេះដឹងដល់សិស្សបានល្អដែរ ហើយសាលាភាគច្រើនមានបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ និងបណ្ណាល័យ។ សាលាភាគច្រើនដែលមានសិស្សនិទ្ទេសAគឺមានបរិស្ថានស្រស់ស្អាត ក្នុងការទាក់ទាញសិស្សឱ្យមករៀន។ ប្រការទាំងអស់នេះហើយ ដែលជួយជ្រោមជ្រែងសិស្សក្នុងការសិក្សារៀនសូត្រ ឱ្យទទួលបាននិទ្ទេសAក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

### ៥.១.២ កត្តាគ្រួសារ

ចំពោះកត្តាគ្រួសារនេះ យើងអង្កេតឃើញថាពិតជាបានរួមចំណែកយ៉ាងសកម្មក្នុងការជួយជ្រោមជ្រែងសិស្សក្នុងការសិក្សាជាពិសេសលើផ្នែកធនធានសម្ភារ និងស្មារតីក្នុងការបញ្ជូនកូនមករៀន។ គ្រប់គ្រួសារទាំងអស់មានទស្សនៈយល់ឃើញដូចគ្នាថា ការសិក្សាពិតជាល្អ។ មិនតែប៉ុណ្ណោះ ពួកគាត់យល់ថាការសិក្សាពិតជាជួយឱ្យកូនគាត់ទទួលបានសេចក្ដីថ្លៃថ្នូរក្លាយជាកូនល្អ សិស្សល្អ និងជាបុគ្គលល្អនៅក្នុងសង្គម ហើយសង្ឃឹមថានៅថ្ងៃអនាគត់នឹងមានការងារជួយគ្រួសារវិញជាក់ជាមិនខាន។ ឪពុកម្ដាយភាគច្រើនបានជំរុញ លើកទឹកចិត្តតាមដានការសិក្សា និងធ្វើការទំនាក់ទំនងជាមួយសាលា ដើម្បីឱ្យកូនរបស់គាត់ខិតខំប្រឹងប្រែងរៀនសូត្រ ដោយបានផ្ដល់នូវសម្ភារសិក្សាដែលកូនត្រូវការ។ ប៉ុន្តែក៏នៅមានឪពុកម្ដាយមួយចំនួនតូចដែលមិនបានយកចិត្តទុកដាក់និងតាមដានការសិក្សារបស់កូន ដោយសាររវល់នឹងការងារ និងការធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស។

### ៥.១.៣ កត្តាផ្ទាល់ខ្លួន

តាមការបកស្រាយចំពោះកត្តាផ្ទាល់ខ្លួនឃើញថា សិស្សមានវិធីសាស្ត្រច្រើនក្នុងការសិក្សា ដោយសិស្សខ្លះ បែងចែកកាលវិភាគរៀននៅផ្ទះ ការខិតខំប្រឹងប្រែងរៀនដោយខ្លួនឯងនៅក្នុងសាលា ការសិក្សាស្រាវជ្រាវមេរៀន ការធ្វើលំហាត់តាមInternet ការរៀនតាមឯកសារគ្រូផ្ដល់ឱ្យ តាមសៀវភៅកំណែ និងតាមឯកសារផ្សេងៗទៀត ការខិតខំប្រឹងប្រែងក្នុងការសិក្សាស្ដាប់គ្រូពន្យល់ ការកំណត់គោលដៅច្បាស់លាស់ក្នុងការរៀនសូត្រ ការជំរុញចិត្តខ្លួន

ឯងឱ្យចង់បាននិទ្ទេសA ការអានសៀវភៅ និងការស្វែងរកការរៀនគួរបន្ថែមក្នុងមួយថ្ងៃពី៤ទៅ៥ម៉ោង។ បន្ថែមពីលើនេះទៀត សិស្សខ្លះបង្កើតក្លឹបសិក្សាជួយបង្រៀនគ្នាទៅវិញទៅមកដើម្បីដឹងពីសមត្ថភាពថា ខ្លួនខ្សោយមុខវិជ្ជាអ្វី ហើយខិតខំប្រឹងប្រែងរៀនមុខវិជ្ជានោះ។ ប៉ុន្តែតាមរយៈការស្រាវជ្រាវនេះ កត្តាផ្ទាល់ខ្លួនក៏មានបញ្ហាមួយចំនួនផងដែរសម្រាប់សិស្សដូចជាការធ្វើដំណើរឆ្ងាយពីសាលា ការខ្វះថវិការៀនគួរ ការរៀននៅសាលារដ្ឋមិនបានដិតដល់ជាដើម។ សរុបសេចក្តីមកកត្តាដែលជះឥទ្ធិពលខ្លាំងធ្វើឱ្យសិស្សអាចទទួលបាននិទ្ទេសA ក្នុងការប្រឡងគឺកត្តាសិស្សខ្លួនឯង បន្ទាប់មកកត្តាសាលារៀន និងចុងក្រោយកត្តាគ្រួសារ ។

## ៥.៣ សំណូមពរ

ដើម្បីរួមចំណែកក្នុងការលើកស្ទួយគុណភាពអប់រំ និងប្រសិទ្ធភាពនៃការបង្រៀន និងរៀនឱ្យសិស្សទទួលបានជោគជ័យក្នុងការប្រឡង ក៏ដូចជាការចូលរួមមួយផ្នែកក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជាទាំងមូល អ្នកសិក្សាសូមលើកនូវសំណូមពរមួយចំនួនដល់សាលារៀន គ្រួសារសិស្ស ក្រសួងអប់រំ យុវជន និងកីឡា និងសិស្សផ្ទាល់ដូចខាងក្រោម៖

### ៥.៣.១ ក្រសួងអប់រំ យុវជន និងកីឡា

- សូមបន្តអនុវត្តការប្រឡងក្រោមពាក្យស្លោក(អ្នកចេះគឺជាប់) ជារៀងរហូត ។
- សូមបន្តរឹតបន្តឹងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យមានតម្លាភាព និងយុត្តិធម៌។
- សូមជួយជំរុញ និងលើកទឹកចិត្តសិស្សដែលទទួលបាននិទ្ទេសAតាមរយៈការផ្តល់អាហារូបករណ៍ឬការផ្តល់សម្ភារៈផ្សេងៗ។
- សូមពិនិត្យលទ្ធភាពសាងសង់បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍នៅតាមសាលាមធ្យមសិក្សា។

### ៥.៣.២ សាលារៀន

- ពង្រឹងការបង្រៀន ការតាមដាននិងវាយតម្លៃគ្រូឱ្យបានញឹកញាប់ និងមានផែនការច្បាស់លាស់ក្នុងអភិវឌ្ឍន៍សាលាដើម្បីជួយសិស្ស។
- ពង្រឹងអនាម័យនៅតាមបន្ទប់ និងទីធ្លាសាលាឱ្យបានជាប្រចាំ។

- ពង្រឹងការរៀន ការតាមដានអវត្តមានសិស្ស និងលើកទឹកចិត្តពេលដែលសិស្សប្រឡងទទួលបាននិទ្ទេសល្អ។
- សូមបង្កើតបន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រដើម្បីឱ្យសិស្សបានសិក្សាស្រាវជ្រាវ និងពិសោធន៍ទៅលើមុខវិជ្ជា ជីវវិទ្យា គីមីវិទ្យា និងរូបវិទ្យាជាដើម។
- សូមបង្កើតក្លឹបសិក្សានៅតាមសាលាឱ្យបានគ្រប់សាលាដើម្បីជួយសិស្សរៀនខ្សោយ និងរៀនយឺត។

### ៥.៣.៣ គ្រួសារសិស្ស

- ត្រូវជំរុញ លើកទឹកចិត្តកូនឱ្យខិតខំរៀនសូត្រទាំងនៅផ្ទះនិងនៅសាលា។
- កុំដាក់សម្ពាធការងារដល់កូនកំពុងស្ថិតក្នុងឆ្នាំប្រឡង។
- បន្តតាមដានការសិក្សារបស់កូនជាប្រចាំ ទោះបីមានការងាររវល់យ៉ាងណាក្តី។
- ត្រូវមានទំនាក់ទំនងជាមួយសាលារៀនជាប់ជាប្រចាំ ដើម្បីទទួលបានព័ត៌មានអំពីការសិក្សារបស់កូន និងព័ត៌មានអំពីកូនទៅសាលាវិញ។
- យកចិត្តទុកដាក់ និងចូលរួមអភិវឌ្ឍន៍សាលា តាមរយៈការចូលរួមប្រជុំ និងការផ្តល់សម្ភារតាមលទ្ធភាពដែលមាន។

### ៥.៣.៤ សិស្ស

- ត្រូវខិតខំរៀនសូត្រ គោរពវិន័យសាលា ចេះជួយមិត្តភក្តិ និងជួយបង្រៀនអ្នកដែលរៀនខ្សោយ រឺរៀនយឺត។
- ត្រូវជៀសឆ្ងាយពីគ្រឿងស្រវឹង គ្រឿងញៀន និងបារីជាដើម។
- ត្រូវចេះគោរពលោកគ្រូ អ្នកគ្រូ និងឪពុកម្តាយ ។
- ធ្វើខ្លួនជាសិស្សល្អ កូនល្អ និងពលរដ្ឋល្អ ។

## ៥.៤ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវនេះ ផ្តោតតែលើកត្តាជោគជ័យសិស្សទទួលបាននិទ្ទេសA ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាតែប៉ុណ្ណោះ ហើយសម្រាប់អ្នកស្រាវជ្រាវបន្តទៀតអាចពិចារណាទៅលើចំណុចខាងក្រោម៖

- ស្រាវជ្រាវលើប្រធានបទដដែល តែការជ្រើសរើសសំណាកធំជាងនេះ ដោយធ្វើការប្រមូលទិន្នន័យតាមគុណវិស័យ តាមរយៈការសម្ភាសន៍ រឺពិភាក្សាក្រុម និងជ្រើសរើសករណីសិក្សាឱ្យបានពីរ រឺបីសាកលវិទ្យាល័យដែលសិស្សនិទ្ទេសA ចូលរៀន។

# ឯកសារយោង


រាជរដ្ឋាភិបាលកម្ពុជា សៀវភៅផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ ២០១៩-២០២៣

រាជរដ្ឋាភិបាលកម្ពុជា គោលនយោបាយជាតិស្តីអំពីការអភិវឌ្ឍន៍វិស័យអប់រំ ២០១៥

ក្រសួងអប់រំយុវជន និងកីឡា សៀវភៅផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០១៩-២០២៣

ក្រសួងអប់រំយុវជន និងកីឡា សៀវភៅផែនទីបង្ហាញផ្លូវឆ្នាំ ២០៣០ កុម្ភៈ ២០១៩

ក្រសួងអប់រំយុវជន និងកីឡា គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុង វិស័យអប់រំ ២០១៦

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ សៀវភៅបំណិនវិជ្ជាជីវៈឆ្នាំ ២០០៦

នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ កំណែទម្រង់ការការប្រឡងមធ្យមសិក្សា ១៩ មីនា ២០១៩

បណ្ឌិត ចៅ លិន ការអប់រំនៅកម្ពុជា គ.ស ២០១១

បណ្ឌិត ចៅ លិន ការអភិវឌ្ឍធនធានមនុស្សដើម្បីជោគជ័យ ឆ្នាំ ២០១១

ឯកឧត្តមបណ្ឌិត ស៊ន សេងហុក ទស្សនវិជ្ជានៃការអប់រំ ច្បាប់ និងការអប់រំគោនយោបាយអប់រំ ឆ្នាំ ២០១៩

ហួរ ឈុនគ្រី ប៉ូប៊ុន្តូន ម៉ែន សុខនី ក្រមសីលធម៌វិជ្ជាជីវៈនាយកសាលា មិថុនា ២០១៩

ភ្នំពេញប៉ុស្តិ៍ និយមន័យជោគជ័យ ២១ វិច្ឆិកា ២០១៧

Mintzberg, H. (2009). The best leadership is good management. Retrieved Feb 11, 2011, From http://www.businessweek.com/magazine/content/09_33/b4143068890733.htm: Bloomberg Businessweek.

Sutherland, P., & Crowther, J. (2006). Lifelong learning. In H. Pillay, L. Wilssand G. B. Lewis, Work and learning: Implications for lifelong learning in the workplace (Chap. 20, pp. 218-227).USA: Routledge.

Walker, K. (2009). Cambodian post-graduate students; An exploratory study of an unknown entity.Personal correspondence

Berker, A., & Horn, L. (2003). Work first, study second.US: NCES.

Liebowits, M., & Taylor, J. C. (2004).

Breaking though: Helping low-skilled adults enter and succeed in college and careers.

US: Job for the Future/NCWE.

www.rfi.fr world-history-biog June 20, 2017

http://www.rfi.fr/km/cambodia/success-story-20-08-2019

https://pressocm.gov.kh/archives/57893

https://thmeythmey.com/event/?page=detail&id=30870

https://www.rfa.org/khmer/event/chuon_nath_biography-09222011050505.html

https://pressocm.gov.kh/archives/38323 Oct 18,2018

https://www.ahladang.com/archives/11651

https://camhr.com/pages/articles/article.jsp?id=10001225

https://www.bizkhmer.com/articles/26521

https://camhr.com/pages/articles/article.jsp?id=10001225

https://thmeythmey.com/?page=detail&id=36836

http://unicefcambodia.blogspot.com/2017/02/blog-post.html

https://www.facebook.com/isf.cambodia/posts/1054530804618701/

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ**៦៥២០ **អយក.**វជអ

ថ្ងៃ សុក្រ ១១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**ជម្រាបមក**
**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវរបស់និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៅតាមសាកលវិទ្យាល័យ និងរាជធានី ខេត្ត។
**យោង** ៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ ឆ្នាំសិក្សា ២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកប្រធានថា៖ និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៃវិទ្យាស្ថានជាតិអប់រំ ចំនួន១៣នាក់ ដូចមានក្នុងលិខិតឧទ្ទេសនាមជូនភ្ជាប់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរ និក្ខេបបទស្រាវជ្រាវតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម លោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
-ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
-សាលារាជធានី-ខេត្តពាក់ព័ន្ធ
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងអ.យ.ក
"ដើម្បីជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ - ឯកសារ វជអ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៦៣៣ **អយក.** ទស

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ឆ្នាំសិក្សា ២០១៨-២០១៩។

និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ នៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវ តាមសាកលវិទ្យាល័យ និងរាជធានី ខេត្តនានា ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០ តាមបំណែងចែកដូចខាងក្រោម៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កូវ ប៊ុន្ថា | ប្រុស | តាកែវ |
| ២ | កែម សុកែវ | ប្រុស | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣ | ជិន ភិរម្យ | ប្រុស | ព្រៃវែង |
| ៤ | ញ៉ែម ធា | ប្រុស | ត្បូងឃ្មុំ កំពង់ចាម ព្រៃវែង |
| ៥ | ឌឿន សុគុណ | ប្រុស | ព្រៃវែង |
| ៦ | ផន ឡេង | ប្រុស | ភ្នំពេញ |
| ៧ | ភោគ ស៊ីថន | ប្រុស | សៀមរាប |
| ៨ | ម៉េត ចាន់ណេត | ប្រុស | កណ្តាល |
| ៩ | យ៉ុន សុខេន | ប្រុស | ភ្នំពេញ |
| ១០ | វ៉ាន់ លីឆេង | ប្រុស | បាត់ដំបង |
| ១១ | ស្រី ស្មើ | ប្រុស | ភ្នំពេញ |
| ១២ | ហុក វិចិត្រ | ប្រុស | ព្រះវិហារ |
| ១៣ | ឡុង ចំណាន | ប្រុស | កំពង់ចាម |

ថ្ងៃ សុក្រ ១១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- សាលារាជធានី-ខេត្តពាក់ព័ន្ធ "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងអ.យ.ក "ដើម្បីជ្រាបជាព័ត៌មាន"
- មន្ទីរអ.យ.ក រាជធានី-ខេត្តដែលពាក់ព័ន្ធ "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

# កម្រងសំណួរ

ខ្ញុំបាទឈ្មោះ **យ៉ុន សុខេន** ជានិស្សិតវគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី ២ ឆ្នាំសិក្សា ២០១៨-២០១៩ នៅវិទ្យាស្ថានជាតិអប់រំ ត្រូវបានរៀបចំធ្វើការសិក្សាស្រាវជ្រាវមួយដែលទាក់ទងទៅនឹងប្រធានបទ៖ ***កត្តាជោគជ័យរបស់សិស្សទទួលបាននិទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។***

សូមប្អូនៗរួមចំណែកក្នុងការសិក្សារបស់ខ្ញុំ ដោយឆ្លើយនូវកម្រងសំណួរមួយចំនួនដូចខាងក្រោម។ ខ្ញុំជឿជាក់ថាការចូលរួមនេះ ពិតជាមានសារៈសំខាន់ក្នុងការផ្តល់ចម្លើយសម្រាប់ខ្ញុំ ក្នុងការសិក្សាស្រាវជ្រាវនេះ។ ខ្ញុំសូមថ្លែងអំណរគុណទុកជាមុនចំពោះការចូររួមផ្តល់ចម្លើយរបស់ប្អូនៗ ហើយខ្ញុំបាទសូមធានាខុសត្រូវទាំងស្រុងនូវរាល់ចម្លើយរបស់ប្អូនៗ នឹងត្រូវបានរក្សាទុកជាការសម្ងាត់។

## I. ព័ត៌មានទូទៅ

១. ឈ្មោះ......................................... ភេទ ☐ ប្រុស ☐ ស្រី អាយុ...................

២.ឪពុក.......................................... មុខរបរ..................................................................

៣.ម្តាយ.......................................... មុខរបរ..................................................................

៤.មកពីខេត្ត.................................... វិទ្យាល័យ................................ឆ្នាំប្រឡងបាក់ឌុប.......

៥.រៀនឯកទេស(RUPP)............................................................ ឆ្នាំទី................................

៦.លេខទូរស័ព្ទទំនាក់ទំនង......................................................................................

## II. កត្តាផ្ទាល់ខ្លួន

១.តើមានកត្តាផ្ទាល់ខ្លួនអ្វីខ្លះដែលធ្វើឱ្យប្អូនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទទួលបាននិទ្ទេស A?

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

២. តើប្អូនមានវិធីសាស្រ្តអ្វីខ្លះដើម្បីអានសៀវភៅឱ្យយល់ និងចាំបានល្អ ?

.........................................................................................................................

.........................................................................................................................

……………………………………………………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………………….......

៣. តើប្អូនចំណាយពេលរៀនខ្លួនឯងប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………………….......

៤. តើប្អូនចំណាយពេលរៀនគួរប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………………….......

៥. តើប្អូនចំណាយពេលរៀនជាមួយមិត្តភក្តិប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………………….......

៦. តើប្អូនស្រាវជ្រាវលំហាត់ និងមេរៀនតាមរយៈអ្វីខ្លះ ? មានយៈពេលប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៧. តាមការយល់ឃើញរបស់ប្អូនការរៀននៅសាលាមាន ប្រសិទ្ធភាពកម្រិតណាសម្រាប់ប្អូន?*សូមដាក់ពិន្ទុពីលេខ ១ ដល់លេខ ៥។*

| | | | | |
|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 |

ហេតុអ្វីបានជាប្អូនដាក់ពិន្ទុដូច្នេះ?

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

៨.តាមការគិតរបស់ប្អូនទាក់ទងទៅ និងការរៀនដោយខ្លួនឯងមានប្រសិទ្ធភាពកម្រិតណា?
*សូមដាក់ពិន្ទុពីលេខ១ដល់លេខ៥*

| | | | | |
|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 |

ហេតុអ្វីបានជាប្អូនដាក់ពិន្ទុដូច្នេះ?

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

## III. **កត្តាសាលារៀន**

១. តើគណៈគ្រប់គ្រងសាលាបានផ្ដល់អ្វីខ្លះសម្រាប់ប្អូនក្នុងការប្រឡងបាននិទ្ទេសA?

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

២. តើលោកគ្រូ អ្នកគ្រូបានបង្រៀនវិធីសាស្ត្រអ្វីខ្លះ ដល់ប្អូន?

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

៣. សាលារៀនរបស់ប្អូនមានបានបង្កើតក្លឹបសិក្សាដែរ រឺទេ? ហេតុអ្វី?

.............................................................................................................................

.............................................................................................................................

..................................................................................................................................

..................................................................................................................................

៤. នៅសាលារបស់ប្អូន បរិស្ថានមានស្ថានភាពកម្រិតណា? ហេតុអ្វី?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

៥. តើសាលារៀនប្អូនមានបន្ទប់កុំព្យូទ័រ បណ្ណាល័យ និងបន្ទប់ពិសោធន៍សម្រាប់ឱ្យប្អូនៗធ្វើការសិក្សាស្រាវជ្រាវដែរ រឺទេ?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

៦. តាមប្អូនគិត កត្តាសាលារៀន ឬ កត្តាខ្លួនប្អូនផ្ទាល់ ដែលជំរុញឱ្យប្អូនរៀនបាននិទ្ទេសA? ហេតុអ្វីបានជាប្អូនគិតដូច្នេះ?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

VI. **កត្តាគ្រួសារ**

១. តើឪពុកម្តាយ រឺអាណាព្យាបាលរបស់ប្អូនគាត់មានគំនិតយ៉ាងណាក្នុងការបញ្ជូនប្អូនមករៀន?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

២. តើឪពុក ម្តាយ រឺអាណាព្យាបាលប្អូនបានជំរុញ និងលើកទឹកចិត្តប្អូនក្នុងការរៀនសូត្រដែររឺទេ? បើបានជំរុញតាមវិធីណា? បើមិនបានហេតុអ្វី?

..................................................................................................................................

..................................................................................................................................

......................................................................................................................................................

......................................................................................................................................................

៣. តើឪពុក ម្តាយ រឺអាណាព្យាបាលប្អូនមានបានផ្តល់សម្ភារៈក្នុងការសិក្សាដល់ប្អូនក្នុងការរៀនសូត្រដែររឺទេ?

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

៤. តើឪពុក ម្តាយ រឺអាណាព្យាបាលប្អូនមានបានតាមដានការសិក្សារបស់ប្អូនដែររឺទេ?

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

៥. តើឪពុក ម្តាយ រឺអាណាព្យាបាលប្អូនមានបានទំនាក់ទំនងជាមួយនាយក និងគ្រូនៅសាលាដែររឺទែ?

......................................................................................................................................................

......................................................................................................................................................